ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# របាយការណ៍ជាតិលើកទី១និងទី២

# ស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារ

# ស្តីពី

# ការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ

# និងរូបភាពអាសអាភាសកុមារ

ឆ្នាំ២០០២ដល់២០១០

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ

នាថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១១

រៀបចំដោយ

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

# មាតិកា


ទំព័រ

សេចក្តីផ្តើម ........ ១

ព័ត៌មានទូទៅ ........ ១

ទិន្នន័យ ........ ២

វិធានការទូទៅនៃការអនុវត្ត ........ ៨

ការបង្ការ ........ ២២

ការហាមឃាត់និងបញ្ហាពាក់ព័ន្ធ ........ ២៨

ការការពារសិទ្ធិជនរងគ្រោះ ........ ៣៩

ជំនួយនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ ........ ៤៤

បទប្បញ្ញាត្តិច្បាប់ដទៃទៀត ........ ៤៦

សេចក្តីសន្និដ្ឋាន ........ ៤៧

## សេចក្តីផ្តើម

ព្រះរាជាណាចក្រកម្ពុជា បានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២ និងបានផ្តល់សច្ចាប័នលើពិធីសារបន្ថែមស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០២ ដោយពុំមានដាក់ឧបសម្រុង។ ឯកសារនេះជារបាយការណ៍លើកទី១និងលើកទី២ ដែលបរិយាយពីការអនុវត្តពិធីសារចន្លោះពីឆ្នាំ២០០២ ដល់ឆ្នាំ២០១០ ដោយឆ្លើយតបនឹងការអនុវត្តកាតព្វកិច្ច យោងតាមកថាខណ្ឌទី១និងកថាខណ្ឌទី២ មាត្រា១២នៃពិធីសារបន្ថែមនិងកថាខណ្ឌទី១(ខ) មាត្រា៤៤នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។

## ព័ត៌មានទូទៅ

១- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានបង្កើតក្រុមការងារមួយដែលមានសមាសភាពមកពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងយុត្តិធម៌ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រសួងទេសចរណ៍ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងផែនការ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រុមប្រឹក្សាអ្នកច្បាប់ មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ(UNICEF) គម្រោងអន្តរៈទីភ្នាក់ងារអង្គការសហប្រជាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (UNIAP) គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ(NGOCRC) គណៈកម្មាធិការបំបាត់ពេស្យាចារ ការរំលោភ និងការជួញដូរកុមារនៅកម្ពុជា(ECPAT) សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលដើម្បីដោះស្រាយបញ្ហាជួញដូរនិងកេងប្រវ័ញ្ចផ្លូវភេទលើកុមារក្នុងប្រទេសកម្ពុជា(COSECAM) និងសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលប្រឆាំងការជួញដូរកុមារនៅកម្ពុជា(Cambodia ACTs) ដើម្បីសរសេររបាយការណ៍ស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ។ ក្រុមការងារនេះ អាចអនុញ្ញាតឲ្យអង្គការមិនមែនរដ្ឋាភិបាលនិងអង្គការអន្តរជាតិផ្សេងទៀតចូលរួមផ្តល់យោបល់លើរបាយការណ៍។ របាយការណ៍នេះត្រូវបានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារធ្វើការពិគ្រោះយោបល់ដើម្បីស្វែងរកការផ្តល់មតិបន្ថែមពីកុមារមកពី១៦រាជធានី ខេត្ត តាមរយៈវេទិកាកុមារថ្នាក់ជាតិដែលបានប្រព្រឹត្តទៅនៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១០ និងពីអ្នកដែលធ្វើការងារពាក់ព័ន្ធ មកពីក្រសួង ស្ថាប័ន និងអង្គការមិនមែនរដ្ឋាភិបាលតាមរយៈសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១០។ មតិរបស់កុមារនិងអ្នកធ្វើការងារពាក់ព័ន្ធ ត្រូវបានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារយកមកពិចារណាយ៉ាងល្អិតល្អន់ក្នុងការធ្វើរបាយការណ៍នេះ។

២- ព្រះរាជាណាចក្រកម្ពុជាអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារនិងពិធីសារបន្ថែមស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ តាមវិធីសាស្ត្រដោយផ្អែកលើសិទ្ធិមនុស្ស ជាពិសេសសិទ្ធិកុមារធ្វើជាមូលដ្ឋានសម្រាប់រៀបចំកម្មវិធី។ គោលការណ៍ឧត្តមប្រយោជន៍របស់កុមារ ការមិនរើសអើង សិទ្ធិមានជីវិត សិទ្ធិរស់រានមានជីវិតនិងសិទ្ធិអភិវឌ្ឍ និងការគោរពទស្សនៈរបស់កុមារ ត្រូវ

បានយកធ្វើជាស្នូលនៃគ្រប់កម្មវិធី គម្រោង និងសកម្មភាព។ ការអនុវត្តសិទ្ធិកុមារត្រូវបានរៀបចំជាកម្មវិធីប្រចាំប្រទេសរៀងរាល់០៥ឆ្នាំម្តង និងតាមឆ្នាំនីមួយៗរៀបចំជាកម្មវិធីប្រចាំឆ្នាំដោយមានកំណត់សូចនាករដែលត្រូវធ្វើឲ្យបានសម្រេចក្នុងឆ្នាំនីមួយៗ។

៣- ក្រុមប្រឹក្សាធម្មនុញ្ញបានចេញសេចក្តីសម្រេចលេខ០៩២/០០៣/២០០៧ កបធ.ច ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ ដែលបានកំណត់ថា "ក្នុងការជំនុំជម្រះក្តី ចៅក្រមត្រូវផ្អែកលើច្បាប់"។ ពាក្យថាច្បាប់ខាងលើនេះមានន័យថាច្បាប់ជាតិ រួមមានរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូល ច្បាប់ទាំងឡាយដែលនៅជាធរមាន និងច្បាប់អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាបានទទួលស្គាល់រួចមកហើយ ជាពិសេសអនុសញ្ញាស្តីពីសិទ្ធិកុមារ។ ក្នុងរឿងក្តីព្រហ្មទណ្ឌ ច្បាប់ត្រូវបកស្រាយយ៉ាងតឹងរឹង។ ចៅក្រមមិនអាចពង្រីកវិសាលភាពអនុវត្តឬប្រព្រឹត្តតាមសទិសភាពបានឡើយ។

៤- គិតចាប់ពីពេលដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើពិធីសារហូតមកដល់បច្ចុប្បន្ននេះ និងអនុលោមតាមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ស្ថានភាពស្ត្រីនិងកុមារមានការរីកចម្រើនគួរឲ្យកត់សម្គាល់។ មានវិស័យជាច្រើនត្រូវបានយកចិត្តទុកដាក់ខ្ពស់ ដូចជាការលុបបំបាត់ការជួញដូរកុមារ ពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ និងមានការធានាឲ្យមានកិច្ចការពារនិងការទទួលបានសិទ្ធិដែលមានចែងក្នុងពិធីសារ។ ទន្ទឹមនឹងនេះ មានកុមារព្រះរាជាណាចក្រកម្ពុជាមួយចំនួននៅតែប្រឈមមុខនឹងបញ្ហាអំពើហិង្សា ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្សេងៗ។

## ទិន្នន័យ

៥- ច្បាប់ស្តីពីស្ថិតិ ដែលគ្រប់គ្រងលើផ្នែកទាំងអស់ទាក់ទងនឹងការប្រមូលដំណើរការនៃការចងក្រង ការវិភាគ ការបោះពុម្ព និងការផ្សព្វផ្សាយទិន្នន័យក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវបានប្រកាសឲ្យប្រើនៅឆ្នាំ២០០៥។ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការទទួលខុសត្រូវក្នុងកិច្ចការទាំងនេះ។ កន្លងមកប្រព័ន្ធទិន្នន័យកម្ពុជា CAMInfo ជាមូលដ្ឋានទិន្នន័យសូចនាករជាតិស្តីពីសេដ្ឋកិច្ច សង្គមកិច្ច សម្រាប់ការតាមដានភាពរីកចម្រើនធៀបនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាក៏ដូចជាគោលដៅផ្សេងៗទៀតរបស់ជាតិ គោលដៅប្រចាំតំបន់និងពិភពលោក រួមទាំងពិភពលោកសមស្របសម្រាប់កុមារ។ CAMInfo រួមមានទិន្នន័យថ្នាក់ជាតិនិងថ្នាក់រាជធានី ខេត្ត រហូតដល់ឃុំ សង្កាត់ ដែលអាចធ្វើឲ្យមានការតាមដានពីសូចនាករនានានៅថ្នាក់មូលដ្ឋាន។ ទិន្នន័យចម្បងៗដែលបានពីការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ទិន្នន័យដែលបានពីការឃ្លាំមើលជាប្រចាំ ទិន្នន័យរដ្ឋបាលនិងមូលដ្ឋាន ទិន្នន័យឃុំ សង្កាត់ ក៏ត្រូវបានដាក់បញ្ចូលទៅក្នុងCAMInfoផងដែរ និងបានធ្វើបច្ចុប្បន្នកម្ម០២ដងក្នុងមួយឆ្នាំ។ CAMInfo ត្រូវបានប្រើប្រាស់សម្រាប់ធ្វើបច្ចុប្បន្នកម្មនូវរបាយការណ៍ស្តីពីការអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ឆ្នាំ២០០៥ និងសម្រាប់ធ្វើរបាយការណ៍ទៀងទាត់របស់រាជរដ្ឋាភិបាលដើម្បីផ្ញើជូនគណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ។ នៅឆ្នាំ២០០២ ក្រសួងផែនការបានរៀបចំមូលដ្ឋានទិន្នន័យជាតិឃុំ សង្កាត់។ ទិន្នន័យនេះត្រូវបានពិនិត្យឡើងវិញនៅក្នុងឆ្នាំ២០០៤-២០០៥ ដើម្បីកែលំអគុណភាពទិន្នន័យនិងកែសម្រួលសូចនាករដែលមានស្រាប់ ក៏ដូចជាដាក់បន្ថែមសូចនាករស្តីពីសុខភាព ការអប់រំ កិច្ចការពារទឹក និងអនាម័យផងដែរ។ មូលដ្ឋានទិន្នន័យជាតិ ឃុំ សង្កាត់

ត្រូវបានប្រមូលរៀងរាល់ឆ្នាំពីសៀវភៅទិន្នន័យតាមភូមិ ឃុំ សង្កាត់ និងត្រូវបានប្រើប្រាស់ជាឧបករណ៍សម្រាប់កសាងផែនការវិនិយោគឃុំ សង្កាត់។

៦- នៅឆ្នាំ១៩៩៩ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានបង្កើតប្រព័ន្ធទិន្នន័យ ដើម្បីប្រមូលផ្តុំព័ត៌មានទាក់ទងនឹងស្ត្រីនិងកុមាររងគ្រោះនិងងាយរងគ្រោះដោយសារចំណាកស្រុក និងការជួញដូរ។ ក្នុងឆ្នាំ២០០៧ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានបង្កើតប្រព័ន្ធមូលដ្ឋានទិន្នន័យអំពីការថែទាំជំនួស ចំពោះកុមារ ដើម្បីប្រមូលទិន្នន័យទៀងទាត់អំពីកុមាររស់នៅក្រោមការថែទាំក្នុងមណ្ឌល។ ស្ថិតិឆ្នាំ២០១០បានបង្ហាញថាកុមារសរុបចំនួន១១ ៩៣៩នាក់ កំពុងរស់នៅក្រោមការថែទាំរយៈពេលវែងនៅក្នុងមជ្ឈមណ្ឌលសរុបចំនួន២៦៩ ក្នុងនោះមានមជ្ឈមណ្ឌលរដ្ឋចំនួន២១ និងមជ្ឈមណ្ឌលរបស់អង្គការមិនមែនរដ្ឋាភិបាលចំនួន២៤៨។

៧- នៅឆ្នាំ២០០៤ មូលដ្ឋានទិន្នន័យជាតិអំពីបទល្មើសព្រហ្មទណ្ឌខាងផ្លូវភេទត្រូវបានបង្កើតឡើងនៅក្រសួងមហាផ្ទៃដើម្បីប្រមូលផ្តុំព័ត៌មានអំពីការរំលោភផ្លូវភេទ ការកេងប្រវ័ញ្ច និងករណីជួញដូរ ហើយផ្តល់ព័ត៌មានលម្អិតអំពីករណីរបស់ជនរងគ្រោះនិងជនសង្ស័យ ដែលអាចប្រើប្រាស់ជាឧបករណ៍គ្រប់គ្រងករណីនៃបទល្មើស។ ក្រោយមកទៀត ទិន្នន័យដាក់បញ្ចូលនូវអំពើហិង្សាក្នុងគ្រួសារទៅក្នុងប្រព័ន្ធទិន្នន័យនេះថែមទៀត។ ក្រសួងមហាផ្ទៃផ្តល់សេវាទូរសព្ទអចិន្ត្រៃយ៍នៅក្នុងរាជធានី ខេត្តចំនួន០៧។ ប្រព័ន្ធទិន្នន័យទាក់ទងនឹងបទល្មើសជួញដូរនិងការកេងប្រវ័ញ្ចផ្លូវភេទ ត្រូវបានកែសម្រួលសម្របទៅតាមច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ។

៨- នៅឆ្នាំ២០០៦ ក្រសួងយុត្តិធម៌បានបង្កើតប្រព័ន្ធប្រមូលទិន្នន័យនិងប្រព័ន្ធត្រួតពិនិត្យយុត្តិធម៌អនីតិជន រួមទាំងទិន្នន័យតាមប្រព័ន្ធកុំព្យូទ័រ ដើម្បីត្រួតពិនិត្យលើដំណើរការរឿងក្តីរបស់កុមារប្រព្រឹត្តល្មើសច្បាប់ និងកុមាររងគ្រោះនៅតាមស្ថាប័នផ្សេងៗនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ ក្រសួងយុត្តិធម៌បានអនុវត្តគម្រោងសាកល្បងក្នុងការប្រមូលទិន្នន័យនិងប្រព័ន្ធទិន្នន័យស្តីពីយុត្តិធម៌កុមារនៅក្នុងរាជធានី ខេត្តចំនួន០៦ ហើយកំពុងត្រួតពិនិត្យឡើងវិញដើម្បីឲ្យស្របនឹងការចុះបញ្ជីថ្មីនៅតុលាការសាកល្បង។ ប្រព័ន្ធនេះនឹងភ្ជាប់គ្នាជាមួយនឹងប្រព័ន្ធទិន្នន័យរបស់ស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌផ្សេងៗទៀត។

**ប្រព័ន្ធទិន្នន័យសំខាន់ៗរួមមាន៖**

| ឈ្មោះប្រព័ន្ធទិន្នន័យ | ក្រសួង ស្ថាប័ន ទទួលខុសត្រូវ | ប្រភេទទិន្នន័យ |
|---|---|---|
| ប្រព័ន្ធទិន្នន័យកម្ពុជា CAMInfo | ក្រសួងផែនការ | សេដ្ឋកិច្ចនិងសង្គមកិច្ច |
| ប្រព័ន្ធទិន្នន័យស្តីពីការបញ្ជូនត្រឡប់មកវិញនូវស្ត្រីនិងកុមាររងគ្រោះ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ស្ត្រីនិងកុមាររងគ្រោះពីការជួញដូរឆ្លងដែន |
| ប្រព័ន្ធទិន្នន័យស្តីពីបទល្មើសផ្លូវភេទ ការជួញដូរមនុស្សនិងអំពើហិង្សាក្នុងគ្រួសារ | ក្រសួងមហាផ្ទៃ | ការរាយការណ៍ទៅនគរបាល ការចាប់ខ្លួន ការជួយសង្គ្រោះ ការបញ្ជូន |

| | | |
|---|---|---|
| | | សេវាកម្មសង្គមកិច្ច សេចក្តីលម្អិតអំពីជនរងគ្រោះនិងជនសង្ស័យនៃការរំលោភបំពាន ការកេងប្រវ័ញ្ចផ្លូវភេទ ការជួញដូរ និងអំពើហិង្សាក្នុងគ្រួសារ |
| ប្រព័ន្ធទិន្នន័យស្តីពីយុត្តិធម៌កុមារ | ក្រសួងយុត្តិធម៌ | សូចនាករស្តីពីកុមាររងគ្រោះពីបទល្មើសផ្លូវភេទនិងកុមារល្មើសច្បាប់នៅដំណាក់កាលស៊ើបអង្កេតនិងជំនុំជម្រះ |

ក្រៅពីការប្រមូលទិន្នន័យតាមរយៈប្រព័ន្ធខាងលើក្នុងឆ្នាំ២០០៩ ក្រុមការងារចម្រុះមកពីក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ និងកងរាជអាវុធហត្ថលើផ្ទៃប្រទេសបានចុះទៅត្រួតពិនិត្យនិងស្រង់ទិន្នន័យរឿងក្តីព្រហ្មទណ្ឌគ្រប់រាជធានី ខេត្តទាំង២៤។

៩- ជាទូទៅ ការប្រមូលទិន្នន័យទាក់ទងនឹងបទល្មើសជួញដូរមនុស្សនិងការកេងប្រវ័ញ្ចផ្លូវភេទ ក្រសួងស្ថាប័ននានា អនុវត្តទៅតាមនីតិវិធី ដូចខាងក្រោម៖

- អង្គភាពជំនាញរៀបចំចុះបញ្ជីព័ត៌មាននៅរាជធានី ខេត្ត
- ការបំពេញទម្រង់លម្អិតដោយដៃឬដោយប្រើកុំព្យូទ័រ ដែលរួមមានលេខសម្ងាត់ អត្តសញ្ញាណជនរងគ្រោះ អត្តសញ្ញាណជនល្មើស ប្រភេទបទល្មើស ចំណាត់ការដែលបានអនុវត្ត ប្រភេទសេចក្តីសម្រេច
- ថ្នាក់រាជធានី ខេត្ត ចម្លងព័ត៌មាននិងទិន្នន័យហើយផ្ញើរបាយការណ៍នោះទៅក្រសួង
- ករណីខ្លះ មន្ត្រីថ្នាក់ក្រសួងចុះទៅប្រមូលព័ត៌មាននិងទិន្នន័យនៅរាជធានី ខេត្ត
- ទិន្នន័យត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធទិន្នន័យនៅថ្នាក់ក្រសួង។

១០- បទល្មើសផ្លូវភេទក្នុងឆ្នាំ២០០៩ជាបទល្មើសដែលមានចំនួនច្រើនដោយប្រៀបធៀបនឹងបទល្មើសផ្សេងទៀត។ បទល្មើសប្រភេទនេះមានច្រើនជាង៦៤ភាគរយ អំពើហិង្សាក្នុងគ្រួសារមាន២០ភាគរយ ការកេងប្រវ័ញ្ចផ្លូវភេទនិងរូបភាពអាសអាភាសមាន១១ភាគរយ និងការជួញដូរមនុស្សមាន៥ភាគរយនៃបទល្មើសដែលនាយកដ្ឋានប្រឆាំងការជួញដូរនិងការពារអនីតិជនបានស៊ើបអង្កេត។ រហូតមកដល់ពេលនេះ មិនមានការអង្កេតថ្នាក់ជាតិនិងប្រព័ន្ធទិន្នន័យដែលអាចកំណត់ឲ្យបានច្បាស់លាស់ពីចំនួននិងឧបទ្ទវហេតុនៃការជួញដូរកុមារ សម្រាប់គោលបំណងជាក់លាក់ទាក់ទងនឹងការផ្ទេរកុមារដើម្បីកេងប្រវ័ញ្ចផ្លូវភេទ ការផ្ទេរសរីរាង្គកុមារដើម្បីផលកម្រៃ និងការបង្ខិតបង្ខំកុមារឲ្យធ្វើពលកម្ម និងមិនមានទិន្នន័យច្បាស់លាស់អំពីកុមារដែលត្រូវបានសុំយកទៅចិញ្ចឹមតាមរយៈអន្តរការីដោយផ្ទុយនឹងបទប្បញ្ញត្តិមាត្រា២១នៃអនុសញ្ញាស្តីពីសិទ្ធិកុមារនិងអនុសញ្ញាក្រុងឡាអេស្តីពីកិច្ចការ

ពារកុមារ និងកិច្ចសហប្រតិបត្តិការពាក់ព័ន្ធនឹងស្នុំកូនអន្តរប្រទេសឡើយ។ ដោយសារចរិតបទល្មើស និងកត្តាចិត្តសាស្ត្រសង្គមរបស់ជនរងគ្រោះនិងគ្រួសារជនរងគ្រោះ មានបទល្មើសជួញដូរតិចតួចត្រូវបានរាយការណ៍ ទៅអាជ្ញាធរមានសមត្ថកិច្ច[១]។

ពីឆ្នាំ២០០៥ដល់ឆ្នាំ២០០៩ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជនសម្រេចបាននូវសមិទ្ធផល ដូចខាងក្រោម៖

| | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ |
|---|---|---|---|---|---|
| ១- ចំនួនករណីសរុបដែលត្រូវបានរាយការណ៍និងអះអាងថាមានបទល្មើសពាក់ព័ន្ធ រួមទាំងតាមរយៈទូរសព្ទពិសេស | ៦៦៥ | ៩៦៧ | ៥៧៦ | ៦១៤ | ៦៤០ |
| ២- ចំនួនករណីត្រូវបានស៊ើបអង្កេត | ៦១២ | ៨៩៦ | | | ៦៣៥ |
| ៣- ចំនួនករណីសរុបដែលត្រូវបានបញ្ជូនទៅតុលាការ | ៣៩៨ | ៦១៤ | ៥២៩ | ៤៣៨ | ៥៩៤ (ជនជាប់សង្ស័យ៥៣៥នាក់ ត្រូវបានបញ្ជូនទៅតុលាការ) |
| ៤- ចំនួនជនល្មើសដែលត្រូវបានចាប់ខ្លួន | ៤៣១ | ៦៧០ | ៥៨២ | ៤៩៦ | ៥៩៥ (ចំណោមជនជាប់សង្ស័យសរុប ៧២៣នាក់) (ជនជាប់សង្ស័យ៨ភាគរយជាជនបរទេស) |

ចំនួនជនរងគ្រោះដែលត្រូវបានសង្គ្រោះនិងជួយដោយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជនពីឆ្នាំ២០០៥ដល់ឆ្នាំ២០០៩៖

| | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ |
|---|---|---|---|---|---|
| ១- ចំនួនជនរងគ្រោះ ត្រូវបានសង្គ្រោះ | | | | | |
| - អាយុក្រោម១៥ឆ្នាំ | ២០២ | ២៤១ | ១៩៨ | ១៥៥ | ១៩៨ |
| - អាយុពី១៥ទៅ១៧ឆ្នាំ | ១០១ | ២១៣ | ៧៦ | ១១៩ | ១២៦ |
| - អាយុចាប់ពី១៨ឆ្នាំឡើង | ៣១២ | ៣៣០ | ៤៩៧ | ៦៧៣ | ៤៦៧ |
| - សរុប | ៦១៥ | ៧៨៤ | ៧៧១ | ៩៤៧ | ៧៩១ |
| ២- បានបញ្ជូនជនរងគ្រោះ | | | | | |
| - បញ្ជូនទៅក្រសួងស.អ.យ. | ៩១ | ១១៩ | ១៣០ | ៣១៧ | ៧៤ |
| - បញ្ជូនទៅអង្គការមិនមែនរដ្ឋាភិបាល | ២២២ | ១៧៧ | ៥៨ | ៨៨ | ៥៧ |
| - ប្រគល់ជូនគ្រួសារ | ៣០២ | ៤៨៨ | ៥៨៣ | ៥៤៣ | ៦៦៩ |
| - សរុប | **៦១៥** | **៧៨៤** | **៧៧១** | **៩៤៨** | **៨០០** |

[១] ប្រភពពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន

ក្នុងចន្លោះខែតុលា ឆ្នាំ២០០៩ ដល់ខែតុលា ឆ្នាំ២០១០ អគ្គស្នងការដ្ឋាននគរបាលជាតិនិងកងរាជអាវុធហត្ថលើផ្ទៃប្រទេសសម្រេចបាននូវសមិទ្ធផល ដូចខាងក្រោម៖

| ប្រភេទបទល្មើស | ចំនួនករណីបង្ក្រាប | ចំនួនជនរងគ្រោះ | ចំនួនជនល្មើស |
|---|---|---|---|
| ការនាំយកអនីតិជនចេញដោយមិនស្របច្បាប់ | ៦ | ៥ | ៧ |
| ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ៦ | ២២ | ១០ |
| ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ២៤ | ១៩៥ | ៣៤ |
| ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច | ០ | ០ | ០ |
| អំពើលក់ដូរមនុស្ស | ៥ | ៤ | ៩ |
| អំពើលក់ដូរមនុស្សដោយមានគោលដៅ | ៣ | ៤ | ៦ |
| អំពើលក់ដូរមនុស្សសម្រាប់នាំឆ្លងដែន | ២ | ២ | ២ |
| ការដឹកជញ្ជូនដោយមានគោលដៅ | ០ | ០ | ០ |
| អំពើនាំឆ្លងដែន | ៣ | ២០ | ៣ |
| ការចាប់ពង្រត់ ការឃុំឃាំង ការបង្ខាំង | ៣ | ៦៤ | ៤ |
| ការទិញពេស្យាចារកុមារ | ១៥ | ៤៣ | ២២ |
| អំពើអូសទាញពេស្យាចារកុមារ | ៣ | ៥ | ៩ |
| សញ្ចារកម្ម | ១៩ | ១២១ | ៣៤ |
| សញ្ចារកម្ម(អនីតិជន) | ២ | ៦ | ៦ |
| សញ្ចារកម្ម(ស្ពានទម្ងន់) | ៨ | ៣២ | ៩ |
| សញ្ចារកម្មទាក់ទងនឹងពេស្យាចារកុមារ | ៦ | ៥៥ | ៩ |
| ការផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ | ១៥ | ១១១ | ២០ |
| រូបភាពនិងសម្ភារៈអាសអាភាស | ៦ | ៤៤ | ១៨ |
| រូបភាពនិងសម្ភារៈអាសអាភាសនៃកុមារ | ២ | ១ | ២ |
| អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ២៦ | ២៥ | ២៧ |
| អំពើអាសប្រធាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ៧ | ៩ | ១០ |
| សរុប | ១៦១ | ៧៦៨ | ២៤១ |

*ប្រភពពីគណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ(ប.ជ.រ.ព.ភ.)*

ជនរងគ្រោះត្រូវបានបញ្ជូនទៅ៖

- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ចំនួន៣៥១នាក់
- អង្គការមិនមែនរដ្ឋាភិបាល ចំនួន១៣នាក់ និង
- គ្រួសារឬអ្នកអាណាព្យាបាល ចំនួន៤០៤នាក់។

ក្នុងឆ្នាំ២០០៩ សាលាដំបូងរាជធានី ខេត្ត បានកាត់ក្តីឲ្យជនល្មើសចំនួន១១២នាក់ជាប់ពន្ធនាគារ។ ក្នុងឆ្នាំ២០១០ សាលាដំបូងរាជធានី ខេត្ត បានចាត់វិធានការលើករណីជួញដូរមនុស្សនិងអំពើ

កេងប្រវ័ញ្ចផ្លូវភេទចំនួន៨៧ករណី ក្នុងនោះមានជនជាប់សង្ស័យចំនួន១២២នាក់។ ក្នុងចំណោមរឿងក្តីទាំងនេះ រឿងក្តីចំនួន៥៥ ត្រូវបានជំនុំជម្រះ ក្នុងនោះជនល្មើសចំនួន៧៦នាក់ត្រូវបានផ្តន្ទាទោសៈ

| ប្រភេទបទល្មើស | ចំនួនករណី | ចំនួនជនល្មើស |
|---|---|---|
| ការនាំយកអនីតិជនចេញដោយមិនស្របច្បាប់ | ៣ | ៣ |
| ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ៤ | ៥ |
| អំពើលក់ដូរមនុស្ស | ៣ | ៣ |
| អំពើលក់ដូរមនុស្សដោយមានគោលដៅ | ២ | ៧ |
| ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច | ១ | ១ |
| សញ្ជារកម្ម | ១៣ | ២០ |
| សញ្ជារកម្ម(អនីតិជន) | ៤ | ៨ |
| សញ្ជារកម្ម(ស្ថានទម្ងន់) | ២ | ២ |
| ការផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ | ២ | ២ |
| រូបភាពនិងសម្ភារៈអាសអាភាស | ១ | ២ |
| ការទិញពេស្យាចារកុមារ | ១០ | ១៣ |
| អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ៥ | ៥ |
| អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ៥ | ៥ |
| សរុប | ៥៥ | ៧៦ |

*(ប្រភពពីគណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ)*

ប្រភេទនៃការកេងប្រវ័ញ្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា រួមមានការកេងប្រវ័ញ្ចពលកម្មនិងការកេងប្រវ័ញ្ចផ្លូវភេទ។

១១- មិនមានចំនួនជាក់លាក់នៃជនអាយុក្រោម១៨ឆ្នាំ ដែលចូលរួមក្នុងសកម្មភាពពេស្យាចារនៅព្រះរាជាណាចក្រកម្ពុជាទេដោយសារចរិតលាក់បាំងនៃអំពើពេស្យាចារ។

១២- ព្រះរាជាណាចក្រកម្ពុជាបានបង្កើតច្បាប់យ៉ាងតឹងរ៉ឹងអំពីបញ្ហារូបភាពអាសអាភាស ប៉ុន្តែសកម្មភាពលួចលាក់និងអាជីវកម្មអំពីអំពើនេះនៅតែកើតមាន។ បទល្មើសដែលពាក់ព័ន្ធនឹងការធ្វើពាណិជ្ជកម្មក្នុងការសម្តែង ការលក់ ការជួលវីដេអូដែលមិនមានទិដ្ឋាការដោយរំលោភទៅលើកម្មសិទ្ធិបញ្ញា និងការបង្ហាញពីវីដេអូអាសអាភាសជាដើម ត្រូវបានឆ្លើយតបយ៉ាងមានប្រសិទ្ធភាពតាមរយៈយុទ្ធនាការចុះបង្ក្រាប។ ប៉ុន្តែរូបភាពនិងសម្ភារៈអាសអាភាសមួយចំនួន ត្រូវបានជនខិលខូចបង្ហោះនៅតាមគេហទំព័រ ថតចម្លងទៅក្នុងឧបករណ៍អេឡិចត្រូនិក ទូរសព្ទដៃ និងរក្សាទុកនៅក្នុងវីស៊ីឌី។ ភិនភាគរូបភាពអាសអាភាសនៃជនដែលមានអាយុក្រោម១៨ឆ្នាំ ជាទូទៅ ស្តែងឡើងតាមរូបភាពពិតដែលរូបភាពទាំងនោះយើងមិនដឹងពីប្រភពឡើយ។ ការសម្តែងអំពើអាសអាភាសដោយផ្ទាល់ត្រូវបានច្បាប់ហាមឃាត់និងត្រូវបានបង្ក្រាបទាំងស្រុងតាំងពីឆ្នាំ២០០៧។ គិតមកដល់ឆ្នាំ២០០៨ មានចំនួន២ ៦១៨ករណីដែលអ្នកលក់ត្រូវបានណែនាំនិងចុះកិច្ចសន្យាឈប់ប្រកបរបរខុសច្បាប់ទៀត ហើយមាន

ហាងវីដេអូខុសច្បាប់ចំនួន១០២ត្រូវបានបិទអាជីវកម្ម។ ក្នុងករណីមួយចំនួនត្រូវបញ្ជូនសំណុំរឿងទៅតុលាការតាមនីតិវិធីច្បាប់។ គណៈកម្មាធិការអន្តរក្រសួងនៅតាមរាជធានី ខេត្ត បានបើកប្រតិបត្តិការចុះបង្ក្រាបនិងដកហូត ដុតបំផ្លាញបានវីស៊ីឌីនិងឌីវីឌីដែលហាមឃាត់ចំនួន៩៧ ៥៤៩បន្ទះ រួមទាំងកាសែតវីដេអូនិងសម្ភារៈលួចចម្លងដែលជនដែដល់ប្រើសម្រាប់ផលិតនិងផ្សព្វផ្សាយរូបភាពនិងសម្ភារៈអាសអាភាស ដែលក្នុងនោះដកហូតបាននូវវីស៊ីឌីនិងឌីវីឌីជាច្រើនសែនបន្ទះ។ គណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ រាជធានី ខេត្តបានផ្សព្វផ្សាយ តាមរយៈវិទ្យុ ទូរទស្សន៍ ភាពយន្ត ប៉ាណូ បដា និងផ្សព្វផ្សាយដល់ម្ចាស់អាជីវកម្ម ម៉ាស្សា ខារ៉ាអូខេ ផ្ទះសំណាក់ និងសណ្ឋាគារ ឲ្យរាយការណ៍និងបានធ្វើការទប់ស្កាត់ជាមួយអាជ្ញាធរមានសមត្ថកិច្ច ក្នុងករណីមានការសង្ស័យពីការធ្វើសកម្មភាពទាក់ទងនឹងពេស្យាចារកុមារនិងរូបភាពអាសអាភាស សមត្ថកិច្ចបានចុះធ្វើការត្រួតពិនិត្យជាបន្ទាន់។

១៣- ព្រះរាជាណាចក្រកម្ពុជាបានបង្កើតនិងកំពុងប្រឹងប្រែងដើម្បីដំណើរការប្រព័ន្ធទិន្នន័យ ពាក់ព័ន្ធនឹងចំនួននៃការចោទប្រកាន់និងការផ្តន្ទាទោសចំពោះបទល្មើសខាងលើ ដោយបំបែកទិន្នន័យទាំងនោះទៅតាមចរិតនៃបទល្មើសផ្លូវភេទដែលមានចែងក្នុងក្រមព្រហ្មទណ្ឌនិងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ក៏ប៉ុន្តែការងារនេះទាមទារពេលវេលា ធនធានមនុស្ស និងថវិកាបន្ថែមច្រើនទៀតដើម្បីសម្រេចទៅបាននិងរក្សាបាននូវនិរន្តរភាព។

## វិធានការទូទៅនៃការអនុវត្ត

១៤- ព្រះរាជាណាចក្រកម្ពុជាបានអនុម័តច្បាប់ លិខិតបទដ្ឋានគតិយុត្ត យុទ្ធសាស្ត្រ គោលនយោបាយ ផែនការជាតិ៥ឆ្នាំប្រឆាំងការជួញដូរនិងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ មានដូចខាងក្រោម៖

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមាត្រា៣១ ចែងថា "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយដែលទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ"។ មាត្រា៤៨ ចែងថា "រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ជាពិសេសសិទ្ធិរស់រានមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាមនិងការការពារប្រឆាំងនឹងអាជីវកម្ម សេដ្ឋកិច្ច ឬកាមគុណលើកុមារ"។
- ក្រុមប្រឹក្សាធម្មនុញ្ញបានចេញសេចក្តីសម្រេចលេខ០៩២/០០៣/២០០៧ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ ដោយកំណត់ថា ច្បាប់អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាបានទទួលស្គាល់រួចមកហើយ ជាពិសេសអនុសញ្ញាស្តីពីសិទ្ធិកុមាររួមបញ្ចូលជាផ្នែកមួយនៃច្បាប់ជាតិ រួមទាំងច្បាប់ជាតិផងដែរ ដែលចៅក្រមត្រូវផ្អែកលើ ក្នុងការជំនុំជម្រះក្តី។
- ព្រះរាជក្រមលេខ នស/រកម/០១១០/០០១ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១០ ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ។

- ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០២០៨/០០៥ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ក្នុងគោលបំណងបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ដើម្បីការពារសិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់មនុស្ស និងបង្កើននូវសុខភាពនិងសុខុមាលភាពរបស់ប្រជាពលរដ្ឋនិងរក្សាការពារលើកកម្ពស់នូវទំនៀមទម្លាប់ប្រពៃណីដ៏ល្អរបស់ជាតិ និងអនុវត្តឲ្យបានសមស្របតាមពិធីសារអង្គការសហប្រជាជាតិឬកិច្ចព្រមព្រៀងអន្តរជាតិផ្សេងៗទៀតទាក់ទងនឹងការជួញដូរមនុស្សនៅព្រះរាជាណាចក្រកម្ពុជា។ ដើម្បីពង្រឹងការអនុវត្តច្បាប់ក្រសួងយុត្តិធម៌បានចេញសេចក្តីណែនាំលេខ៩៧៨ព្រ.ទ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍បង្ក្រាបអំពើល្មើសច្បាប់មួយចំនួននិងសេចក្តីណែនាំលេខ៧០០ កយព្រ.ទ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៥ ស្តីពីការចោទប្រកាន់និងការផ្តន្ទាទោសជនប្រព្រឹត្តបទល្មើសជួញដូរមនុស្សនិងធ្វើអាជីវកម្មផ្លូវភេទ។
- ក្រមនីតិវិធីព្រហ្មទណ្ឌប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មានគោលបំណងកំណត់អំពីវិធានទាំងឡាយដែលត្រូវគោរពនិងប្រព្រឹត្តតាមដោយហ្មត់ចត់ដើម្បីកំណត់ឲ្យច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយ។ បទប្បញ្ញត្តិនៃក្រមនេះត្រូវយកទៅអនុវត្តចំពោះរឿងព្រហ្មទណ្ឌ កាលណាពុំមានវិធានដោយឡែកចែងដោយច្បាប់ពិសេសទេនោះ។
- ក្រមព្រហ្មទណ្ឌដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ មានគោលបំណងកំណត់បទល្មើសចង្អុលបង្ហាញបុគ្គលដែលអាចត្រូវបានប្រកាសថាជាអ្នកទទួលខុសត្រូវចំពោះបទល្មើសនិងកំណត់ទោសព្រមទាំងបែបបទនៃការកំណត់ទោស។
- ច្បាប់ស្តីពីទេសចរណ៍ត្រូវបានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ មានគោលដៅកំណត់វិធាននិងយន្តការសម្រាប់គ្រប់គ្រងនិងអភិវឌ្ឍវិស័យទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា។
- ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១០០៥/០៣១ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ ចែងឲ្យមានយន្តការតាមផ្លូវច្បាប់ក្នុងការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ និងស្របតាមអនុសញ្ញាស្តីពីការលុបបំបាត់នូវរាល់អំពើបំពារបំពានក្នុងគ្រួសារដល់ស្ត្រី។
- ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១២០៩/០២៤ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៩ មានគោលដៅកំណត់ពីគោលការណ៍ លក្ខខណ្ឌ នីតិវិធី ទម្រង់បែបបទ និងអានុភាពនៃសុំកូនអន្តរប្រទេស។
- ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៧/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៧ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី០៩

ខែឧសភា ឆ្នាំ២០០៥។

- រាជរដ្ឋាភិបាលបានចេញ៖

ក. គោលការណ៍ណែនាំលេខ០០១ សណន បជរពភ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ស្តីពីការអនុវត្តច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ដើម្បីធានាអនុវត្តច្បាប់នេះឲ្យមានប្រសិទ្ធភាព តម្លាភាព និងយុត្តិធម៌។

ខ. អនុក្រឹត្យលេខ៦៣ អនក្រ.បក ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការគ្រប់គ្រងត្រួតពិនិត្យសិល្បៈ ភាពយន្ត និងវីដេអូ ដែលកំណត់ពីការដាក់ពិន័យដល់ជនដែលបញ្ចាំង កាត់ត ដំឡើងរូបភាព ថតចម្លង បញ្ចូលសំឡេង ជួល លក់និងចែកចាយវីដេអូអាសអាភាស និងការដាក់ពិន័យដល់ចារី និងសហចារីដែលផលិតវីដេអូអាសអាភាស។

គ. សេចក្តីសម្រេចលេខ១០ សសរ ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០០១ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងបង្ក្រាបបទល្មើសភាពយន្តនិងវីដេអូក្នុងព្រះរាជាណាចក្រកម្ពុជា។

ឃ. សេចក្តីសម្រេចលេខ៥៧សសរ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមការងារចម្រុះពិនិត្យចំណាត់ការរឿងក្តីព្រហ្មទណ្ឌនៅតាមអង្គភាពអនុវត្តច្បាប់នានា។

ក្រៅពីនេះរាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ១៨៣អនក្រ.បក ចុះថ្ងៃ០៣ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកំណត់បែបបទនិងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរនិងជនបរទេស និងសេចក្តីណែនាំលេខ០១ សណន ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៩ ស្តីពីការអនុវត្តអនុក្រឹត្យនេះ។ ដោយឡែកក្រសួងមហាផ្ទៃបានចេញសេចក្តីសម្រេចលេខ២៧២៩សសរ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមការងារចម្រុះច្រកចេញចូលតែមួយសម្រាប់ពិនិត្យចុះបញ្ជីការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរនិងជនបរទេស។

- ដើម្បីធានានូវកិច្ចសហប្រតិបត្តិការល្អរវាងស្ថាប័នរដ្ឋនិងបណ្តាទីភ្នាក់ងារគាំទ្រជនរងគ្រោះ ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងយុត្តិធម៌ ក្រសួងកិច្ចការនារី ក្រសួងសុខាភិបាល និងទីភ្នាក់ងារគាំទ្រជនរងគ្រោះចំនួន២៤ បានចុះកិច្ចព្រមព្រៀងថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីគោលការណ៍ណែនាំអនុវត្តនិងកិច្ចសហការរវាងស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ និងបណ្តាទីភ្នាក់ងារគាំទ្រជនរងគ្រោះក្នុងដំណើររឿងក្តីជួញដូរមនុស្ស។
- ក្រសួងយុត្តិធម៌បានចេញសេចក្តីណែនាំចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៥ អំពីការអនុវត្តគោលការណ៍នានាក្នុងច្បាប់ជាតិនិងអន្តរជាតិ ដែលកំពុងនៅមានជាធរមានទាក់ទងនឹងការការពារជនរងគ្រោះ។ សេចក្តីណែនាំនេះ បានចង្អុលបង្ហាញនូវបទប្បញ្ញត្តិជាច្រើនដែលបានកំណត់នៅក្នុងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ ច្បាប់អន្តរជាតិនានាទាក់ទងនឹងយុត្តិធម៌អនីតិជននិងកិច្ចការពារជនរងគ្រោះដោយសារបទល្មើសព្រហ្មទណ្ឌ។
- សេចក្តីណែនាំលេខ០១ កយសណន/០៩ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៩ របស់ក្រសួងយុត្តិធម៌ ស្តីពីការអនុវត្តមាត្រា៤២ " អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ " និងមាត្រា៤៣ " អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំនៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើ

អាជីវកម្មផ្លូវភេទ"។

- ប្រកាសលេខ១៧៩ ប.ទ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីអាជ្ញាបណ្ណបើកអាជីវកម្មសាលបម្រើអ៊ិនធឺណិត។
- ប្រកាសលេខ៦២ កយប្រក/០៨ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៨ ស្តីពីការប្រើប្រាស់របាំងក្នុងបន្ទប់សវនាការនិងបន្ទប់សវនាការភ្ជាប់បណ្តាញទូរទស្សន៍ ដើម្បីយកសក្ខីកម្មពីកុមារ ឬជនរងគ្រោះ ឬសាក្សីដែលងាយរងគ្រោះ។
- សារាចរណែនាំលេខ០០៩ ស.អ.យ. ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពីការងារសមាហរណកម្ម និងតាមដានក្រុមជនរងគ្រោះដែលបានស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋនិងអង្គការមិនមែនរដ្ឋាភិបាល។
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈមាននាយកដ្ឋានការងារកុមារ បានបង្កើតផែនការសកម្មភាពជាតិស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារឆ្នាំ២០០៨-២០១២ ដោយមានគោលដៅបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ។

១៥- កិច្ចការពារសង្គមជាសមាសភាគមួយនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ របស់រាជរដ្ឋាភិបាលកម្ពុជា។ គោលនយោបាយមួយចំនួនត្រូវបានដាក់ចេញដើម្បីផ្តល់នូវការការពារដល់កុមារងាយរងគ្រោះដូចជាផែនការជាតិ៥ឆ្នាំប្រឆាំងការជួញដូរនិងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ គោលនយោបាយ និងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងគោលនយោបាយជាតិស្តីពីការថែទាំជំនួសចំពោះកុមារ។ ផែនការជាតិ៥ឆ្នាំ លើកទី១ត្រូវបានប្រកាសឲ្យប្រើដោយសេចក្តីប្រកាសលេខ០១ សប្រក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០០ ស្តីពីវិធានការចាត់តាំងអនុវត្ត ផែនការជាតិ៥ឆ្នាំ ប្រឆាំងការជួញដូរកុមារនិងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានចេញគោលនយោបាយនិងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្សលេខ០៦២ ស.អ.យ. ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩។ គោលនយោបាយនិងបទដ្ឋានអប្បបរមានេះ កំណត់អំពីទស្សនាទានទាក់ទងនឹងកិច្ចការពារគំរូ សម្រាប់កិច្ចការពារនិងគោលនយោបាយទូទៅស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស។
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានចេញគោលនយោបាយជាតិស្តីពីការថែទាំជំនួសចំពោះកុមារលេខ៩០៧ ស.អ.យ. ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៦។ គោលនយោបាយនេះមានចែងពីប្រភេទផ្សេងៗគ្នានៃការថែទាំជំនួសចំពោះកុមារដែលមិនបានទទួលការថែទាំដោយឪពុកម្តាយបង្កើត ហើយកំណត់គោលការណ៍នៃការថែទាំជំនួស។ ក្រសួងបានចេញប្រកាសលេខ ៨៥២ ស.អ.យ. ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ ស្តីពីការដាក់ឲ្យអនុវត្តគោលនយោបាយស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស។
- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានចេញសេចក្តីសម្រេចលេខ១០៧ ក.ជ.ក.ក. ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីគោលការណ៍ការពារសិទ្ធិកុមាររងគ្រោះ ដោយសារការជួញដូរ ដើម្បីជួយដល់

កុមាររងគ្រោះដោយសារការជួញដូរឲ្យទទួលបានសិទ្ធិជាមូលដ្ឋានរបស់ពួកគេ ទទួលបានសេវាសមស្រប ដែលធ្វើឲ្យពួកគេមានជីវិតរស់នៅប្រកបដោយភាពកក់ក្ដៅ ទទួលបានការអប់រំបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងធានាបាននូវនិរន្តរភាពក្នុងជីវភាពរស់នៅ ហើយរួចផុតពីការបៀតបៀននិងការប្រមាថមើលងាយ។

- រាជរដ្ឋាភិបាលកម្ពុជាបានកំណត់នូវគោលនយោបាយក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ ជាទេសចរណ៍វប្បធម៌និងធម្មជាតិ គ្មានការលើកទឹកចិត្តដល់ទេសចរណ៍ផ្លូវភេទ និងប្រឆាំងដាច់ខាតទេសចរណ៍ផ្លូវភេទលើកុមារ។ ក្រសួងទេសចរណ៍បានដាក់ចេញនូវផែនការ វិធានការ សារាចរណែនាំជាបន្តបន្ទាប់ ជាពិសេសច្បាប់ស្ដីពីទេសចរណ៍ ដើម្បីទប់ស្កាត់អំពើជួញដូរមនុស្សចាប់តាំងពីឆ្នាំ២០០១មក ក្រសួងបានបង្កើតគណៈកម្មាធិការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍និងបណ្ដាញរបស់ខ្លួននៅតាមរាជធានី ខេត្ត ទាំង២៤ ក្នុងគោលបំណងពង្រឹងប្រសិទ្ធភាពទប់ស្កាត់និងលុបបំបាត់អាជីវកម្មផ្លូវភេទនិងកេងប្រវ័ញ្ចលើកម្លាំងពលកម្មស្ត្រីនិងកុមារវ័យក្មេងក្នុងវិស័យទេសចរណ៍ដោយប្រកាន់យកវិធានការពីរជាចម្បង គឺវិធានការអប់រំនិងវិធានការរដ្ឋបាល និងបានផ្ដន្ទាទោសជនដែលប្រព្រឹត្តអំពើជួញដូរមនុស្សតាមរយៈវិស័យទេសចរណ៍។

១៦- រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតស្ថាប័ននិងយន្តការមួយចំនួន ដើម្បីអនុវត្តគោលនយោបាយនិងកម្មវិធីសកម្មភាពជាតិពាក់ព័ន្ធនឹងកិច្ចការពារកុមារព្រមទាំងពិធីសារនេះ។ ស្ថាប័នទាំងនោះរួមមាន៖

- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ គឺជាស្ថាប័នសម្របសម្រួលនិងផ្ដល់យោបល់ជូនរាជរដ្ឋាភិបាលលើការងារទាក់ទងនឹងការរស់រានមានជីវិត ការអភិវឌ្ឍ ការការពារ ការលើកកម្ពស់សុខុមាលភាព និងការចូលរួមចំណែករបស់កុមារសម្រាប់ការអនុវត្តផែនការសកម្មភាពដែលពាក់ព័ន្ធទៅនឹងការអនុវត្តអនុសញ្ញាស្ដីពីសិទ្ធិកុមារ។
- រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ១៦២ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៩ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងកិច្ចការប្រយុទ្ធប្រឆាំងការជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ ដោយមានលេខាធិការដ្ឋាននិងក្រុមការងារបច្ចេកទេសចម្រុះស្ថាប័ន០៦ជាជំនួយក្នុងការអនុវត្តផែនការសកម្មភាពជាតិនិងមានគណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារថ្នាក់រាជធានី ខេត្ត។
- រាជរដ្ឋាភិបាលបានចេញសេចក្ដីសម្រេចលេខ៧១ សសរ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្ដីពីការរៀបចំក្រុមការងារកម្ពុជាប្រឆាំងអំពើជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គហៅកាត់ថា ក្រុមការងារខមមីតកម្ពុជា(Cambodian COMMIT Task Force)។ ក្រុមការងារនេះមានគម្រោងអន្តរៈទីភ្នាក់ងារសហប្រជាជាតិប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សប្រចាំព្រះរាជាណាចក្រកម្ពុជា ជាលេខាធិការដ្ឋានជួយធ្វើការសម្របសម្រួលរាល់សកម្មភាពថ្នាក់ជាតិនិងថ្នាក់តំបន់ដែលពាក់ព័ន្ធនឹងបញ្ហាជួញដូរមនុស្សនិងទេសន្តរប្រវេសន៍ និងជាពិសេសសហការជាមួយ គណៈកម្មាធិការជាតិដឹកនាំការបង្ក្រាប

អំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ។

- ក្រសួងការពារជាតិបានបង្កើតការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនស្ថិតក្រោមបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេសដែលមានភារកិច្ចៈ
    - ត្រួតពិនិត្យបទល្មើសជួញដូរមនុស្ស អំពើអាជីវកម្មផ្លូវភេទ កំណត់និងចាប់ជនល្មើសព្រមទាំងប្រមូលភស្តុតាងកសាងសំណុំរឿងបញ្ជូនទៅតុលាការ
    - ទទួលបន្ទុកអនុវត្តរាល់ដីការបស់តុលាការពាក់ព័ន្ធបទល្មើសជួញដូរមនុស្ស
    - ទទួលបណ្តឹងពីគ្រប់មជ្ឈដ្ឋានអំពីបទល្មើសជួញដូរមនុស្ស និងចាត់ការតាមនីតិវិធីចំពោះបណ្តឹងនោះ
    - ក្តាប់លទ្ធផលប្រឆាំងការជួញដូរមនុស្សរបស់អង្គភាពរាជធានី ខេត្ត និងរាយការណ៍ជូនថ្នាក់លើ
    - សហការជាមួយការិយាល័យនិងអង្គភាពពាក់ព័ន្ធ ដើម្បីសម្រេចភារកិច្ចជំនាញ
    - សហការសម្របសម្រួលការអប់រំនិងស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស
    - ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានស្នងការប្រគល់ជូន។
- ក្រសួងមហាផ្ទៃបានបង្កើតនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៅឆ្នាំ២០០២ ដែលមានការិយាល័យនិងផ្នែកចំណុះនៅគ្រប់ស្នងការដ្ឋានរាជធានី ខេត្ត។ នាយកដ្ឋានជំនាញនេះមានភារកិច្ចបង្ក្រាបបទល្មើសនិងការពារជនរងគ្រោះដោយសារការជួញដូរនិងអាជីវកម្មផ្លូវភេទ។ នាយកដ្ឋានបានបង្កើតឲ្យមានទូរសព្ទពិសេសប្រចាំការ (Hot line) ២៤ម៉ោងលើ២៤ម៉ោង សម្រាប់ទទួលបណ្តឹងពីជនរងគ្រោះ។
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានបង្កើតការិយាល័យសមាហរណកម្មនិងប្រឆាំងការជួញដូរមនុស្សនៅឆ្នាំ២០០៦ ដែលមានភារកិច្ចកំណត់អត្តសញ្ញាណ ការពារ ស្វែងរក វាយតម្លៃ សមាហរណកម្មបញ្ជូន និងប្រព័ន្ធគាំទ្រសម្រាប់ជនរងគ្រោះដោយសារការជួញដូរ អាជីវកម្មនិងហិង្សា ការបំពារបំពានគ្រប់ទម្រង់ផ្សេងៗទៀត។ ក្រសួងក៏បានបង្កើតក្រុមការងារថ្នាក់ជាតិពហុវិស័យស្តីពីកុមារកំព្រានិងកុមារងាយរងគ្រោះ ដើម្បីពង្រឹងការអនុវត្តកម្រងសិទ្ធិទាំង០៤របស់កុមារកំព្រានិងកុមារងាយរងគ្រោះ ព្រមទាំងផ្តល់ការគាំទ្រផ្នែកបច្ចេកទេស កម្មវិធីរដ្ឋបាល និងទទួលខុសត្រូវផ្តល់ការគាំទ្រដល់ការបង្កើត ការអនុវត្ត និងការត្រួតពិនិត្យតាមដានផែនការសកម្មភាពជាតិសម្រាប់កុមារកំព្រា កុមារទទួលផលប៉ះពាល់ដោយមេរោគអេដស៍/ជំងឺអេដស៍និងកុមារងាយរងគ្រោះដទៃទៀត។
- ក្រសួងកិច្ចការនារីមានរចនាសម្ព័ន្ធជាច្រើនដើម្បីគាំទ្របញ្ហានានាដែលពាក់ព័ន្ធនឹងស្ត្រី រួមទាំងការបញ្ជ្រាបយេនឌ័រទៅក្នុងការអនុវត្តសិទ្ធិក្នុងការបំពេញការងារនិងអភិបាលកិច្ច ដោយបានយកចិត្តទុកដាក់ពង្រឹងសមត្ថភាពនារីនៅក្នុងការងាររបស់រាជរដ្ឋាភិបាល តាមរយៈការបណ្តុះបណ្តាលលើវិស័យទាំង០៥រួមមាន ១- ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ២- ការអប់រំរបស់ស្ត្រីនិងកុមារី និងការផ្លាស់ប្តូរឥរិយាបថ ៣- កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រីនិងកុមារី ៤- សុខភាពអាហារូបត្ថម្ភសម្រាប់ស្ត្រីនិងក្មេងស្រីនិងទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍ និង៥- ស្ត្រីក្នុងការធ្វើ

សេចក្តីសម្រេចចិត្តក្នុងវិស័យសាធារណៈនិងនយោបាយ ផ្នែកច្បាប់ ការផ្សព្វផ្សាយព័ត៌មាន ការស្វែងរកការគាំទ្រមតិនិងការតស៊ូមតិ។ ក្រសួងមានកម្មវិធីផ្តល់មូលនិធិតាមភូមិដល់គ្រួសាររបស់កុមារដែលត្រូវបានជួយសង្គ្រោះ និងអ្នកដែលងាយរងគ្រោះដោយអំពើហិង្សា អំពើរំលោភសេពសន្ថវៈ ការកេងប្រវ័ញ្ចផ្លូវភេទនិងអំពើជួញដូរកម្លាំងពលកម្ម។

១៧- ការផ្សព្វផ្សាយនិងបណ្តុះបណ្តាលអំពីពិធីសារៈ

- ព្រះរាជាណាចក្រកម្ពុជាបានធ្វើការផ្សព្វផ្សាយខ្លឹមសារនៃពិធីសារនេះដល់ស្ថាប័នពាក់ព័ន្ធ រួមទាំងបណ្តាញសារព័ត៌មានដើម្បីបន្តផ្សព្វផ្សាយឲ្យបានជ្រួតជ្រាបទៅដល់ប្រជាពលរដ្ឋរួមទាំងកុមារ។ ខ្លឹមសារពិធីសារនេះគឺជាមូលដ្ឋានដ៏សំខាន់ សម្រាប់បន្តការលើកកម្ពស់ការយល់ដឹងនិងការស្វែងរកការគាំទ្រពីអាជ្ញាធរមូលដ្ឋាននិងសហគមន៍ផងដែរ។ ទន្ទឹមនឹងនេះ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារដែលជាស្ថាប័នសេនាធិការរបស់រាជរដ្ឋាភិបាល ក៏មានភារកិច្ចផ្សព្វផ្សាយនិងតាមដានត្រួតពិនិត្យអំពីការអនុវត្តខ្លឹមសារនេះនិងបានបោះពុម្ពឯកសារអំពីខ្លឹមសារ ដើម្បីប្រើប្រាស់ក្នុងការផ្សព្វផ្សាយ។
- ការផ្សព្វផ្សាយពិធីសារនេះ កំពុងត្រូវបានបន្តនិងបានសម្របសម្រួលរវាងស្ថាប័នរាជរដ្ឋាភិបាលនិងសង្គមស៊ីវិល ដោយបានបញ្ចូលខ្លឹមសារពិធីសារនេះនៅតាមវគ្គបណ្តុះបណ្តាលជាច្រើនសម្រាប់ភ្នាក់ងារសង្គមកិច្ចនិងមន្ត្រីដែលអនុវត្តច្បាប់។
- ក្រសួងអប់រំ យុវជន និងកីឡាបានដាក់បញ្ចូលអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារទៅក្នុងកម្មវិធីសិក្សា ហើយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានបញ្ចូលអនុសញ្ញាស្តីពីសិទ្ធិកុមារទៅក្នុងកម្មវិធីបណ្តុះបណ្តាលមន្ត្រីសង្គមកិច្ចផងដែរ។ បទប្បញ្ញត្តិក្រមព្រហ្មទណ្ឌទាក់ទងនឹងបទល្មើសប្រឆាំងកុមារត្រូវបានបណ្តុះបណ្តាលដល់នគរបាល សមត្ថកិច្ចតុលាការ និងអ្នកប្រតិបត្តិដទៃទៀត។
- ក្រសួងមហាផ្ទៃបានចេញគោលការណ៍ណែនាំដល់អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌឲ្យដាក់បញ្ចូលបញ្ហាស្ត្រីនិងកុមារ ជាចំណុចអាទិភាព នៅក្នុងរបៀបវារៈប្រជុំរបស់គេនិងរាយការណ៍ជាប្រចាំពីភាពរីកចម្រើននៃការធ្វើអន្តរាគមន៍គន្លឹះនានា។ សិក្ខាសាលាមួយចំនួនត្រូវបានធ្វើឡើងនៅក្នុងចំណោមអ្នកធ្វើការសម្រេចចិត្ត ដើម្បីពិភាក្សាពីសារៈសំខាន់ក្នុងការអនុវត្តសកម្មភាពសាមញ្ញនិងអាចថ្លឹងថ្លែងបាន សម្រាប់ស្ត្រីនិងកុមារ តាមរយៈកិច្ចសហការរវាងអាជ្ញាធរខេត្ត អ្នកផ្តល់សេវាសង្គមសំខាន់ៗ និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។
- ក្រសួងអប់រំ យុវជន និងកីឡាបានធ្វើការផ្សព្វផ្សាយអំពីវិធានការនិងផែនការប្រឆាំងទប់ស្កាត់អំពើជួញដូរមនុស្ស ដល់សិស្ស និស្សិតនៅតាមសាលានិងឧត្តមសិក្សាទូទាំងប្រទេស រួមទាំងកម្មវិធីអប់រំក្រៅប្រព័ន្ធ និងមានកម្មវិធីត្រួតពិនិត្យតាមដានសុវត្ថិភាពកុមារតាមសាលា។ ទន្ទឹមនឹងនេះ ក្រសួងមានកម្មវិធីអប់រំដល់សហគមន៍ រួមទាំងមាតាបិតាឬអ្នកអាណាព្យាបាលរបស់សិស្ស និស្សិត ដើម្បីលើកកម្ពស់ការយល់ដឹង មានស្មារតីប្រុងប្រយ័ត្ន និងការពារកុមារឲ្យរួចផុតពីការជួញដូរ។
- ក្រោយពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលបានចាប់ផ្តើមពីឆ្នាំ២០០២មក ក្រុមប្រឹក្សា ឃុំ សង្កាត់ នៅទូទាំងប្រទេសបានជ្រើសរើសជនបង្គោលដើម្បីទទួលខុសត្រូវការងារស្ត្រីនិងកុមារ(CFPWC)សំដៅធានាថា បញ្ហាស្ត្រីនិងកុមារត្រូវបានដាក់បញ្ចូលទៅក្នុងការរៀបចំផែនការនិង

សេចក្ដីសម្រេចនានានៅថ្នាក់វិមជ្ឈការ(ឃុំ សង្កាត់)។ ចាប់ពីឆ្នាំ២០០៥មក គណៈកម្មាធិការឃុំទទួលបន្ទុកកិច្ចការស្ត្រីនិងកុមារ(CCWC) ត្រូវបានបង្កើតនិងសាកល្បងនៅខេត្តចំនួន០៦ក្នុងឃុំ សង្កាត់ចំនួន២០៣ គាំទ្រដោយមូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ(UNICEF) ដែលដើរតួនាទីជាអង្គភាពសម្រាប់ពិគ្រោះយោបល់ចំពោះក្រុមប្រឹក្សាឃុំ សង្កាត់ស្ដីពីបញ្ហានានាដែលពាក់ព័ន្ធស្ត្រីនិងកុមារ។ បច្ចុប្បន្ន គណៈកម្មាធិការនេះត្រូវបានបង្កើតឡើងទូទាំងប្រទេស។ ឯកសារបង្រៀនស្ដីពីសិទ្ធិកុមារ សុខភាព ការអប់រំ និងការការពារកុមារត្រូវបានរៀបចំដើម្បីបណ្ដុះបណ្ដាលដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីឲ្យសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ កាន់តែមានការយល់ដឹងស៊ីជម្រៅបន្ថែមទៀតទៅលើសិទ្ធិកុមារ សេវានានាដែលផ្ដល់ដោយរាជរដ្ឋាភិបាលនិងរបៀបរបបដែលសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ អាចរួមចំណែកចែករំលែកក្នុងការធ្វើឲ្យល្អប្រសើរនូវការផ្ដល់និងការប្រើប្រាស់នូវសេវាទាំងនោះ។

- គម្រោងអន្តរៈទីភ្នាក់ងារសហប្រជាជាតិប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស(UNIAP) បាននិងកំពុងអនុវត្តសកម្មភាពរបស់ខ្លួនក្នុងបណ្ដាប្រទេសទាំង០៦នៃមហាអនុតំបន់មេគង្គ ដែលរួមមានព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដោយបានកសាងមូលដ្ឋានចំណេះដឹងស្ដីពីយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទាំងថ្នាក់តំបន់ ទាំងថ្នាក់ជាតិជូនដល់មន្ត្រីរាជការ ដែលកំពុងធ្វើការងារប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ព្រមទាំងគាំទ្រដល់សកម្មភាពរបស់ក្រុមការងារ សម្របសម្រួលគំនិតផ្ដួចផ្ដើមថ្នាក់រដ្ឋមន្ត្រីប្រឆាំងអំពើជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គ(COMMIT)កម្ពុជា។
- ព្រះរាជាណាចក្រកម្ពុជា បានយកចិត្តទុកដាក់យ៉ាងសកម្មក្នុងការផ្សព្វផ្សាយនិងបណ្ដុះបណ្ដាលឲ្យមានការយល់ដឹងទូទៅអំពីការទប់ស្កាត់និងការប្រឆាំងការជួញដូរមនុស្សជាពិសេសកុមារ ដូចជា៖
    - ការយល់ដឹងជាសាធារណៈអំពីច្បាប់ ការអនុវត្តច្បាប់ និងគោលនយោបាយរបស់រាជរដ្ឋាភិបាលតាមរយៈការបើកវេទិកាជាសាធារណៈតាមរាជធានី ខេត្ត។
    - បានបើកវគ្គបណ្ដុះបណ្ដាលបច្ចេកទេសដល់មន្ត្រីអនុវត្តច្បាប់ រួមមាននគរបាលឯកទេស កងរាជអាវុធហត្ថ ព្រះរាជអាជ្ញា និងចៅក្រមអំពីបច្ចេកទេសស៊ើបអង្កេត ចោទប្រកាន់ និងផ្ដន្ទាទោស រួមទាំងបច្ចេកទេសលើកទឹកចិត្តដល់ជនរងគ្រោះដែលជាសាក្សីឲ្យហ៊ានឆ្លើយនៅចំពោះមុខតុលាការ។ ក្នុងឆ្នាំ២០០៩ ក្រសួងយុត្តិធម៌បានធ្វើការផ្សព្វផ្សាយសេចក្ដីណែនាំពីការអនុវត្តមាត្រា៤២និងមាត្រា៤៣នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទដល់គ្រប់សាលាដំបូងរាជធានី ខេត្ត។
    - សម្របសម្រួលកិច្ចសហប្រតិបត្តិការ តាមរយៈកិច្ចប្រជុំទៀងទាត់របស់ប្រធានអង្គភាពប្រឆាំងអំពើជួញដូររបស់ប្រទេសទាំង០៣ (ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋសង្គមនិយមវៀតណាម និងព្រះរាជាណាចក្រថៃ) និងបណ្ដុះបណ្ដាលមន្ត្រីជួរមុខរួមមាន វរសេនាតូចការពារព្រំដែន កងកម្លាំងនគរបាល កងរាជអាវុធហត្ថ អាជ្ញាធរមូលដ្ឋានផ្នែកពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល

ជាតិនិងអន្តរជាតិ ដើម្បីបង្កើនការគ្រប់គ្រងត្រួតពិនិត្យនិងពង្រឹងកិច្ចសហប្រតិបត្តិការ ក្នុងការតាមចាប់និងបង្ក្រាបខ្សែបណ្ដាញពួកឧក្រិដ្ឋជនដែលបានប្រព្រឹត្តអំពើជួញដូរកុមារឲ្យទទួលបានលទ្ធផលល្អ។

- បានបណ្ដុះបណ្ដាលឲ្យមានការយល់ដឹងពីយុទ្ធសាស្ត្រទប់ស្កាត់ប្រឆាំងអំពើជួញដូរស្ត្រីនិងកុមារដល់មន្ត្រីរាជការរាជធានី ខេត្ត។

១៨- ចំពោះសកម្មភាពនានារបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សូមមេត្តាមើលកថាខណ្ឌទី៣៣នៃរបាយការណ៍នេះ។

១៩- សេវាកម្មច្បាប់និងតំណាងជនរងគ្រោះដោយអំពើជួញដូរ ត្រូវបានផ្ដល់ដោយគណៈមេធាវីកម្ពុជា។ រាជរដ្ឋាភិបាលបានផ្ដល់ថវិកាដល់ការប្រព្រឹត្តទៅរបស់គណៈមេធាវីដើម្បីធានាឲ្យអ្នកក្រីក្រទទួលបាននូវការការពារតាមច្បាប់ដោយមិនបង់ថ្លៃ។ ជំនួយនេះត្រូវបានផ្ដល់ផងដែរដោយអង្គការមិនមែនរដ្ឋាភិបាល ដូចជា ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា អង្គការការពារយុត្តិធម៌កុមារ(PJJ) អង្គការជំនួយផ្នែកច្បាប់កម្ពុជា(LAC) និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនទៀត។

២០- បទដ្ឋាន លក្ខណវិនិច្ឆ័យ និងយុទ្ធសាស្ត្រសម្រាប់តុលាការសាកល្បង ត្រូវបានរៀបចំឡើងដោយក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។ ក្រសួងយុត្តិធម៌បានរៀបចំផែនការសកម្មភាពរួមនឹងសៀវភៅបញ្ជីដំណើរការរឿងក្ដីនានា ដាក់ឲ្យអនុវត្តសាកល្បងនិងដាក់ឲ្យដំណើរការនៅក្នុងតុលាការគំរូចំនួន០៤។ ក្រសួងយុត្តិធម៌បានបំពាក់របាំងក្នុងបន្ទប់សវនាការនៅក្នុងសាលាដំបូងរាជធានី ខេត្តទូទាំងប្រទេស។ បន្ទប់សវនាការភ្ជាប់បណ្ដាញទូរទស្សន៍ដើម្បីយកសក្ខីកម្មពីកុមារ ឬជនរងគ្រោះ ឬសាក្សីដែលងាយរងគ្រោះ ត្រូវបានបំពាក់នៅក្នុងសាលាដំបូងរាជធានី ខេត្តចំនួន០៥។ ជាមួយគ្នានេះដែរ ក្រសួងបានផលិតវីដេអូស្ដីពីតួនាទីរបស់តួអង្គយុត្តិធម៌ព្រហ្មទណ្ឌ សម្រាប់អប់រំណែនាំកុមាររងគ្រោះ កុមារជាសាក្សី និងកុមារល្មើសនឹងច្បាប់។ ដោយឡែក ក្រសួងមហាផ្ទៃបានប្រើប្រាស់បន្ទប់សម្ភាសអនីតិជនរងគ្រោះដែលមានបំពាក់ឧបករណ៍បច្ចេកទេសត្រឹមត្រូវនៅតាមនាយកដ្ឋានជំនាញក៏ដូចជានៅតាមរាជធានី ខេត្តសំខាន់ៗមួយចំនួន។ តុលាការមួយចំនួនក្នុងព្រះរាជាណាចក្រកម្ពុជា ជាពិសេសតុលាការខេត្តកណ្ដាល បានជំរុញការប្រើប្រាស់កាសែតវីដេអូជាភស្តុតាងសម្រាប់ការស៊ើបអង្កេតរឿងក្ដីដែលពាក់ព័ន្ធនឹងកុមារនិងមិនទាមទារឲ្យកុមាររងគ្រោះបង្ហាញខ្លួននៅមុខតុលាការឡើយ។

២១- ក្រោមកិច្ចសហការជាមួយរាជរដ្ឋាភិបាល អង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) បានអនុវត្តកម្មវិធីគាំទ្រគោលនយោបាយនិងច្បាប់ក្នុងរាជធានី ខេត្តចំនួន០៥ ដើម្បីពង្រឹងសមត្ថភាពរបស់ភ្នាក់ងារអនុវត្តច្បាប់និងតុលាការតាមរាជធានី ខេត្ត ក្នុងការចាត់ចែងរឿងក្ដីទាក់ទងនឹងការជួញដូរមនុស្ស។ ក្រសួងយុត្តិធម៌បានបណ្ដុះបណ្ដាលចៅក្រម ព្រះរាជអាជ្ញា នគរបាល និងកងរាជអាវុធហត្ថអំពីច្បាប់ទាក់ទងនឹងការជួញដូរមនុស្សនិងជំនាញក្នុងការស៊ើបអង្កេត។

២២- នាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជនរបស់ក្រសួងមហាផ្ទៃ បានសហការជាមួយគណៈកម្មាធិការសម្របសម្រួលមូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ(UNICEF) ទស្សនៈពិភពលោក

(World Vision) ទេសន្តរប្រវេសន៍អន្តរជាតិ(IOM) សង្គ្រោះកុមារន័រវេស៍(SCN) និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា(OHCHR) អនុវត្តកម្មវិធីស្តីពីការងារអនុវត្តច្បាប់ប្រឆាំងនឹងការរំលោភផ្លូវភេទ ការធ្វើអាជីវកម្មផ្លូវភេទ និងការជួញដូរស្ត្រីនិងកុមារ(LEASETC) ដោយបានបើកវគ្គបណ្តុះបណ្តាលដល់គ្រូបង្គោល ស្នងការរង មន្ត្រីនគរបាលជំនាញ មន្ត្រីនគរបាលឈរជើងនៅតាមព្រំដែន មន្ត្រីនគរបាលយុត្តិធម៌ និងមន្ត្រីនគរបាលពិសេសផ្សេងទៀតនៃរាជធានី ខេត្តចំនួន១៣។ ការបណ្តុះបណ្តាលនេះសំដៅបង្កើនជំនាញស៊ើបអង្កេត ការស្វែងរកភស្តុតាង ការជួយសង្គ្រោះ នីតិវិធីក្នុងការសម្ភាស និងការកសាងសំណុំរឿងបញ្ជូនទៅតុលាការ។ ទន្ទឹមនឹងនេះដែរក៏បានផលិតខ្សែភាពយន្តដែលមានចំណងជើងថា "ជនរងគ្រោះ" ហើយធ្វើការផ្សព្វផ្សាយតាមទូរទស្សន៍។ នាយកដ្ឋានមានទូរសព្ទពិសេស២៤ម៉ោងលើ២៤ម៉ោង (Hot line) ដែលទទួលការហៅចូលបានពីរភាសាគឺ ខ្មែរនិងអង់គ្លេស។ លើសពីនេះទៀត រហូតដល់ឆ្នាំ២០០៧ នាយកដ្ឋានបានរៀបចំបន្ទប់សម្ភាសសម្រាប់កុមារ(Child friendly interview room) ដោយប្រើម៉ាស៊ីនថតរូបភាព (Camera Video) នៅតាមស្នងការដ្ឋាននគរបាលរាជធានី ខេត្តចំនួន១០ ក្នុងគោលដៅបញ្ចៀសការភ័យខ្លាចដល់កុមាររងគ្រោះនៅពេលធ្វើសម្ភាសន៍។

- នាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន បានជំរុញអង្គភាពជំនាញតាមរាជធានី ខេត្តឲ្យអនុវត្តផែនការលេខ១២ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៧ របស់ក្រសួងដែលក្នុងនោះ មានវិធានការធំៗចំនួន០៤គឺ ១- ការគ្រប់គ្រងនិងតាមដានសភាពការណ៍ ២- ការបង្ការទប់ស្កាត់ ៣- ការបង្ក្រាប ៤- ការពង្រីកនិងពង្រឹងធនធានមនុស្ស។ ដោយមានកិច្ចសហការល្អជាមួយអង្គភាពនៃក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកិច្ចការនារី ក្រសួងទេសចរណ៍ អាជ្ញាធរដែនដី អង្គភាពជំនាញនៅតាមរាជធានី ខេត្ត បានធ្វើការផ្សព្វផ្សាយដល់សិស្សនិងប្រជាពលរដ្ឋឲ្យយល់អំពីច្បាប់ ល្បិចកល និងសកម្មភាពរបស់ជនល្មើស ដើម្បីឲ្យពួកគេសហការ ផ្តល់ព័ត៌មានទាន់ពេលដើម្បីចាប់ខ្លួនជនល្មើស។ ក្នុងករណីជនល្មើសជាបរទេស នាយកដ្ឋានបានសហការជាមួយស្ថានទូតឬស្ថានកុងស៊ុលប្រចាំនៅព្រះរាជាណាចក្រកម្ពុជាដើម្បីនាំជននោះមកផ្តន្ទាទោស។
- នៅឆ្នាំ២០០៩ នគរបាលយុត្តិធម៌នៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន និងមន្ត្រីនៃការិយាល័យប្រឆាំងការជួញដូរនិងការពារអនីតិជននៃរាជធានី ខេត្ត ចំនួន១០ បានទទួលការហ្វឹកហ្វឺននៅនឹងកន្លែងស្តីពីការតាមដាន ការគ្រប់គ្រងនៅក្នុងពេលស៊ើបអង្កេត និងការបញ្ជូនករណីជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ ការកេងប្រវ័ញ្ចផ្លូវភេទ និងអំពើហិង្សាក្នុងគ្រួសារ។ សៀវភៅបណ្តុះបណ្តាលនគរបាលត្រូវបានធ្វើបច្ចុប្បន្នកម្មដោយដាក់បញ្ចូលបទប្បញ្ញត្តិពាក់ព័ន្ធដែលមាននៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនិងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ។ សិក្ខាសាលាថ្នាក់ជាតិចំនួន០២លើក ត្រូវបានរៀបចំឡើងដោយមានការចូលរួមពីការិយាល័យនិងផ្នែកប្រឆាំងការជួញដូរនិងការពារអនីតិជននៃរាជធានី ខេត្តទាំង២៤ ដើម្បីធ្វើការផ្លាស់ប្តូរបទពិសោធនិងមេរៀនល្អៗក្នុងការចាត់ការករណីរំលោភបំពានផ្លូវភេទ ការកេងប្រវ័ញ្ចផ្លូវភេទ និងអំពើហិង្សាលើស្ត្រីនិងកុមារ និងពិនិត្យឡើងវិញនូវទិដ្ឋភាពច្បាប់និងបច្ចេកទេសស៊ើបអង្កេត។ អធិការ

អធិការរងក្រុង ស្រុក ខណ្ឌ ប្រធាន អនុប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ចំនួន៩៥០នាក់នៃរាជធានី ខេត្តចំនួន១០ បានទទួលការបណ្តុះបណ្តាលស៊ីជម្រៅទាក់ទងនឹងនីតិវិធីច្បាប់ជំនាញស៊ើបអង្កេត និងការសហការជាមួយអាជ្ញាធរមូលដ្ឋាន។ នគរបាលយុត្តិធម៌ជាង១ ៧០០នាក់ បានទទួលការបណ្តុះបណ្តាលនៅបណ្ឌិត្យសភានគរបាលនិងសាលាហ្វឹកហ្វឺននគរបាលនៅតាមភូមិភាគចំនួន០៦ ដើម្បីធ្វើឲ្យជ្រួតជ្រាបអំពីបញ្ហាទាក់ទងនឹងការរំលោភបំពានផ្លូវភេទ ការកេងប្រវ័ញ្ចផ្លូវភេទ ការជួញដូរកុមារនិងនីតិវិធីក្នុងការចាត់ការករណីទាំងនោះ។

- ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល និងក្រសួងយុត្តិធម៌បានរៀបចំឲ្យមានការបណ្តុះបណ្តាលរួមគ្នា និងការបណ្តុះបណ្តាលដោយឡែកសម្រាប់នគរបាលយុត្តិធម៌ វេជ្ជបណ្ឌិត និងតុលាការស្តីពីនីតិវេជ្ជសាស្ត្រ និងការស៊ើបអង្កេតករណីរំលោភបំពានផ្លូវភេទលើកុមារ។ វគ្គបណ្តុះបណ្តាលទីមួយស្តីពីទិដ្ឋភាពនីតិវេជ្ជសាស្ត្រនិងទិដ្ឋភាពសុខុមាលភាពនៃការស៊ើបអង្កេតករណីរំលោភបំពានផ្លូវភេទលើកុមារប្រព្រឹត្តទៅនៅខែតុលាឆ្នាំ២០០៨។ វគ្គបណ្តុះបណ្តាលបន្តស្តីពីទិដ្ឋភាពនីតិវេជ្ជសាស្ត្រនិងទិដ្ឋភាពច្បាប់នៃការស៊ើបអង្កេតករណីរំលោភបំពានផ្លូវភេទលើកុមារ ប្រព្រឹត្តទៅនៅខែមករា ឆ្នាំ២០១០។
- ចាប់តាំងពីឆ្នាំ២០០៦មក វគ្គបណ្តុះបណ្តាលមូលដ្ឋានស្តីពីសិទ្ធិកុមារ ច្បាប់ និងយុត្តិធម៌ ត្រូវបានបញ្ចូលទៅក្នុងវគ្គបណ្តុះបណ្តាលរបស់រាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ សម្រាប់បណ្តុះបណ្តាលដល់ចៅក្រមនិងព្រះរាជអាជ្ញាកំពុងបម្រើការ និងវគ្គបណ្តុះបណ្តាលរបស់សាលាមេធាវីសម្រាប់បណ្តុះបណ្តាលដល់សិស្សមេធាវី។
- គិតមកទល់ឆ្នាំ២០០៩ ចំនួន៥៤ភាគរយនៃមន្ត្រីសង្គមកិច្ចថ្នាក់ជាតិ ថ្នាក់រាជធានី ខេត្ត និង៨៣ភាគរយនៃមន្ត្រីសង្គមកិច្ចថ្នាក់ក្រុង ស្រុក ខណ្ឌបានទទួលវគ្គបណ្តុះបណ្តាលមូលដ្ឋាន និងជំនាញស្តីពីកិច្ចការសង្គម។ មេរៀនស្តីអំពីតួនាទីមន្ត្រីសង្គមកិច្ចនៅក្នុងប្រព័ន្ធយុត្តិធម៌កុមារ ត្រូវបានដាក់បញ្ចូលទៅក្នុងវគ្គបណ្តុះបណ្តាលមូលដ្ឋាននិងថ្នាក់ជំនាញខាងសេវាសង្គមកិច្ចនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។
- ក្នុងឆ្នាំ២០០៩ ក្រសួងយុត្តិធម៌បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលពហុវិស័យស្តីពីយុត្តិធម៌អនីតិជនសម្រាប់គ្រូបង្គោលចំនួន៣៥នាក់ដែលជាមន្ត្រីតុលាការ សង្គមកិច្ច និងអង្គការមិនមែនរដ្ឋាភិបាល។

២៣- ដោយសារការអនុវត្តពិធីសារទាមទារឲ្យមានក្រសួងនិងស្ថាប័នអនុវត្តច្រើន កន្លងមក មិនមានការធ្វើវិភាជន៍ថវិកាសម្រាប់តែសកម្មភាពដែលពាក់ព័ន្ធនឹងការអនុវត្តពិធីសារនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធបានបញ្ចូលសកម្មភាពដែលរួមវិភាគទានដល់ការអនុវត្តពិធីសារនេះទៅក្នុងផែនការរួមរបស់ខ្លួន។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិដែលជាកញ្ចប់ថវិកាដោយឡែកនៅក្នុងក្របខ័ណ្ឌប្រចាំឆ្នាំរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារទទួលការឧបត្ថម្ភថវិកាមួយចំនួនពីដៃគូអភិវឌ្ឍនិងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការដើម្បីនិង/ឬជាមួយនឹងកុមារសម្រាប់កិច្ចការដែលអង្គការទាំងនោះគាំទ្រ។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារមិនមានកញ្ចប់ថវិកានិងមិនទទួលបានជំនួយសម្រាប់អនុវត្តពិធីសារឡើយ។

២៤- យុទ្ធសាស្ត្រទូទៅដើម្បីលុបបំបាត់ការជួញដូរកុមារ ពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ និងយុទ្ធសាស្ត្រទាក់ទងនឹងកិច្ចការពារជនរងគ្រោះមានកំណត់នៅក្នុង៖

- ផែនការជាតិ៥ឆ្នាំ ប្រឆាំងការជួញដូរកុមារ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ដែលមានកម្មវិធីចំនួន០៥ គឺ ១- គោលនយោបាយនិងកិច្ចសហប្រតិបត្តិការ ២- ការបង្ការនិងការទប់ស្កាត់ ៣- យុត្តិធម៌ព្រហ្មទណ្ឌ ៤- ការការពារ(ការផ្តល់ជំនួយក្នុងការធ្វើមាតុភូមិនិវត្តន៍ ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្ម) និង ៥- ការពិនិត្យតាមដាននិងការវាយតម្លៃ។
- គោលនយោបាយនិងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស
- គោលនយោបាយជាតិស្តីពីការថែទាំជំនួសចំពោះកុមារ។

រាជរដ្ឋាភិបាលបានចេញលិខិតលេខ១៧៤៨ សជណ.អរ ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០៧ ដោយបានចាត់ទុកថ្ងៃ១២ធ្នូ ជាទិវាប្រឆាំងការជួញដូរមនុស្ស។

២៥- សង្គមស៊ីវិលបានចូលរួមវិភាគទានយ៉ាងច្រើនចំពោះកិច្ចខិតខំដើម្បីលុបបំបាត់ការជួញដូរកុមារ ពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ។ សេវាផ្ទាល់ដូចជាសេវាស្តារនីតិសម្បទា សេវាសមាហរណកម្ម ការលើកកម្ពស់ការយល់ដឹង និងសេវាផ្នែកច្បាប់ជាអាទិ៍ ត្រូវបានផ្តល់ឲ្យកុមារតាមរយៈអង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ។ សេវាសំខាន់ៗដែលផ្តល់ដោយសង្គមស៊ីវិល រួមមាន៖

ក- សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលប្រឆាំងការជួញដូរកុមារនៅកម្ពុជា(Cambodia Acts) មានអង្គការចំនួន១២ជាសមាជិក។ សមាជិកនៃសម្ព័ន្ធអង្គការនេះធ្វើប្រតិបត្តិការក្នុងរាជធានី ខេត្តចំនួន១០។ កម្មវិធីនិងសកម្មភាពរបស់សម្ព័ន្ធអង្គការនេះ និងសមាជិកនៃសម្ព័ន្ធ មានជាអាទិ៍៖

- ចូលរួមធ្វើសកម្មភាពប្រារព្ធទិវាប្រឆាំងការជួញដូរមនុស្សនៅថ្ងៃទី១២ធ្នូរៀងរាល់ឆ្នាំ
- ការផ្សព្វផ្សាយអនុសញ្ញាស្តីពីសិទ្ធិកុមារនិងពិធីសារនៃអនុសញ្ញានេះដល់សហគមន៍
- ការជំរុញការអនុវត្តច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ តាមរយៈក្រសួងកិច្ចការនារី (ច្បាប់នេះត្រូវបានអនុម័តនៅឆ្នាំ២០០៨)
- ការបណ្តុះបណ្តាលដល់អ្នកសារព័ត៌មាននិងនគរបាលថ្នាក់រាជធានី ខេត្ត អំពីអនុសញ្ញាស្តីពីសិទ្ធិកុមារនិងពិធីសារនៃអនុសញ្ញានេះ
- ការផ្តល់សេវាផ្នែកច្បាប់ដោយមេធាវីចំនួន០៣នាក់ដល់ជនរងគ្រោះ
- ការផ្តល់សេវាពិគ្រោះយោបល់ដល់ជនរងគ្រោះនិងផ្តល់ថវិកាដើម្បីបង្កើតមុខរបរ និងបញ្ជូនទៅបណ្តុះបណ្តាលវិជ្ជាជីវៈទៅតាមស្ថានភាពសមស្រប។
- កម្មវិធីបណ្តាញភូមិសុវត្ថិភាពដោយបានជំរុញកុមារឲ្យចូលរៀន លុបបំបាត់អំពើហិង្សានិងល្បែងស៊ីសង។ កម្មវិធីនេះបានផ្តល់ប្រាក់កម្ចីដើម្បីឲ្យប្រជាជនបង្កើតមុខរបរ ហើយមានកម្មវិធីផ្សេងៗទៀតដូចជាការជំរុញការអនុវត្តច្បាប់ ការអប់រំសហគមន៍ឲ្យយល់ដឹងពីការជួញដូរ មិត្តអប់រំមិត្ត និងការស្រង់ព័ត៌មាននិងទិន្នន័យ។

ខ- អង្គការដែលជាសមាជិកនៃសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលដើម្បីដោះស្រាយបញ្ហាកេងប្រវ័ញ្ចផ្លូវភេទ

លើកុមារនៅកម្ពុជា(COSECAM) មានអង្គការជាសមាជិកចំនួន២៥។ សមាជិកនៃសម្ព័ន្ធអង្គការនេះផ្តល់សេវាបង្ការ សេវាផ្នែកច្បាប់ សេវាជួយសង្គ្រោះ សេវាស្តារនីតិសម្បទា និងសេវាសមាហរណកម្មដល់ជនរងគ្រោះ។ សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលដើម្បីដោះស្រាយបញ្ហាកេងប្រវ័ញ្ចផ្លូវភេទលើកុមារនៅកម្ពុជា (COSECAM) បាននិងកំពុងអនុវត្តកម្មវិធីចម្បង០៣ នៅក្នុងរាជធានី ខេត្ត ចំនួន០៩៖

- COSECAM បានធ្វើការលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិកុមារ ការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទដល់កុមារនិងប្រជាពលរដ្ឋក្រីក្រនៅតាមសហគមន៍មួយចំនួននៃរាជធានី ខេត្ត ចំនួន០៩ បុគ្គលិកជំនាញនៃស្ថាប័នរដ្ឋាភិបាល អង្គការមួយចំនួន និងសិស្សនៅតាមសាលាក្នុងនិងក្រៅប្រព័ន្ធតាមរយៈបណ្ណាល័យចល័ត ការប្រជុំផ្សព្វផ្សាយ ការចែកខិត្តបណ្ណ ការបញ្ចាំងវីដេអូ ការផ្សព្វផ្សាយតាមវិទ្យុទូរទស្សន៍។
- ធ្វើការបណ្តុះបណ្តាលវិជ្ជាជីវៈដល់កុមារក្រីក្រក្នុងសហគមន៍មួយចំនួន ដើម្បីឲ្យពួកគេមានមុខរបរ និងដើម្បីកុំឲ្យធ្លាក់ក្នុងភាពរងគ្រោះនៃការជួញដូរនិងកេងប្រវ័ញ្ចផ្លូវភេទ។
- ធ្វើការសម្របសម្រួលលើការគ្រប់គ្រងករណីក្នុងរាជធានី ខេត្ត ចំនួន០៥។

គ- គណៈកម្មការបំបាត់ពេស្យាចារ ការរំលោភ និងការជួញដូរកុមារ(ECPAT) មានអង្គការជាសមាជិកចំនួន២៩។ សមាជិកនៃសម្ព័ន្ធអង្គការនេះធ្វើប្រតិបត្តិការក្នុងរាជធានី ខេត្តចំនួន១៩។ កម្មវិធីនិងសកម្មភាពរបស់សម្ព័ន្ធអង្គការនិងសមាជិកសម្ព័ន្ធ មានជាអាទិ៍៖

- ការបង្ការការជួញដូរមនុស្សតាមរយៈការលើកកម្ពស់ការយល់ដឹងអំពីការជួញដូរមនុស្ស ដើម្បីកាត់បន្ថយហានិភ័យនៃការជួញដូរ
- ការការពារ ដោយសហការជាមួយនគរបាលដើម្បីសង្គ្រោះនិងផ្តល់ការស្តារនីតិសម្បទាដល់កុមាររងគ្រោះនិងងាយរងគ្រោះ។ ផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការអប់រំក្រៅប្រព័ន្ធ សេវាផ្នែកច្បាប់ សេវាសុខភាព និងសេវាថែទាំដល់កុមាររងគ្រោះនិងងាយរងគ្រោះ
- សហការជាមួយបណ្តាញ COSECAM និងគណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាល ដើម្បីសិទ្ធិកុមារ(NGOCRC) ក្នុងការប្រមូលទិន្នន័យស្តីពីការជួញដូរផ្លូវភេទនិងការរំលោភសេពសន្ថវៈពីឆ្នាំ២០០៥រហូតមកដល់បច្ចុប្បន្ន
- នៅឆ្នាំ២០០៩ អង្គការសមាជិកចំនួន១០បានអនុវត្តគម្រោងដៃគូយុវជនក្នុងរាជធានីភ្នំពេញ។ គម្រោងនេះ ធ្វើឲ្យយុវជនរងគ្រោះនិងងាយរងគ្រោះជ្រួតជ្រាបអំពីការធ្វើអាជីវកម្មផ្លូវភេទលើកុមារ និងផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ។

ឃ- គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ(NGOCRC) មានអង្គការ៤៩ជាសមាជិក ហើយមានកម្មវិធីធំៗចំនួន០២៖

- ការត្រួតពិនិត្យតាមដានការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលបានអនុវត្តចាប់តាំងពីឆ្នាំ២០០៨ នៅទូទាំងប្រទេស
- ការស្វែងរកការគាំទ្រដើម្បីការចូលរួមរបស់កុមារដែលបានអនុវត្តចាប់តាំងពីឆ្នាំ២០០៦ រហូតមកដល់បច្ចុប្បន្ននៅក្នុងរាជធានី ខេត្តចំនួន១១។

NGOCRC បានរៀបចំពិធីផ្សេងៗក្នុងទិសដៅផ្សព្វផ្សាយបញ្ហាជួញដូរផ្លូវភេទតាមរយៈការផលិតបដា កម្មវិធីសម្តែងរឿងខ្លីៗ សំណួរចម្លើយ និងការចែកចាយខិត្តបណ្ណ ផ្ទាំងរូបភាព ដែលផលិតដោយអង្គការសមាជិក។ ក្រៅពីនេះ NGOCRC បានសហការជាមួយបណ្តាញECPATនិង COSECAM លើការចងក្រងទិន្នន័យរួមគ្នាស្តីពីការរំលោភនិងការជួញដូរផ្លូវភេទនៅព្រះរាជាណាចក្រកម្ពុជា។

ង- អង្គការខេប(KAPE) មិត្តសំឡាញ់(Friend) មូលនិធិអាស៊ី(Asia Foundation) និងអង្គការអប់រំពិភពលោក (World Education) បានចុះអនុស្សរណៈជាមួយក្រសួងអប់រំ យុវជន និងកីឡា អនុវត្តកម្មវិធីអ៊ុបសិន (OPTION) នៅក្នុងខេត្តព្រៃវែង កំពង់ចាម បន្ទាយមានជ័យ និងរាជធានីភ្នំពេញ ដោយបានបង្កើននិងជំរុញការអប់រំប្រកបដោយសមធម៌ចំពោះកុមារីដែលប្រឈមមុខនឹងគ្រោះថ្នាក់និងការធ្វើអាជីវកម្មផ្លូវភេទតាមរយៈកម្មវិធីអប់រំក្នុងនិងក្រៅប្រព័ន្ធ។ អង្គការអប់រំពិភពលោកបានផ្សព្វផ្សាយនៅតាមសហគមន៍អំពីការជួញដូរនិងការធ្វើអាជីវកម្មផ្លូវភេទលើកុមារ និងជំរុញឲ្យមានការកែប្រែឥរិយាបថដើម្បីឲ្យកុមារ ជាពិសេស កុមារីក្នុងគ្រួសារដែលប្រឈមនឹងបញ្ហាជីវភាពក្រីក្រ បានចូលរៀន។

ច- អង្គការពលកម្មអន្តរជាតិ/កម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ គម្រោងមហាអនុតំបន់មេគង្គប្រឆាំងការជួញដូរស្ត្រីនិងកុមារ(ILO/IPEC-TICW) បានធ្វើសកម្មភាពជាមួយស្ថាប័នរដ្ឋាភិបាល សមាគមនិយោជក សហជីព អង្គការសហប្រជាជាតិនិងអង្គការមិនមែនរដ្ឋាភិបាលក្នុងទិសដៅលុបបំបាត់ការជួញដូរនិងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ និងពលកម្មកុមារ លើកកម្ពស់ការធ្វើចំណាកស្រុកដោយសុវត្ថិភាពតាមរយៈការកាត់បន្ថយភាពងាយរងគ្រោះ។ សកម្មភាពនេះបានអនុវត្តជាមួយជនដែលកំពុងរស់នៅកន្លែងគ្រោះថ្នាក់ជាងគេបំផុត ដែលអាចធ្វើឲ្យពួកគេធ្លាក់ខ្លួនជាជនរងគ្រោះដោយមិនដឹងខ្លួន ដោយប្រាប់ឲ្យពួកគេដឹងមុនអំពីគ្រោះថ្នាក់នៃការធ្វើចំណាកស្រុកដែលគ្មានព័ត៌មានច្បាស់លាស់និងមិនបានរៀបចំទុកជាមុន។ គម្រោងនេះបានជួយគាំទ្រស្ថាប័នរដ្ឋាភិបាលគ្រប់ជាន់ថ្នាក់ដើម្បីអភិវឌ្ឍនិងរក្សាការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងបានផ្តោតការយកចិត្តទុកដាក់ចំពោះស្ត្រីនិងកុមារដែលមានជីវភាពខ្សត់ខ្សោយ ខ្វះការអប់រំរៀនសូត្រ ដែលងាយរងគ្រោះដោយការកេងប្រវ័ញ្ចផ្លូវភេទនិងពលកម្ម។ គម្រោងបានឧបត្ថម្ភគាំទ្រដល់កម្មវិធីជួយស្ត្រីនិងកុមារវ័យក្មេងងាយរងគ្រោះ ដើម្បីកែលម្អគុណភាពជីវិតរបស់ពួកគេ។

២៦- ចាប់តាំងពីឆ្នាំ២០០៦មក អង្គការមូលនិធិអាស៊ីបានអនុវត្តកម្មវិធីប្រឆាំងអំពើជួញដូរមនុស្សដែលមាន០៤សមាសភាគៈ ការបង្ការទប់ស្កាត់ កិច្ចការពារ កិច្ចសហការសម្របសម្រួល និងការផ្តន្ទាទោស។ គម្រោងនេះគាំទ្រដល់គណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារខេត្ត ក្នុងការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន និងអាជ្ញាធរមូលដ្ឋាន ឲ្យយល់ដឹងពីបញ្ហាជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយមានសុវត្ថិភាព និងយល់ដឹងពីល្បិចកលរបស់ជនល្មើស។ ក្នុងឆ្នាំ២០១០ តាមរយៈកម្មវិធីនេះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានធ្វើការបណ្តុះបណ្តាលអំពីគោលនយោបាយនិងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្សដល់៖

- គ្រូបង្គោលចំនួន២៨នាក់
- មន្ត្រីគណៈកម្មាធិការជាតិដឹកនាំការបង្រ្កាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារថ្នាក់ជាតិ ចំនួន៥០នាក់
- មន្ត្រីសង្គមកិច្ចថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌមកពីរាជធានី ខេត្ត ទាំង២៤។

កម្មវិធីនេះបានបណ្តុះបណ្តាលលើប្រធានបទដូចគ្នា ដល់អង្គការមិនមែនរដ្ឋាភិបាលចំនួន០៣វគ្គ និងបញ្ជ្រាបការបណ្តុះបណ្តាលលើប្រធានបទនេះទៅក្នុងកម្មវិធីបណ្តុះបណ្តាលស្តីពីបទដ្ឋានអប្បបរមានិងស្តីពីការថែទាំជំនួសចំពោះកុមារ។ ការបណ្តុះបណ្តាលអំពីគោលនយោបាយនិងបទដ្ឋាន អប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្សគ្រោងនឹងបញ្ចូលទៅក្នុងកម្មវិធីបណ្តុះបណ្តាលជំនាញសង្គមកិច្ច។ ឧបករណ៍សម្រាប់ត្រួតពិនិត្យតាមដាននិងវាយតម្លៃលើប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយ និងបទដ្ឋានអប្បបរមាត្រូវបានព្រាងនិងដាក់ឲ្យប្រើប្រាស់ក្នុងឆ្នាំ២០១១។

កម្មវិធីបានសាកល្បងដាក់ឲ្យអ្នកពិគ្រោះបញ្ហាប្រើប្រាស់ឧបករណ៍ប៉ាន់ប្រមាណអំពីកម្រិតនៃការប៉ះទង្គិចផ្នែកផ្លូវចិត្តលើកុមាររងគ្រោះដោយសារការកេងប្រវ័ញ្ចផ្លូវភេទ។

២៧- គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ជាស្ថាប័នមួយរបស់រាជរដ្ឋាភិបាលមានភារកិច្ចដើម្បីរក្សា ការពារ អភិវឌ្ឍ និងលើកតម្កើងវិស័យសិទ្ធិមនុស្សនៅព្រះរាជាណាចក្រកម្ពុជាស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ហើយមានតួនាទី៖

- ការពារ លើកស្ទួយ និងអភិវឌ្ឍសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ នៅព្រះរាជាណាចក្រកម្ពុជា និងត្រួតពិនិត្យរាល់ការរំលោភសិទ្ធិមនុស្ស និងបណ្តឹងតវ៉ានានា
- ផ្តល់យោបល់និងលើកសំណើជូនរាជរដ្ឋាភិបាលអំពីសភាពការណ៍សិទ្ធិមនុស្សសំដៅធ្វើការកែលម្អ និងធ្វើយ៉ាងណាឲ្យកាន់តែសមស្របនឹងរដ្ឋធម្មនុញ្ញ ច្បាប់ប្រទេស និងអនុសញ្ញាទាំងឡាយរបស់អន្តរជាតិ
- សហការជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារនិងក្រសួងកិច្ចការនារីដែលជាស្ថាប័នទទួលខុសត្រូវអំពីសិទ្ធិកុមារនិងសិទ្ធិនារី
- គាំទ្រសហការជាមួយអង្គការសង្គមស៊ីវិល ដើម្បីបុព្វហេតុការពារនិងអភិវឌ្ឍវិស័យសិទ្ធិមនុស្សនៅព្រះរាជាណាចក្រកម្ពុជា។

## ការបង្ការ

២៨- ការធ្វើអាជីវកម្មផ្លូវភេទលើកុមារកើតមានជាទូទៅនៅលើពិភពលោកជាបន្តបន្ទាប់។ ប្រទេសជាច្រើនកំពុងកសាងច្បាប់និងចាត់វិធានការដើម្បីទប់ស្កាត់ លុបបំបាត់បញ្ហានេះ។ ដោយឡែក នៅព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលបានដាក់បញ្ចូលក្នុងកម្មវិធីនយោបាយកសាងច្បាប់និងដាក់ចេញនូវវិធានការនិងផែនការសកម្មភាពជាបន្តបន្ទាប់ដើម្បីទប់ស្កាត់បញ្ហានេះ ហើយទន្ទឹមនឹងការអនុវត្តវិធានការទាំងនោះ រាជរដ្ឋាភិបាលកម្ពុជាបានខិតខំជំរុញការអនុវត្តយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ និងការលើកកម្ពស់សុខុមាលភាពសង្គម ជាបញ្ហាអាទិភាពដែលក្នុងនោះបានប្រមូលផ្តុំលើបញ្ហា

អាហារូបត្ថម្ភ សុខុមាលភាព និងការអប់រំ។ ក្នុងការអនុវត្តយុទ្ធសាស្ត្រនេះ ក្រសួងនិងស្ថាប័នរបស់រាជរដ្ឋាភិបាលមានកម្មវិធីជាច្រើន ដោយមានកិច្ចសហការយ៉ាងល្អពីដៃគូអភិវឌ្ឍសំខាន់ៗក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាល។ ដោយឡែក ក្រុមប្រឹក្សាស្តារអភិវឌ្ឍវិស័យកសិកម្មនិងជនបទបានរៀបចំផែនការយុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងងាយរងគ្រោះ។ ផែនការនេះត្រូវបានរាជរដ្ឋាភិបាលអនុម័តនៅខែមេសា ឆ្នាំ២០១១។

២៩- យោងតាមគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ កុមារដែលរស់នៅក្នុងស្ថានភាពងាយរងគ្រោះមួយឬច្រើនប្រភេទដូចមានរៀបរាប់ខាងក្រោមនេះ ត្រូវបានចាត់ទុកថាជាប្រភេទកុមារត្រូវការកិច្ចការពារពិសេសឬកុមារប្រឈមមុខនឹងគ្រោះថ្នាក់។ កុមារត្រូវការកិច្ចការពារពិសេស រួមមានកុមារកំព្រា កុមារដែលត្រូវគេបោះបង់ចោល កុមារផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ឬទទួលរងផលប៉ះពាល់ពីមេរោគអេដស៍/ជំងឺអេដស៍ កុមារដែលទទួលរងការរំលោភបំពានផ្លូវភេទ ឬរូបរាងកាយ ឬផ្លូវចិត្ត កុមារអនាថា កុមារប្រព្រឹត្តល្មើសនឹងច្បាប់ កុមាររងគ្រោះដោយអំពើកេងប្រវ័ញ្ចផ្លូវភេទឬទម្រង់ពលកម្មប្រកបដោយគ្រោះថ្នាក់ កុមារពិការ កុមារញៀនសារធាតុញៀន និងកុមារដែលមិនបានទទួលនូវតម្រូវការរូបវន្តជាមូលដ្ឋាន។ ប្រភេទកុមារដែលប្រឈមមុខនឹងគ្រោះថ្នាក់មានទំនាក់ទំនងទៅនឹងបរិបទមួយចំនួនដូចជាភាពក្រីក្រខ្លាំង ការបែកបាក់គ្រួសារ ការសេពគ្រឿងស្រវឹង ការលេងល្បែងស៊ីសង អំពើហិង្សាក្នុងគ្រួសារ ការបោះបង់ចោលការសិក្សា ការរស់នៅក្នុងតំបន់តាំងទីលំនៅថ្មីនិងជីវិតរស់នៅជាមួយនឹងអ្នកដែលពុំមែនជាឪពុកម្តាយបង្កើតជាដើម។ ការកំណត់អត្តសញ្ញាណកុមារ ដែលងាយរងគ្រោះពីអំពើជួញដូរកុមារ ពេស្យាកម្មកុមារ ឬរូបភាពអាសអាភាសកុមារឈរលើមូលដ្ឋាននៃលក្ខណវិនិច្ឆ័យទាំងនេះ។

៣០- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានបង្កើតនិងធ្វើតេស្តសាកល្បងសេចក្តីព្រាងប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយ ថែទាំជំនួសចំពោះកុមារ និងយន្តការស្តីពីការប្រព្រឹត្តទៅនៃប្រព័ន្ធសុខុមាលភាពកុមារ ក្នុងខេត្តចំនួន០៥(ខេត្តកំពង់ស្ពឺ ខេត្តកំពង់ធំ ខេត្តបាត់ដំបង ខេត្តព្រៃវែង និងខេត្តស្វាយរៀង)។ យន្តការនៅថ្នាក់មូលដ្ឋានកំពុងត្រូវបានធ្វើតេស្តសាកល្បងក្នុងគោលបំណងកំណត់គ្រួសារនិងកុមារងាយរងគ្រោះ ផ្តល់ការជួយឧបត្ថម្ភគាំទ្រដល់គ្រួសារ និងផ្តល់សេវាបញ្ជូនដើម្បីបង្ការការបែកបាក់គ្រួសារឬការមិនអាចធ្វើសមាហរណកម្មនិងស្វែងរកដំណោះស្រាយនៅតាមសហគមន៍ជូនកុមារងាយរងគ្រោះ។

៣១- ចាប់ពីឆ្នាំ២០០១-២០០៩ ក្រសួងកិច្ចការនារីដោយសហការជាមួយនឹងអង្គការទេសន្តរប្រវេសន៍អន្តរជាតិ(IOM)និងទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីកិច្ចអភិវឌ្ឍ(USAID) បានអនុវត្តគម្រោងទប់ស្កាត់រាល់ទម្រង់នៃការជួញដូរស្ត្រីនិងកុមារ ដោយផ្តោតលើផ្នែកសំខាន់ចំនួន០៤ គឺ៖

១- ការបណ្តុះបណ្តាលផ្នែកច្បាប់ ផ្នែកសេដ្ឋកិច្ច និងផ្នែកសង្គមកិច្ច៖

បានបណ្តុះបណ្តាលផ្នែកច្បាប់ ផ្នែកសេដ្ឋកិច្ច និងផ្នែកសង្គមកិច្ចដែលទាក់ទងនឹងការជួញដូរស្ត្រីនិងកុមារ និងការធ្វើចំណាកស្រុក និងច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់និងលក់ដូរមនុស្ស និង

អំពើធ្វើអាជីវកម្មលើមនុស្សដល់មន្ត្រីទទួលបន្ទុកកិច្ចការនារីនិងកុមារ មន្ត្រីមកពីក្រសួងនិងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានក្នុងទូទាំង២៤ រាជធានី ខេត្ត។

២- ប្រព័ន្ធផ្សព្វផ្សាយគោលនយោបាយនិងការស្វែងរកការគាំទ្រមតិ៖

- ប្រព័ន្ធផ្សព្វផ្សាយ៖ បានបណ្តុះបណ្តាលមន្ត្រីក្រសួងអំពីការផលិតកម្មវិធីវិទ្យុនារីរតនៈដែលពាក់ព័ន្ធនឹងច្បាប់ ការជួញដូរមនុស្ស និងការធ្វើចំណាកស្រុក និងសម្ភារៈសម្រាប់ផ្សព្វផ្សាយ និងបានផ្សព្វផ្សាយក្នុងទូទាំងប្រទេសនិងមានកម្មវិធីផ្សព្វផ្សាយដោយឡែកតាមវិទ្យុ FM ខេត្តស្វាយរៀងនិងខេត្តកោះកុងរៀងរាល់ថ្ងៃអង្គារនិងថ្ងៃព្រហស្បត៍។ ដោយឡែក ក្នុងឆ្នាំ២០០៩ បានអនុវត្តយុទ្ធនាការផ្សព្វផ្សាយតាមវិទ្យុនិងទូរទស្សន៍នូវច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ។
- គោលនយោបាយនិងការស្វែងរកការគាំទ្រមតិ៖ បានធ្វើការស្វែងរកការគាំទ្រមតិក្នុងការផ្តល់សច្ចាប័នលើពិធីសារស្តីពីការទប់ស្កាត់ ការបង្ក្រាប និងការផ្តន្ទាទោសការជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារដែលបន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង។
- ដាក់បញ្ចូលខ្លឹមសារនៃពិធីសារបន្ថែមស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារនិងរូបភាពអាសអាភាសកុមារ អង្គការសហប្រជាជាតិដែលពាក់ព័ន្ធនឹងសេចក្តីព្រាងច្បាប់។
- អនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរាជរដ្ឋាភិបាលនៃរាជាណាចក្រថៃស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរកុមារនិងស្ត្រី និងជួយដល់ជនរងគ្រោះដោយសារការជួញដូរ និងរវាងព្រះរាជាណាចក្រកម្ពុជានិងបណ្តាប្រទេសក្នុងមហាអនុតំបន់មេគង្គ។
- រៀបចំនិងចុះហត្ថលេខា ព្រមទាំងអនុវត្តកិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋសង្គមនិយមវៀតណាមឆ្នាំ២០០៥។ ដោយឡែក ក្នុងឆ្នាំ២០១០នេះ ក្រសួងកំពុងធ្វើការស្វែងរកការគាំទ្រមតិក្នុងការចុះហត្ថលេខា លើអនុស្សរណៈនៃការយោគយល់គ្នារវាងព្រះរាជាណាចក្រកម្ពុជានិងសហព័ន្ធម៉ាឡេស៊ី។

៣- យុទ្ធនាការផ្សព្វផ្សាយព័ត៌មាននិងសកម្មភាពថ្នាក់ភូមិ៖

- យុទ្ធនាការផ្សព្វផ្សាយព័ត៌មាន៖ ពីឆ្នាំ២០០១ដល់២០០៦ ក្រសួងកិច្ចការនារីបានធ្វើយុទ្ធនាការផ្សព្វផ្សាយព័ត៌មានអំពីការជួញដូរមនុស្ស ការធ្វើចំណាកស្រុក និងច្បាប់ដល់ប្រជាពលរដ្ឋនៅតាមសហគមន៍គោលដៅក្នុងទូទាំង២៤ រាជធានី ខេត្ត តាមរយៈការបញ្ចាំងវីដេអូ ការសម្តែងរឿងកំប្លែងដែលពាក់ព័ន្ធនឹងការប្រើសំណួរចម្លើយ ការផ្តល់រង្វាន់លើកទឹកចិត្ត និងការចែកចាយសម្ភារៈផ្សព្វផ្សាយដែលភ្ជាប់នូវសារអប់រំ ដូចជា អាវយឺត មួក ផ្ទាំងរូបភាព បណ្ណជំនួយជាដើម ដោយមានអ្នកចូលរួមចំនួនប្រមាណ១០៩ ៣៤០នាក់។
- សកម្មភាពថ្នាក់ភូមិ៖ ពីឆ្នាំ២០០៧ដល់២០០៩ ក្រសួងបានធ្វើការបណ្តុះបណ្តាលមន្ត្រីកិច្ចការនារីនិងអ្នកពាក់ព័ន្ធថ្នាក់ខេត្ត និងអាជ្ញាធរមូលដ្ឋានចំនួន៨៧៨នាក់នៅខេត្តព្រៃវែង ស្វាយរៀង

បន្ទាយមានជ័យ ឧត្តរមានជ័យ និងខេត្តកោះកុង និងធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋតាមភូមិបានចំនួន១៣២លើក ដែលមានអ្នកចូលរួមសរុបចំនួន៧ ៩៦២នាក់។ ក្រៅពីនេះ បានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដោយធ្វើការបណ្តុះបណ្តាលមន្ត្រីនៃមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ស្រុក នាយកសាលា និងលោកគ្រូ អ្នកគ្រូចំនួន១២៩នាក់ នៅខេត្តព្រៃវែង បន្ទាយមានជ័យ និងខេត្តកោះកុង និងធ្វើការផ្សព្វផ្សាយបន្តដល់សិស្សតាមសាលារៀនបានចំនួន២២ ៣៥៥នាក់។ ដោយឡែក ក្នុងឆ្នាំ២០១០ បានផ្សព្វផ្សាយពីសុវត្ថិភាពក្នុងការធ្វើចំណាកស្រុកដល់ភូមិចំនួន១០ ក្នុងស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ដោយមានអ្នកចូលរួមប្រមាណ៥៦០នាក់។

៤- សកម្មភាពកាត់បន្ថយភាពក្រីក្រ៖ ពីឆ្នាំ២០០៦ដល់២០០៩ ក្រសួងកិច្ចការនារីបានបង្ហាញពីកិច្ចខិតខំប្រឹងប្រែងក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្រដែលជាកត្តាជះឥទ្ធិពលដល់ការជួញដូរមនុស្សនិងការកេងប្រវ័ញ្ចនានា តាមរយៈការអនុវត្តដកពិសោធនូវកម្មវិធីមូលនិធិទ្រទ្រង់គ្រួសារ (មូលនិធិបង្កើនប្រាក់ចំណូលនិងមូលនិធិសង្គ្រោះបន្ទាន់) ដើម្បីធ្វើឲ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់គ្រួសារដែលងាយរងគ្រោះដោយសារការជួញដូរនិងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន។ កម្មវិធីនេះបានធ្វើក្នុងភូមិចំនួន១០នៃស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង ដែលមូលនិធិសរុបបានកើនឡើងពី៨ ៧០០ដុល្លារ ក្នុងឆ្នាំ២០០៦ ដល់៩ ៣៣៧ដុល្លារ ក្នុងឆ្នាំ២០០៩ ក្នុងនោះ មាន៨៧៣គ្រួសារបានទទួលមូលនិធិបង្កើនប្រាក់ចំណូលឬប្រាក់កម្ចី និង១២១គ្រួសារបានទទួលមូលនិធិសង្គ្រោះបន្ទាន់។ ជាមួយនេះដែរ នៅមានកម្មវិធីបណ្តុះបណ្តាលជំនាញកាត់ដេរសម្រាប់ចូលបម្រើការងារនៅតាមរោងចក្រជូនដល់សមាជិកគ្រួសារដែលមិនមានលទ្ធភាពបន្តការសិក្សា បានចំនួន៥៦៩នាក់ (៨០ភាគរយបានការងារធ្វើ) និងជំនាញជួសជុលម៉ូតូនិងគ្រឿងម៉ាស៊ីនខ្នាតតូចនិងមធ្យមចំនួន៥៦នាក់។ កម្មវិធីនេះនៅតែបន្តរក្សាបាននូវនិរន្តរភាពរហូតដល់បច្ចុប្បន្ន ទោះបីការគាំទ្ររបស់អង្គការដៃគូបានបញ្ចប់ត្រឹមឆ្នាំ២០០៩ក៏ដោយ។ ក្រៅពីនេះ គ្រួសារដែលងាយរងគ្រោះប្រមាណ២០០គ្រួសារ/៨០០គ្រួសារនៃភូមិគោលដៅទាំង១៤ ក្នុងស្រុកស៊ីធរកណ្តាលនៃខេត្តព្រៃវែង ស្រុកចន្ទ្រា និងស្រុកកំពង់រោទ៍នៃខេត្តស្វាយរៀង បានទទួលផលប្រយោជន៍ពីកម្មវិធីតាមរយៈការបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម ការបង្កើតក្រុមផលិតនិងលក់ស្ករត្នោតថ្នាក់ឃុំ ការបង្កើតក្រុមសន្សំ ការបង្កើតសមាគមកសិករ ការរៀបចំសិក្ខាសាលាផ្លាស់ប្តូរបទពិសោធ ការប្រជុំពេញអង្គថ្នាក់ភូមិ ការចុះពិគ្រោះយោបល់តាមគ្រួសារ និងការធ្វើទស្សនកិច្ចសិក្សាជាដើម។

៣២- ដើម្បីការពារកុមាររងគ្រោះនៅព្រះរាជាណាចក្រកម្ពុជា ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានបំពេញភារកិច្ចដូចតទៅ៖

១- បន្ទាប់ពីផែនការជាតិ៥ឆ្នាំលើកទី១ស្តីពីការប្រឆាំងការជួញដូរនិងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ(២០០០ ដល់២០០៤) បានអនុវត្តដោយជោគជ័យ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានកសាងសេចក្តីព្រាងផែនការជាតិទី២ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទដោយផ្តោតលើកម្មវិធីចំនួន០៥ គឺ ១- ការពង្រឹងការអនុវត្តគោលនយោបាយនិងកិច្ចសហប្រតិបត្តិការ ២- ការបង្ការនិង

ទប់ស្កាត់ ៣- យុត្តិធម៌ព្រហ្មទណ្ឌ ៤- ការការពារ(ការផ្ដល់ជំនួយក្នុងការធ្វើមាតុភូមិនិវត្តន៍ ការស្តារសម្បទា ការធ្វើសមាហរណកម្មទៅក្នុងសង្គមវិញ) និង៥- ការពិនិត្យតាមដាននិងវាយតម្លៃ។ បន្ទាប់មក នៅខែវិច្ឆិកា ឆ្នាំ២០០៧ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានបញ្ជូនសេចក្ដីព្រាងផែនការជាតិនេះជូនគណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ ដើម្បីពិនិត្យនិងកែសម្រួលទៅជាផែនការរួមរបស់ជាតិ។ បច្ចុប្បន្ន អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ សហការជាមួយក្រុមការងារសម្របសម្រួលគំនិតផ្ដួចផ្ដើមថ្នាក់រដ្ឋមន្ត្រីប្រឆាំងការជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គ(COMMIT) បានដាក់ផែនការជាតិនេះជូនគណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ ដើម្បីពិនិត្យនិងអនុម័ត។

២- ក្នុងឆ្នាំ២០១០ បានបើកវគ្គបណ្ដុះបណ្ដាលស្ដីពីគោលការណ៍ការពារសិទ្ធិកុមាររងគ្រោះដោយសារការជួញដូរនៅព្រះរាជាណាចក្រកម្ពុជាដល់ជនបង្គោលនៅខេត្តកណ្ដាល សៀមរាប បន្ទាយមានជ័យ ពោធិ៍សាត់ បាត់ដំបង និងខេត្តតាកែវ បានចំនួន១៨០នាក់ ដែលជាមន្ត្រីមកពីមន្ទីរ អង្គភាពខេត្ត និងអង្គការដែលធ្វើការងារពាក់ព័ន្ធនឹងកុមារ ក្នុងគោលបំណងជំរុញបន្ថែមទៀតលើការអនុវត្តគោលការណ៍ឲ្យបានជោគជ័យនិងមានប្រសិទ្ធភាព ដើម្បីជួយកុមាររងគ្រោះដោយសារការជួញដូរឲ្យទទួលបានសិទ្ធិជាមូលដ្ឋាន។

៣- បានផ្ដួចផ្ដើមរៀបចំវិភាគច្បាប់ជាតិ គោលនយោបាយ លិខិតបទដ្ឋានដែលកំពុងនៅជាធរមាន និងសេចក្ដីព្រាងច្បាប់ គោលនយោបាយដែលកំពុងរង់ចាំការអនុម័តផ្អែកតាមមូលដ្ឋានច្បាប់អន្តរជាតិ ដោយធ្វើការប្រៀបធៀបទៅនឹងច្បាប់ការពារកុមាររបស់ប្រទេសនានា ក្នុងគោលបំណងស្វែងរកនូវចន្លោះខ្វះខាត ដើម្បីកសាងច្បាប់ស្ដីពីការការពារកុមារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬដាក់ចេញជារបៀបវារៈគោលនយោបាយ ឬលិខិតបទដ្ឋាន ឬកំណែទម្រង់ច្បាប់ ឬលិខិតបទដ្ឋាន។

៣៣- ពីឆ្នាំ២០០១ដល់ឆ្នាំ២០០៤ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាដោយសហការជាមួយនឹងមូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ បានបង្កើតកម្មវិធីបណ្ដាញការពារកុមារនៅតាមសហគមន៍។ កម្មវិធីនេះអនុវត្តនៅក្នុងរាជធានី ខេត្ត ចំនួន០៥ មានរាជធានីភ្នំពេញ ខេត្តបាត់ដំបង បន្ទាយមានជ័យ ស្វាយរៀង និងខេត្តព្រៃវែង។ បណ្ដាញការពារកុមារនៅតាមសហគមន៍អនុវត្តនៅក្នុងស្រុកគោលដៅចំនួន១៤ ឃុំចំនួន៦៩ និងភូមិចំនួន៦២៥។ នៅឆ្នាំ២០០៣ កម្មវិធីនេះបានកែសម្រួលយុទ្ធវិធីនិងរចនាសម្ព័ន្ធ ដើម្បីធានានិរន្តរភាពនៃកម្មវិធី និងបង្កើនបាននូវកិច្ចការពារកុមារនៅថ្នាក់ភូមិ។ ចាប់ពីឆ្នាំ២០០៥ដល់២០០៨ កម្មវិធីនេះអនុវត្តនៅពីរខេត្តគឺព្រៃវែងនិងស្វាយរៀង។ កម្មវិធីនេះធ្វើឲ្យភ្នាក់ងារសង្គមកិច្ច អាជ្ញាធរដែនដី និងសហគមន៍បានធ្វើការរួមគ្នាដើម្បីកំណត់អត្តសញ្ញាណជនសង្ស័យថាបានប្រព្រឹត្តបទល្មើស ហើយតាមដានសកម្មភាពជនទាំងនោះ។ ទន្ទឹមនឹង

នេះដែរ កុមារងាយរងគ្រោះមួយចំនួននៅតាមសហគមន៍ក៏ទទួលបានសេវាសង្គមកិច្ច ហើយមូលនិធិសង្គមកិច្ចត្រូវបានបង្កើតឡើងដើម្បីសង្គ្រោះបន្ទាន់នូវកុមារងាយរងគ្រោះនៅក្នុងភូមិគោលដៅចំនួន៩០៨នៃខេត្តទាំងពីរ។ កម្មវិធីនេះបានធ្វើការផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងដល់ប្រជាជននៅក្នុងភូមិលើប្រធានបទចំនួន៣គឺ ១- ការចុះអត្រានុកូលដ្ឋាន ២- ការប្រឆាំងការរំលោភបំពានផ្លូវភេទ ៣- ការប្រឆាំងការវាយដំលើកុមារ។ កម្មវិធីបណ្តាញការពារកុមារតាមសហគមន៍បានធ្វើការផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងដល់ប្រជាជននៅក្នុងភូមិចំនួន១៤ ០៣៩ នៃ១៨៩ស្រុកទូទាំងប្រទេសលើប្រធានបទទាំង០៣ខាងលើនេះ។

៣៤- ក្រសួងអប់រំ យុវជន និងកីឡា ធ្វើការផ្សព្វផ្សាយព័ត៌មានអំពីការជួញដូរមនុស្សដល់សិស្សសាលាតាមរយៈកម្មវិធីសិក្សាក្នុងនិងក្រៅប្រព័ន្ធ និងមានកម្មវិធីពិនិត្យតាមដានសុវត្ថិភាពកុមារតាមសាលា លើកកម្ពស់ការយល់ដឹងដល់សហគមន៍ ឲ្យមានស្មារតីប្រុងប្រយ័ត្នការពារកុមារកុំឲ្យចាញ់បោកពាក្យលួងលោមរបស់ជនខិលខូច ដើម្បីរួចផុតពីការជួញដូរ។ ក្រៅពីការបណ្តុះបណ្តាលនិងយុទ្ធនាការផ្សព្វផ្សាយ នាយកដ្ឋានអប់រំក្រៅប្រព័ន្ធរបស់ក្រសួងបានផលិតសៀវភៅចំនួនពីរប្រភេទ សម្រាប់ការបណ្តុះបណ្តាលក្រៅប្រព័ន្ធដែលមានអត្ថន័យផ្តោតលើអនុសញ្ញាសិទ្ធិកុមារ ការលុបបំបាត់ការជួញដូរ និងអាជីវកម្មផ្លូវភេទ។ សៀវភៅទាំងនោះ ត្រូវបានប្រើប្រាស់ក្នុងការបណ្តុះបណ្តាលអក្សរសាស្ត្រ និងការបណ្តុះបណ្តាលវិជ្ជាជីវៈដែលរៀបចំឡើងដោយអង្គការមិនមែនរដ្ឋាភិបាល។ ក្នុងឆ្នាំ២០០៩ ក្រសួងបានផ្សព្វផ្សាយអំពីការងារមិត្តអប់រំមិត្ត សិទ្ធិកុមារ ការការពារខ្លួនពីការជួញដូរពលកម្ម និងការជួញដូរផ្លូវភេទលើកុមារ ដល់មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ សហគមន៍ មាតាបិតាសិស្ស លោកគ្រូ អ្នកគ្រូ ក្នុងខេត្តព្រៃវែងនិងខេត្តកណ្តាល បានចំនួន២ ៥០៦នាក់។

៣៥- ចាប់ពីខែធ្នូ ឆ្នាំ២០០៨ ដល់ខែធ្នូ ឆ្នាំ២០០៩ គណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មលើមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ បានធ្វើការបញ្ចាំងខ្សែភាពយន្តជូននិស្សិតមហាវិទ្យាល័យចំនួន០៦ ក្រោមប្រធានបទ "ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស"។

- គណៈកម្មាធិការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍របស់ក្រសួងទេសចរណ៍ បានធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួនដូចជា ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួងកិច្ចការនារី ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ដូចជាអង្គការទស្សនៈពិភពលោក(World Vision) គម្រោងអន្តរៈទីភ្នាក់ងារសហប្រជាជាតិប្រឆាំងអំពើជួញដូរមនុស្ស (UNIAP) អង្គការមិត្តសំឡាញ់(Friend International) អង្គការអែដេទូស(Aide Détous) គណៈកម្មាធិការបំបាត់ពេស្យាចារ ការរំលោភ និងការជួញដូរកុមារនៅកម្ពុជា(ECPAT) អង្គការពលកម្មអន្តរជាតិ(ILO) អង្គការ Child Wise Australia និងអង្គការផ្សេងៗទៀតដែលប្រយុទ្ធប្រឆាំងនឹងទេសចរណ៍ផ្លូវភេទលើកុមារ ដើម្បីបង្កើតវគ្គបណ្តុះបណ្តាលកម្រិតថ្នាក់ជាតិ ថ្នាក់រាជធានី ខេត្ត និងថ្នាក់មូលដ្ឋានជូន

មន្ត្រីរាជការ នគរបាល កងរាជអាវុធហត្ថ អាជ្ញាធរដែនដី និយោជិត និយោជក នៅតាមបណ្តាមូលដ្ឋានអាជីវកម្ម សេវាកម្មទេសចរណ៍ ជូននិស្សិត សិស្សសាលា គ្រូបង្រៀន និងមាតាបិតាសិស្សនៅតាមសហគមន៍ ស្តីពីការលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ និងបានផ្សព្វផ្សាយដល់ប្រព័ន្ធឧស្សាហកម្មពាក់ព័ន្ធនឹងគោលនយោបាយទេសចរណ៍កម្ពុជា និងការចូលរួមចំណែកលើវិធានការទប់ស្កាត់ទាំងឡាយដែលត្រូវប្រកាន់យក និងបានពន្យល់អំពីរបៀបទាក់ទងមកក្រសួង ស្ថាប័នមានសមត្ថកិច្ច ដើម្បីជួយជនរងគ្រោះឲ្យទាន់ពេលវេលា និងចាត់វិធានការទៅតាមផ្លូវច្បាប់។ ឆ្នាំ២០០៧ គណៈកម្មាធិការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍របស់ក្រសួងទេសចរណ៍នៅរាជធានីភ្នំពេញ និងបណ្តាញទាំង២៤ រាជធានី ខេត្ត បានបណ្តុះបណ្តាលមនុស្សពេញវ័យបានចំនួន៥ ១៨៥នាក់និងកុមារចំនួន៥ ៩៧០នាក់។ ឆ្នាំ២០០៨ គណៈកម្មាធិការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការជាតិ អន្តរជាតិ បានធ្វើការបណ្តុះបណ្តាលមនុស្សពេញវ័យចំនួន២ ៣៩១នាក់ និងកុមារចំនួន៩៥៨នាក់។ ក្រៅពីការងារអប់រំនិងការបណ្តុះបណ្តាល បានផលិតសម្ភារៈអប់រំផ្សព្វផ្សាយដូចជា វីដេអូស្ប៉ត ស្លាកបិទ សៀវភៅតូចៗ ផ្ទាំងរូបភាពខ្នាតតូច ផ្ទាំងរូបភាពធំៗ សម្រាប់ចែកចាយនិងផ្សព្វផ្សាយតាមសហគមន៍ទេសចរណ៍ ទេសចរណ៍គោលដៅ រមណីយដ្ឋានទេសចរណ៍ និងនៅតាមរាជធានី ខេត្ត មួយចំនួន។

ចាប់ពីខែតុលា ឆ្នាំ២០០៩ ដល់ខែតុលា ឆ្នាំ២០១០ ដើម្បីរួមចំណែកទប់ស្កាត់ការជួញដូរមនុស្ស អគ្គស្នងការដ្ឋាននគរបាលជាតិបាន៖

- ធ្វើសម្ភាសន៍ពលរដ្ឋខ្មែរនិងជនបរទេសដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ចំនួន១ ២៣៧គូ និងសម្ភាសពលរដ្ឋខ្មែរតែម្ខាងចំនួន៥២៧នាក់
- ធ្វើសម្រង់ស្ថិតិនិងឲ្យម្ចាស់អាជីវកម្មដែលអាចពាក់ព័ន្ធនឹងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន១ ១៦១ គោលដៅចុះកិច្ចសន្យា
- ស្រង់ស្ថិតិទីភ្នាក់ងារជ្រើសរើសពលករខ្មែរទៅធ្វើការងារក្រៅប្រទេសបានចំនួន៦០គោលដៅ
- បង្ការទប់ស្កាត់សកម្មភាពប្រជាពលរដ្ឋខ្មែរធ្វើចំណាកស្រុកទៅរកការងារធ្វើនៅព្រះរាជាណាចក្រថៃ បានចំនួន៣០៣នាក់។

៣៦- ក្នុងរយៈពេលអនុវត្តវិធានការខាងលើ អគ្គស្នងការដ្ឋាននគរបាលជាតិបានបិទគោលដៅខារ៉ាអូខេ បញ្ចាំងវីដេអូនិងបញ្ចូលរូបភាពអាសអាភាសចំនួន១៣គោលដៅ និងកម្ទេចចោលវីស៊ីឌីអាសអាភាស ចំនួន២ ៣៤៥បន្ទះ។

៣៧- ក្រៅពីក្រសួង ស្ថាប័នដែលបានរៀបរាប់ខាងលើ នៅមានក្រសួង ស្ថាប័នដទៃទៀតរបស់រាជរដ្ឋាភិបាល ដែលបានសហការជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ រួមទាំងតំបន់ជាប់ព្រំដែនជាមួយប្រទេសជិតខាង បានធ្វើការផ្សព្វផ្សាយដើម្បីទប់ស្កាត់ លុបបំបាត់ការជួញដូរ និងប្រាប់ពីល្បិចកលរបស់ជនខិលខូច ក្នុងមជ្ឈដ្ឋានកងកម្លាំងប្រដាប់អាវុធនិងប្រជាជនតាមមូលដ្ឋាននៅទូទាំងប្រទេស។

## ការហាមឃាត់និងបញ្ហាពាក់ព័ន្ធ

ឆ្លើយតបនឹងមាត្រា៣ មាត្រា៤កថាខណ្ឌទី២និងទី៣ មាត្រា៥ មាត្រា៦ និងមាត្រា៧នៃពិធីសារបន្ថែម។

៣៨- ច្បាប់ព្រហ្មទណ្ឌជាធរមានដែលគ្របដណ្តប់និងកំណត់អំពើនិងសកម្មភាពទាក់ទងនឹងការលក់កុមារ អំពើជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ រួមមាន៖

១- ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទបានកំណត់បទប្បញ្ញត្តិព្រហ្មទណ្ឌគ្របដណ្តប់លើគ្រប់អំពើឬសកម្មភាពជាក់លាក់ដែលបានរៀបរាប់នៅក្នុងវាក្យខណ្ឌទី១ មាត្រា៣នៃពិធីសារនេះ។ បទប្បញ្ញត្តិព្រហ្មទណ្ឌដែលបានកំណត់នៅក្នុងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទទាក់ទងនឹងអំពើលក់ដូរកុមារ មានជាអាទិ៍៖

ក- យោងតាមច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ អំពើលក់ដូរមនុស្សមានន័យថា ការប្រគល់ឲ្យដោយខុសច្បាប់នូវការគ្រប់គ្រងលើអនីតិជនណាម្នាក់ទៅជនដទៃ ឬទទួលយកដោយខុសច្បាប់នូវការប្រគល់ ការគ្រប់គ្រងលើអនីតិជនណាម្នាក់ពីជនដទៃ ដោយផ្តោះប្តូរទៅនឹងរបស់មានតម្លៃអ្វីមួយដោយរាប់បញ្ចូលទាំងសេវានិងមនុស្សផង។ ចំពោះទម្រង់នៃការកេងប្រវ័ញ្ចផ្សេងទៀត ច្បាប់នេះបានកំណត់ជាអាទិ៍ ការកេងប្រវ័ញ្ចលើពេស្យាកម្មជនដទៃ រូបភាពនិងសម្ភារៈអាសអាភាស ពាណិជ្ជកម្មផ្លូវភេទ សេវាឬពលកម្មដោយបង្ខំ ទាសភាពឬការអនុវត្តស្រដៀងគ្នានឹងទាសភាព ការបញ្ចាំខ្លួនដោះបំណុល សេវាភាពដោយមិនស្ម័គ្រចិត្ត ពលកម្មកុមារ ឬការដកហូតសរីរាង្គ (កថាខណ្ឌ៣ មាត្រា១០)។

ខ- ការលក់ដូរមនុស្សត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២ឆ្នាំដល់៥ឆ្នាំ។

គ- ជនណាដែលនាំយកជនដទៃចេញដោយមិនស្របច្បាប់ក្នុងគោលដៅស្វែងរកប្រយោជន៍ឈ្លានពានខាងផ្លូវភេទ ផលិតរូបភាពអាសអាភាស រៀបអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ សុំកូនឬទម្រង់ណាមួយនៃការកេងប្រវ័ញ្ចផ្សេងទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧ឆ្នាំដល់១៥ឆ្នាំ។ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១៥ឆ្នាំដល់២០ឆ្នាំ ក្នុងករណីដែលជនរងគ្រោះជាអនីតិជន។

ឃ- ជនណាដែលលក់ដូរជនដទៃក្នុងគោលដៅប្រគល់ឬនាំយកទៅក្រៅព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧ឆ្នាំដល់១៥ឆ្នាំ។ ជនណាដែលលក់ដូរជនដទៃក្នុងប្រទេសណាមួយក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅប្រគល់ឬនាំយកជននោះទៅប្រទេសផ្សេងទៀតត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧ឆ្នាំដល់១៥ឆ្នាំ។ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១៥ឆ្នាំដល់២០ឆ្នាំ ក្នុងករណីដែលជនរងគ្រោះជាអនីតិជន។

២- ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ បានកំណត់បទប្បញ្ញត្តិព្រហ្មទណ្ឌដែលគ្របដណ្តប់លើគ្រប់អំពើឬសកម្មភាពជាក់លាក់ដែលបានរៀបរាប់នៅក្នុងវាក្យខណ្ឌទី១នៃមាត្រា៣នៃពិធីសារនេះ។ បទប្បញ្ញត្តិព្រហ្មទណ្ឌទាំងនោះ រួមមាន៖

ក- មាត្រា៣២១ចែងថា " អំពើរបស់បុគ្គលមានអំណាចថែរក្សា ដែលបោះបង់អនីតិជនអាយុតិចជាង១៥ឆ្នាំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ឆ្នាំទៅ៥ឆ្នាំ និងពិន័យជាប្រាក់ពី២ ០០០ ០០០ (ពីរលាន)រៀលទៅ១០ ០០០ ០០០(ដប់លាន)រៀល ប្រសិនបើអំពើបោះបង់នោះបណ្តាលឲ្យអន្តរាយដល់សុខភាពឬសន្តិសុខរបស់អនីតិជននោះ"។

ខ- មាត្រា៣២៦ ចែងថា " អំពើប្រព្រឹត្តដោយគំនិតទុច្ចរិត មិនព្រមប្រគល់អនីតិជនឲ្យទៅបុគ្គលដែលមានសិទ្ធិទាមទារនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ខែទៅ១ឆ្នាំ និងពិន័យជាប្រាក់ពី១០០ ០០០(មួយសែន)រៀលទៅ២ ០០០ ០០០(ពីរលាន)រៀល "។

គ- មាត្រា៣២៧ ចែងថា "អំពើដកយកអនីតិជនដោយផ្ទុយនឹងច្បាប់ ពីបុគ្គលដែលថែរក្សាស្របច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ខែទៅ១ឆ្នាំ និងពិន័យជាប្រាក់ពី១០០ ០០០(មួយសែន)រៀលទៅ២ ០០០ ០០០(ពីរលាន)រៀល។ បទល្មើសនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ឆ្នាំទៅ៣ឆ្នាំ និងពិន័យជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀលទៅ៦ ០០០ ០០០(ប្រាំមួយលាន)រៀល ប្រសិនបើអនីតិជនត្រូវបានរក្សាទុកនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា"។

ឃ- មាត្រា៣៣០ ចែងថា "អំពើនៅក្នុងគោលដៅចង់បានកម្រៃ ញុះញង់ដោយផ្ទាល់ដល់ឪពុកម្តាយ ឬដល់ឪពុក ឬដល់ម្តាយឲ្យបោះបង់ទារកដែលកើតមកហើយឬដែលនឹងកើត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ខែទៅ៦ខែ និងពិន័យជាប្រាក់ពី១០០ ០០០(មួយសែន)រៀលទៅ១ ០០០ ០០០(មួយលាន)រៀល"។

ង- មាត្រា៣៣១ ចែងថា "អំពើប្រព្រឹត្តនៅក្នុងគោលដៅចង់បានកម្រៃ ធ្វើជាអន្តរការីរវាងបុគ្គលម្នាក់ឬប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹម និងឪពុកម្តាយដែលចង់បោះបង់កូនដែលកើតមកហើយ ឬដែលនឹងកើត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ខែទៅ៦ខែ និងពិន័យជាប្រាក់ពី១០០ ០០០(មួយសែន)រៀលទៅ១ ០០០ ០០០(មួយលាន)រៀល "។

ច- មាត្រា៣៣២ ចែងថា "អំពើប្រព្រឹត្តនៅក្នុងគោលបំណងចង់បានកម្រៃ ធ្វើជាអន្តរការីរវាងបុគ្គលម្នាក់ឬប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមនិងស្ត្រីម្នាក់យល់ព្រមពពោះដើម្បីនឹងប្រគល់កូននោះឲ្យទៅអ្នកសុំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ខែទៅ៦ខែ និងពិន័យជាប្រាក់ពី១០០ ០០០(មួយសែន)រៀលទៅ១ ០០០ ០០០(មួយលាន)រៀល"។

ឆ- មាត្រា៣៣៣ ចែងថា " អំពើដែលយកទារកមួយជំនួសទារកមួយទៀត ក្លែងឬលាក់បំបាំងអត្តភាពនៃទារក កាលបើអំពើនេះនាំឲ្យមានការក្លែងបន្លំអត្រានុកូលដ្ឋាន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ខែទៅ១ឆ្នាំ និងពិន័យជាប្រាក់ពី១០០ ០០០(មួយសែន)រៀលទៅ២ ០០០ ០០០(ពីរលាន)រៀល "។

៣- ច្បាប់ស្តីពីសុំកូនអន្តរប្រទេស បញ្ញត្តហាមឃាត់នូវអំពើដែលចែងក្នុងមាត្រា៣៣០ មាត្រា៣៣១ និងមាត្រា៣៣២ នៃក្រមព្រហ្មទណ្ឌខាងលើ។ ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អាចព្យួរឬដកហូតការទទួលស្គាល់ ឬបដិសេធការទទួលស្គាល់ទីភ្នាក់ងារសុំកូនអន្តរប្រទេសសាជាថ្មី ប្រសិនបើមានភស្តុតាងបង្ហាញឲ្យឃើញថា ទីភ្នាក់ងារសុំកូនអន្តរប្រទេសរំលោភបំពានបទប្បញ្ញត្តិនៃមាត្រាទាំងបីនេះ។

៤- បទប្បញ្ញត្តិព្រហ្មទណ្ឌដែលបានកំណត់នៅក្នុងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទទាក់ទងនឹងការធ្វើពេស្យាកម្មកុមារ រួមមាន៖

ក- ច្បាប់នេះសន្មតថា ជនណាដែលរក្សាទុកអនីតិជនឲ្យស្ថិតនៅក្រោមការគ្រប់គ្រងឬការត្រួតពិនិត្យរបស់ខ្លួន នឹងត្រូវចាត់ទុកថាបានដឹងពីអាយុរបស់អនីតិជននោះ លើកលែងតែជននោះ

បង្ហាញឲ្យឃើញថាខ្លួនមានការជឿជាក់ដោយសមហេតុសមផលថា អនីតិជននោះមានអាយុ១៨ឆ្នាំឬច្រើនជាង១៨ឆ្នាំ។ អនីតិជននៅក្នុងច្បាប់នេះមានន័យថា ជាជនដែលមានអាយុក្រោម១៨ឆ្នាំ។

ខ- ការធ្វើពេស្យាកម្មលើកុមារត្រូវបានកំណត់ថាជាបទល្មើសនៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជាស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ។ អំពើពេស្យាចារកុមារ នៅក្នុងច្បាប់នេះមានន័យថាជាអំពើរួមភេទឬអំពើគ្រប់រូបភាពផ្សេងទៀតដែលទាក់ទងនឹងភេទរវាងអនីតិជនជាមួយជនដទៃ ដើម្បីផ្លោះប្តូរទៅនឹងវត្ថុមានតម្លៃអ្វីមួយ។ អំពើសញ្ចារកម្មនៅក្នុងច្បាប់នេះមានន័យថា ១- អំពើទាញយកប្រយោជន៍ហិរញ្ញវត្ថុពីអំពើពេស្យារបស់ជនដទៃ ២- អំពើជួយឬការពារអំពើពេស្យាចាររបស់អ្នកដទៃ ៣- អំពើជ្រើសរើស អូសទាញ ឬបណ្តុះបណ្តាលបុគ្គលណាមួយឲ្យធ្វើអំពើពេស្យាចារ ៤- អំពើធ្វើការគាបសង្កត់លើបុគ្គលណាមួយ ដើម្បីឲ្យបុគ្គលនោះធ្វើពេស្យាចារ។ បទប្បញ្ញត្តិទាក់ទងនឹងសញ្ចារកម្មនិងពេស្យាកម្ម ជាអាទិ៍៖

- មាត្រា២៧ចែងថា " ជនណាប្រព្រឹត្តសញ្ចារកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥ឆ្នាំទៅ១០ឆ្នាំ។ មាត្រា២៨ចែងថា "សញ្ចារកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧ឆ្នាំទៅ១៥ឆ្នាំ កាលបើបុគ្គលធ្វើពេស្យាចារនោះជាអនីតិជន "។

- មាត្រា៣៣ ចែងថា " ជនណាប្រព្រឹត្តបទល្មើសណាមួយដែលមានចែងក្នុងមាត្រា៣០(ការដឹកនាំពេស្យាចារ) មាត្រា៣១(ការដឹកនាំគ្រឹះស្ថានពេស្យាចារ) និងមាត្រា៣២(ការផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ)នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧ឆ្នាំទៅ១៥ឆ្នាំ បើបទល្មើសដែលបានប្រព្រឹត្តនោះទាក់ទងនឹងពេស្យាចារកុមារ"។

- មាត្រា៣៥ចែងថា "ជនណាអូសទាញជនដទៃសម្រាប់អំពើពេស្យាចារកុមារឬផ្សាយពាណិជ្ជកម្មពីអំពើពេស្យាចារកុមារ ក្នុងគោលដៅធ្វើជាអន្តរការីនៃអំពើពេស្យាចារកុមារនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២ឆ្នាំដល់៥ឆ្នាំ និងពិន័យជាប្រាក់ពី៤ ០០០ ០០០(បួនលាន)រៀលដល់១០ ០០០ ០០០(ដប់លាន)រៀល។ ជនណាប្រព្រឹត្តបទល្មើសខាងលើ ធ្វើជាមុខរបរ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥ឆ្នាំដល់១០ឆ្នាំ "។

- មាត្រា៣៦ចែងថា "ជនណាឲ្យជនដទៃខ្ចីប្រាក់ឬវត្ថុមានតម្លៃអ្វីមួយដោយភ្ជាប់ទៅនឹងលក្ខខណ្ឌដែលតម្រូវឲ្យអនីតិជនប្រកបរបរពេស្យាចារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥ឆ្នាំដល់១០ឆ្នាំ។ ជនណាឲ្យអនីតិជនខ្ចីប្រាក់ឬវត្ថុមានតម្លៃអ្វីមួយដោយភ្ជាប់ទៅនឹងលក្ខខណ្ឌដែលតម្រូវឲ្យអនីតិជននោះប្រកបរបរពេស្យាចារត្រូវផ្តន្ទាទោសដូចគ្នានឹងកថាខណ្ឌទី១នៃមាត្រានេះ "។

- មាត្រា៣៧ចែងថា " ជនណាធ្វើកិច្ចសន្យាជាមួយជនដទៃដែលក្នុងកិច្ចសន្យានោះតម្រូវឲ្យអនីតិជនប្រកបរបរពេស្យាចារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥ឆ្នាំដល់១០ឆ្នាំ។ ជនណាធ្វើកិច្ចសន្យាជាមួយអនីតិជន ដែលក្នុងកិច្ចសន្យានោះតម្រូវឲ្យអនីតិជនប្រកបរបរពេស្យាចារត្រូវផ្តន្ទាទោសដូចគ្នានឹងកថាខណ្ឌទី១នៃមាត្រានេះ "។

៥- ការធ្វើពេស្យាកម្មក៏ត្រូវបានកំណត់ថាជាបទល្មើសនៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាផងដែរ។ បទប្បញ្ញត្តិព្រហ្មទណ្ឌទាំងនោះរួមមាន៖

- មាត្រា២៨៤ចែងថា " សញ្ចារកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២ឆ្នាំទៅ៥ឆ្នាំ និងពិន័យជាប្រាក់ពី៤ ០០០ ០០០(បួនលាន)រៀលទៅ១០ ០០០ ០០០(ដប់លាន)រៀល "។

- មាត្រា២៨៥ចែងថា " អំពើធ្វើជាអន្តរការីរវាងបុរសឬស្ត្រីពេស្យានិងសញ្ចារិកឬសញ្ចារិកាត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២ឆ្នាំទៅ៥ឆ្នាំ និងពិន័យជាប្រាក់ពី៤ ០០០ ០០០(បួនលាន)រៀលទៅ១០ ០០០ ០០០(ដប់លាន)រៀល "។

- មាត្រា២៨៦ចែងថា " អំពើរបស់ជនណាដែលបានជួយសម្រួលឬបិទបាំងនូវធនធានដែលខ្លួនបានដឹងថាបានមកពីអំពើសញ្ចារកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២ឆ្នាំទៅ៥ឆ្នាំ និងពិន័យជាប្រាក់ពី៤ ០០០ ០០០(បួនលាន)រៀលទៅ១០ ០០០ ០០០(ដប់លាន)រៀល។ ត្រូវផ្តន្ទាទោសដូចគ្នាផងដែរ ចំពោះបុគ្គលដែលមិនអាចបញ្ជាក់អំពីប្រភពធនធានរបស់ខ្លួន ដោយរស់នៅជាមួយជនដែលធ្វើសកម្មភាពពេស្យាចារជាប្រចាំឬដោយសារមានទំនាក់ទំនងជាទម្លាប់ជាមួយជនម្នាក់ឬច្រើននាក់ដែលធ្វើសកម្មភាពពេស្យាចារ "។

- មាត្រា២៨៧ចែងថា " អំពើរាំងដល់ការបង្ការ ការជួយ ឬការអប់រំជាថ្មី ដោយសេវាសាធារណៈ ឬដោយអង្គការឯកជនដែលមាននីតិសម្បទា ដែលធ្វើឡើងដើម្បីអនុគ្រោះដល់បុគ្គលដែលប្រព្រឹត្តពេស្យាចារឬកំពុងមានគ្រោះថ្នាក់ដោយការធ្វើពេស្យាចារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២ឆ្នាំទៅ៥ឆ្នាំ និងពិន័យជាប្រាក់ពី៤ ០០០ ០០០(បួនលាន)រៀលទៅ១០ ០០០ ០០០(ដប់លាន)រៀល"។

- មាត្រា២៨៩និងមាត្រា២៩០នៃក្រមព្រហ្មទណ្ឌកំណត់ពីស្ថានទម្ងន់ទោសថា សញ្ចារកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧ឆ្នាំទៅ១៥ឆ្នាំ កាលបើបុគ្គលដែលធ្វើពេស្យាចារនោះ ជាអនីតិជននិងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១០ឆ្នាំទៅ២០ឆ្នាំ កាលបើសញ្ចារិក សញ្ចារិកា ឬជនជាមេពេស្យាបានប្រើប្រាស់ទារុណកម្មឬអំពើឃោរឃៅចំពោះបុគ្គលដែលធ្វើពេស្យាចារ។

- មាត្រា២៩១ចែងថា " អំពើគ្រប់គ្រង ធ្វើអាជីវកម្ម ដឹកនាំ ធ្វើឲ្យដំណើរការ ឬចេញប្រាក់ឲ្យគ្រឹះស្ថានពេស្យាចារដោយផ្ទាល់ឬតាមរយៈអន្តរការី ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២ឆ្នាំទៅ៥ឆ្នាំ និងពិន័យជាប្រាក់ពី៤ ០០០ ០០០(បួនលាន)រៀលទៅ១០ ០០០ ០០០(ដប់លាន)រៀល "។

- មាត្រា២៩២ចែងថា " ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២ឆ្នាំទៅ៥ឆ្នាំ និងពិន័យជាប្រាក់ពី៤ ០០០ ០០០(បួនលាន)រៀលទៅ១០ ០០០ ០០០(ដប់លាន)រៀល អំពើរបស់អ្នកដែលគ្រប់គ្រង ធ្វើអាជីវកម្ម ដឹកនាំ ឬធ្វើឲ្យដំណើរការនូវគ្រឹះស្ថានណាមួយដែលបើកចំហដល់សាធារណជនដោយផ្ទាល់ឬតាមរយៈអន្តរការីដែលបានយល់ព្រមឬបានអនុគ្រោះ ៖

១- ឲ្យបុគ្គលណាម្នាក់ប្រព្រឹត្តជាប្រចាំនូវពេស្យាចារនៅក្នុងគ្រឹះស្ថានឬនៅក្នុងឧបសម្ព័ន្ធរបស់គ្រឹះស្ថាន។

២- ឲ្យបុគ្គលណាម្នាក់រកជាប្រចាំនូវភ្ញៀវដើម្បីធ្វើពេស្យាចារនៅក្នុងគ្រឹះស្ថានឬនៅក្នុងឧបសម្ព័ន្ធរបស់គ្រឹះស្ថាន "។

- មាត្រា២៩៣ចែងថា " ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២ឆ្នាំទៅ៥ឆ្នាំ និងពិន័យជាប្រាក់ពី

៤ ០០០ ០០០(បួនលាន)រៀលទៅ១០ ០០០ ០០០(ដប់លាន)រៀល ចំពោះបុគ្គលដែលលក់ឬដាក់ឲ្យបុគ្គលណាម្នាក់ប្រើប្រាស់ទីកន្លែងដែលមិនមែនប្រើប្រាស់ដោយសាធារណជន ដោយដឹងជាក់ច្បាស់ថាបុគ្គលនោះនឹងប្រើប្រាស់ទីកន្លែងនោះសម្រាប់ធ្វើសកម្មភាពពេស្យាចារ ”។

៦- បទប្បញ្ញត្តិព្រហ្មទណ្ឌ ដែលបានកំណត់នៅក្នុងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទទាក់ទងនឹងរូបភាពអាសអាភាសកុមារ រួមមាន៖

- មាត្រា៤១ចែងថា “ ជនណាចែកចាយ លក់ ជួល ដាក់តាំង បញ្ចាំង ឬបង្ហាញនៅទីសាធារណៈនូវរូបភាពនិងសម្ភារៈអាសអាភាសនៃកុមារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២ឆ្នាំដល់៥ឆ្នាំ និងពិន័យជាប្រាក់ពី៤ ០០០ ០០០(បួនលាន)រៀលដល់១០ ០០០ ០០០(ដប់លាន)រៀល។ ជនណាកាន់កាប់ ដឹកជញ្ជូន នាំចូល ឬនាំចេញនូវរូបភាពនិងសម្ភារៈអាសអាភាសនៃកុមារក្នុងគោលដៅយកទៅប្រើប្រាស់នៅក្នុងការប្រព្រឹត្តបទល្មើស ដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើ ត្រូវផ្តន្ទាទោសដូចគ្នា។ ជនណាផលិតរូបភាពនិងសម្ភារៈអាសអាភាសនៃកុមារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥ឆ្នាំ ដល់ ១០ឆ្នាំ។ ជនណាផលិតរូបភាពនិងសម្ភារៈអាសអាភាសនៃកុមារក្នុងគោលដៅយកទៅប្រើប្រាស់ នៅក្នុងការប្រព្រឹត្តបទល្មើសណាមួយដូចមានចែងក្នុងកថាខណ្ឌទី១និងទី២ខាងលើ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១០ឆ្នាំដល់២០ឆ្នាំ ”។

៣៩- ស្ថានសម្រាលទោសត្រូវអនុវត្តទៅលើអនីតិជនទាំងអស់ដែលមានអាយុក្រោម១៨ឆ្នាំ។ ទោសដែលប្រកាសពីបទឧក្រិដ្ឋមានអាជ្ញាយុកាល២០ឆ្នាំ និងទោសដែលប្រកាសពីបទមជ្ឈិមមានអាជ្ញាយុកាល ០៥ឆ្នាំ។ នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវបានកំណត់អាយុចាប់ពី១៨ឆ្នាំឡើងទៅ។ អាយុអប្បបរមាដែលអាចទទួលខុសត្រូវព្រហ្មទណ្ឌគឺអាយុ១៤ឆ្នាំ។ មូលហេតុនៃការមិនទទួលខុសត្រូវឬការសម្រាលនូវការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវអនុវត្តទៅតាមវិធានទូទៅនៃក្រមព្រហ្មទណ្ឌ។ ក្រៅពីកាលៈទេសៈនៃបទល្មើសឬបុគ្គលិកលក្ខណៈនៃជនជាប់ចោទតម្រូវ មិនមានបទប្បញ្ញត្តិពិសេសទាក់ទងនឹងស្ថានសម្រាលនិងមធ្យោបាយការពារខ្លួនចំពោះអំពើលក់ដូរអនីតិជន ការទិញពេស្យាចារកុមារ និងបទល្មើសផ្សេងៗទៀតទាក់ទងនឹងរូបភាពនិងសម្ភារៈអាសអាភាសនៃកុមារទេ។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ កំពុងពិនិត្យឡើងវិញនូវក្របខ័ណ្ឌច្បាប់ទាក់ទងនឹងការការពារកុមារ។

៤០- ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ កំណត់នូវវិធានស្តីពីសុំកូនធម្មតានិងសុំកូនពេញលេញនៅក្នុងប្រទេស។ សុំកូនពេញលេញ សំដៅដល់សុំកូនដែលមានអានុភាពបង្កើតនូវទំនាក់ទំនងអចិន្ត្រៃយ៍ជាឪពុកម្តាយនិងកូនរវាងឪពុកម្តាយចិញ្ចឹម ឬឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹមនិងកូនសុំ និងបញ្ចប់សិទ្ធិនិងកាតព្វកិច្ចរវាងកូននិងឪពុកម្តាយបង្កើតឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់ខ្លួន។ ចំពោះសុំកូនធម្មតាញាតិភាពរវាងកូនសុំនិងឪពុកម្តាយបង្កើតត្រូវបន្តអត្ថិភាព ហើយកូនសុំនិងឪពុកម្តាយបង្កើតមានសិទ្ធិធ្វើសន្តតិកម្មគ្នាទៅវិញទៅមក មានសិទ្ធិទាមទារនិងករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច។

៤១- ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារនិងកិច្ចសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេសនៅឆ្នាំ២០០៧។

៤២- ក្រៅពីចូលជាភាគីអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារនិងកិច្ចសហប្រតិបត្តិការទាក់ទងនឹង

ស្មុំកូនអន្តរប្រទេស ព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខាលើសន្ធិសញ្ញាទ្វេភាគីជាមួយសាធារណរដ្ឋបារាំងនិងអ៊ីតាលីដើម្បីធ្វើសហប្រតិបត្តិការលើវិស័យស្មុំកូនអន្តរប្រទេស។ គោលនយោបាយជាតិស្តីពីការថែទាំជំនួសចំពោះកុមារ កំណត់អំពីប្រភេទផ្សេងៗគ្នានៃការថែទាំជំនួសចំពោះកុមារដែលមិនបានទទួលការថែទាំដោយឪពុកម្តាយបង្កើត ហើយកំណត់គោលការណ៍នៃការថែទាំជំនួស។ រាជរដ្ឋាភិបាលកំណត់ថា ការថែទាំតាមមណ្ឌលនិងស្មុំកូនអន្តរប្រទេសគឺជាជម្រើសចុងក្រោយ។ គោលនយោបាយនេះមានទិសដៅធានាឲ្យកុមារបានរីកចម្រើនលូតលាស់នៅក្នុងក្រុមគ្រួសារនិងនៅក្នុងសហគមន៍ ពិសេសក្នុងគ្រួសារបង្កើតនិងសហគមន៍ជាកន្លែងដើមឬស្រុកកំណើត ធានាឲ្យកុមារមានលទ្ធភាពទទួលបានសេវាសុខភាព សេវាអប់រំដោយឥតគិតថ្លៃ និងការគាំទ្រផ្លូវចិត្តដើម្បីឲ្យកុមារអាចរស់រាននិងអភិវឌ្ឍ និងបង្កើនសមត្ថភាពសហគមន៍ក្នុងការថែទាំនិងការការពារកុមារងាយរងគ្រោះតាមរយៈការលើកស្ទួយនិងពង្រឹងបណ្តាញសុវត្ថិភាពទាំងអស់របស់សហគមន៍។

៤៣- កថាខណ្ឌ៧នៃមាត្រា៥នៃច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស បញ្ញត្តថា អាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធនឹងនីតិវិធីស្មុំកូនអន្តរប្រទេសត្រូវធានាថា ដំណើរការស្មុំកូនអន្តរប្រទេសមិនបណ្តាលឲ្យមានការទទួលផលកម្រៃផ្នែកហិរញ្ញវត្ថុដោយមិនស្របច្បាប់ និងត្រូវបង្ការមិនឲ្យមានការចាប់ពង្រត់ ការលក់ និងការជួញដូរកុមារក្នុងពេលកំពុងដំណើរការស្មុំកូនអន្តរប្រទេស។ មានតែប្រាក់ចំណាយលើសោហ៊ុយនិងវិភាគទានដែលកំណត់ដោយបទប្បញ្ញត្តិនៃច្បាប់នេះទេដែលត្រូវបង់។ ដើម្បីការពារសិទ្ធិជាមូលដ្ឋានរបស់កុមារដែលជាកម្មវត្ថុនៃស្មុំកូនអន្តរប្រទេស ច្បាប់នេះកំណត់នូវវិធានដូចខាងក្រោម៖

(ក) ការបង្ការស្មុំកូនខុសច្បាប់ មានតែទីភ្នាក់ងារដែលបានទទួលការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចនៃព្រះរាជាណាចក្រកម្ពុជានិងពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសទទួលប៉ុណ្ណោះ ដែលមានសិទ្ធិធ្វើប្រតិបត្តិការក្នុងនីតិវិធីស្មុំកូនអន្តរប្រទេស។ ចំនួនទីភ្នាក់ងារមកពីប្រទេសទទួលនីមួយៗ ដែលអនុញ្ញាតឲ្យផ្តល់សេវានៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវកំណត់ដោយកិច្ចព្រមព្រៀងមួយរវាងក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចនិងអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទទួល។

(ខ) ការបញ្ចុះបញ្ចូលម្តាយឬស្ត្រីមានផ្ទៃពោះឲ្យផ្តល់កូនរបស់ខ្លួនសម្រាប់ធ្វើជាកម្មវត្ថុនៃការស្មុំ និងការផ្សព្វផ្សាយពាណិជ្ជកម្មសេវាស្មុំកូន ត្រូវបានហាមឃាត់។ អំពើញុះញង់ដល់ឪពុកម្តាយ ឬដល់ឪពុក ឬដល់ម្តាយឲ្យបោះបង់ទារកដែលកើតមកហើយឬដែលនឹងកើត ត្រូវបានហាមឃាត់។ អំពើធ្វើជាអន្តរការីរវាងបុគ្គលម្នាក់ឬប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹម និងឪពុកម្តាយដែលចង់បោះបង់កូនដែលកើតមកហើយឬដែលនឹងកើត ត្រូវបានហាមឃាត់។ អំពើធ្វើជាអន្តរការីរវាងបុគ្គលម្នាក់ឬប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹម និងស្ត្រីម្នាក់យល់ព្រមពពោះដើម្បីនឹងប្រគល់កូននោះឲ្យទៅអ្នកសុំ ត្រូវបានហាមឃាត់។ ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចអាចព្យួរ ដកហូត ឬបដិសេធការទទួលស្គាល់ទីភ្នាក់ងារស្មុំកូនអន្តរប្រទេសសាជាថ្មី ចំពោះទីភ្នាក់ងារស្មុំកូនអន្តរប្រទេស ដែលធ្វើការផ្សាយពាណិជ្ជកម្មឬការបោះពុម្ពផ្សាយនូវអត្តសញ្ញាណឬរូបថតរបស់កុមារណាមួយដែលជាកម្មវត្ថុស្មុំកូន ក្នុងគោលបំណងបញ្ចុះបញ្ចូលបុគ្គលណាមួយឲ្យដាក់ពាក្យសុំកូន។

(គ) មានតែទីភ្នាក់ងារដែលបានទទួលការអនុញ្ញាតត្រឹមត្រូវប៉ុណ្ណោះ ដែលមានសិទ្ធិធ្វើប្រតិបត្តិការក្នុងនីតិវិធីសុំកូនអន្តរប្រទេស។

(ឃ) ការលួចកុមារតូចនិងការក្លែងបន្លំការចុះបញ្ជីកំណើត ត្រូវផ្តន្ទាទោសដោយបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ។ អំពើដកយកអនីតិជនដោយផ្ទុយនឹងច្បាប់ ពីបុគ្គលដែលថែរក្សាស្របច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ខែទៅ១ឆ្នាំ។ អំពើដែលយកទារកមួយជំនួសទារកមួយទៀត ក្លែង ឬលាក់បំបាំងអត្តិភាពនៃទារក កាលបើអំពើនេះនាំឲ្យមានការក្លែងបន្លំអត្រានុកូលដ្ឋាន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ខែទៅ១ឆ្នាំ។

(ង) ដំណើរការសុំកូនអាចប្រព្រឹត្តទៅបាន លុះត្រាតែមានការយល់ព្រមរបស់ឪពុកម្តាយ ឬឪពុក ឬម្តាយដោយសេរីនិងច្បាស់លាស់ដោយមិនត្រូវមានវិការៈ។ ឪពុកម្តាយ ឬឪពុក ឬម្តាយរបស់កុមារត្រូវទទួលនូវការពិគ្រោះយោបល់ពីភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ចដែលបានទទួលការអនុញ្ញាតជាមុនសិន មុននឹងផ្តល់ការយល់ព្រម។ ក្នុងករណីដែលឪពុកម្តាយរបស់កុមារបានស្លាប់ ឬស្ថិតនៅក្នុងស្ថានភាពដែលមិនអាចបង្ហាញឆន្ទៈបាន ឬត្រូវបានដកហូតអំណាចមេបា ការយល់ព្រមត្រូវផ្តល់ដោយអ្នកអាណាព្យាបាលរបស់កុមារនោះ។ អ្នកអនុវត្តអំណាចមេបាដែលស្ថិតនៅក្នុងស្ថានភាពលំបាកបំផុត អាចធ្វើការទុកដាក់កុមារឲ្យនៅក្រោមការថែទាំរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចនោះ។ ក្នុងករណីនេះ ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចជាអ្នកអាណាព្យាបាលរបស់កុមារដែលត្រូវបានប្រគល់មកក្រសួងយោងតាមអំណាចនៃដីកាសម្រេចរបស់តុលាការ។ ការយល់ព្រមលើសុំកូនដែលត្រូវបានផ្តល់ដោយអ្នកអនុវត្តអំណាចមេបាត្រូវធ្វើនៅចំពោះមុខមេឃុំ ចៅសង្កាត់ និងត្រូវពិនិត្យផ្ទៀងផ្ទាត់ដោយតុលាការ។

(ច) ច្បាប់ស្តីពីសុំកូនអន្តរប្រទេសកំណត់អំពីគោលការណ៍មួយចំនួនទាក់ទងនឹងប្រាក់ចំណាយសោហ៊ុយ និងវិភាគទាននានាទាក់ទងនឹងសុំកូនអន្តរប្រទេស ដែលនឹងត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច។

៩៤- ការផលិតនិងការផ្សព្វផ្សាយសម្ភារៈដែលផ្សាយពាណិជ្ជកម្មអំពីបទល្មើស ដែលមានកំណត់ក្នុងពិធីសារជាពិសេស រូបភាពនិងសម្ភារៈអាសអាភាសនៃកុមារ ត្រូវបានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ កំណត់ថាជាបទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២ឆ្នាំដល់៥ឆ្នាំ និងពិន័យជាប្រាក់ពី៤លានរៀលដល់១០លានរៀល។ អំពើអូសទាញឬផ្សព្វផ្សាយពាណិជ្ជកម្មនូវអំពើពេស្យាចារកុមារត្រូវផ្តន្ទាទោសដូចគ្នា។

៩៥- រាជរដ្ឋាភិបាលបានចេញគោលការណ៍និងវិធានការដើម្បីបង្ក្រាប ទប់ស្កាត់ការផ្សព្វផ្សាយរូបភាពអាសអាភាសរបស់ស្ត្រីនិងកុមារ រួមមាន៖

- ការអនុវត្តច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ
- ការអនុវត្តច្បាប់ស្តីពីរបបសារព័ត៌មាន
- វិធានការបង្ហាក់ Internet IP ដែលអាចបញ្ជូនរូបភាពអាសអាភាស

- ការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យនិងចាត់វិធានការបង្ក្រាបការបញ្ចាំងវីដេអូអាសអាភាស ការលក់ ការជួលស្នាដៃភាពយន្តនិងស្នាដៃវីដេអូអាសអាភាស ដែលគ្មានទិដ្ឋាការគ្រប់ប្រភេទ
- ក្រសួងនីមួយៗត្រូវណែនាំនិងអប់រំមន្ត្រីរាជការកុំឲ្យមើលឬផ្សព្វផ្សាយរូបភាពអាសអាភាស
- រៀបចំយុទ្ធនាការអប់រំយុវវ័យនិងសង្គមដោយសហការជាមួយគ្រប់ក្រសួងពាក់ព័ន្ធ។

ការកេងប្រវ័ញ្ចផ្លូវភេទនិងរូបភាពអាសអាភាសមាន១១ភាគរយនៃបទល្មើសផ្លូវភេទក្នុងឆ្នាំ២០០៩។ ក្នុងឆ្នាំ២០០៩ បទល្មើសទាក់ទងនឹងរូបភាពនិងសម្ភារៈអាសអាភាសចំនួន២១ករណីត្រូវបានបង្ក្រាបហើយជនល្មើសចំនួន១៥នាក់ ត្រូវបានចាប់ខ្លួនដោយនាយកដ្ឋានប្រឆាំងការជួញដូរនិងការពារអនីតិជន។

៤៦- ការធ្វើបត្យាប័នបុគ្គលដែលត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តបទល្មើសដែលមានកំណត់នៅក្នុងពិធីសារ និងបទល្មើសព្រហ្មទណ្ឌផ្សេងៗទៀត ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌទាក់ទងនឹងការធ្វើបត្យាប័ន។ បត្យាប័នអាណិកជនបរទេសដែលត្រូវបានចាប់ខ្លួននៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានគ្រប់គ្រងដោយបទប្បញ្ញត្តិនៃសន្ធិសញ្ញានិងអនុសញ្ញាអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័ន។ ក្នុងករណីគ្មានសន្ធិសញ្ញាឬអនុសញ្ញាអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នទេនោះ បទប្បញ្ញត្តិនៃជំពូកស្តីពីបត្យាប័ននៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌត្រូវយកមកអនុវត្ត លើកលែងតែមានបញ្ញត្តពិសេសនៅក្នុងច្បាប់ផ្សេងទៀត។ បត្យាប័នអាចធ្វើទៅបាន លុះត្រាតែអំពើដែលត្រូវចោទប្រកាន់លើបុគ្គលដែលគេទាមទារនោះ ជាបទល្មើសតាមច្បាប់របស់រដ្ឋធ្វើសំណើផងនិងតាមច្បាប់ព្រះរាជាណាចក្រកម្ពុជាផង។ គ្រប់ពាក្យសុំធ្វើបត្យាប័នត្រូវតែជូនចំពោះរាជរដ្ឋាភិបាលកម្ពុជាតាមផ្លូវទូត។ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជាបញ្ជូនពាក្យសុំឲ្យធ្វើបត្យាប័ននិងលិខិតបញ្ជាក់ភស្តុតាងទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ផ្ទៀងផ្ទាត់មើលនិយតភាពនៃពាក្យសុំ និងបញ្ជូនពាក្យនោះទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ។ សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញជាអង្គការតែមួយគត់ដែលមានសមត្ថកិច្ច ដើម្បីពិចារណាលើនិយតភាពនៃបត្យាប័នដែលរាជរដ្ឋាភិបាលកម្ពុជាបានទទួល។ មាត្រា៣៣នៃរដ្ឋធម្មនុញ្ញចែងថា "ប្រជាពលរដ្ឋខ្មែរមិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬចាប់បញ្ជូនខ្លួនទៅឲ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក"។ រហូតដល់ពេលនេះ ព្រះរាជាណាចក្រកម្ពុជាបានចុះសន្ធិសញ្ញាបត្យាប័នជាមួយនឹងព្រះរាជាណាចក្រថៃ(ចុះហត្ថលេខានៅបាងកកថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៩៨) ជាមួយសាធារណរដ្ឋប្រជាមានិតចិន(ចុះហត្ថលេខានៅប៉េកាំងថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ១៩៩៩) ជាមួយសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ(ចុះហត្ថលេខានៅវៀងចន្ទន៍ ថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៩៩) និងជាមួយសាធារណរដ្ឋកូរ៉េ (ចុះហត្ថលេខានៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៩)។

៤៧- កន្លងមកនេះ អាជ្ញាធរព្រះរាជាណាចក្រកម្ពុជាបានចាប់បញ្ជូនជនបរទេសមួយចំនួនដែលបានចូលមកព្រះរាជាណាចក្រកម្ពុជា ហើយបានប្រព្រឹត្តបទល្មើស មានជាអាទិ៍៖

- ឆ្នាំ២០០៩ ឃាត់ខ្លួនជនសង្ស័យជាជនបរទេស បញ្ជូនទៅសាលាដំបូងបានចំនួន៣២នាក់ ក្នុងនោះសញ្ជាតិបារាំង០៧នាក់ អាមេរិក០៦នាក់ កូរ៉េ០៣នាក់ ចិន០៣នាក់ កាណាដា០២នាក់ ថៃ០២នាក់ អង់គ្លេស០២នាក់ អាល្លឺម៉ង់០១នាក់ ក្រិច០១នាក់ ស៊ុយអែត០១នាក់ ស្វ៊ីស០១នាក់ ជប៉ុន០១នាក់ ដាណឺម៉ាក០១នាក់ និងអ៊ីស្រាអែល០១នាក់។

- ក្នុងឆ្នាំ២០០៩ ព្រះរាជាណាចក្រកម្ពុជាបានធ្វើបត្យាប័ននូវជនជាតិអូស្ត្រាលី០១នាក់ដែលបានប្រព្រឹត្តអំពើបំពារបំពានផ្លូវភេទលើកុមារ ហើយបានគេចខ្លួនចូលមកព្រះរាជាណាចក្រកម្ពុជាក្នុងនាមជាអ្នកទេសចរ។ ជននេះត្រូវបានអាជ្ញាធរអូស្ត្រាលីចោទប្រកាន់ពីបទប្រព្រឹត្តអំពើអាសលើកុមារដែលប្រឆាំងនឹងច្បាប់របស់ប្រទេសអូស្ត្រាលី។ ជននេះបានរត់គេចចូលមកលាក់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អាជ្ញាធរអូស្ត្រាលីបានស្នើសុំឲ្យអាជ្ញាធរព្រះរាជាណាចក្រកម្ពុជាចាប់ខ្លួន និងសុំឲ្យធ្វើបត្យាប័នដើម្បីយកទៅផ្តន្ទាទោសតាមច្បាប់អូស្ត្រាលី ប៉ុន្តែពេលនោះ ព្រះរាជាណាចក្រកម្ពុជានិងអូស្ត្រាលីពុំទាន់មានសន្ធិសញ្ញាបត្យាប័នជាមួយនឹងគ្នានៅឡើយ។ អនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ អាជ្ញាធរព្រះរាជាណាចក្រកម្ពុជាបានធ្វើបត្យាប័នជនល្មើសនេះទៅឲ្យអាជ្ញាធរអូស្ត្រាលីបាន។ ថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៩ អាជ្ញាធរព្រះរាជាណាចក្រកម្ពុជា បានប្រគល់ជនល្មើសឲ្យអាជ្ញាធរអូស្ត្រាលី។

- ឆ្នាំ២០០៨ អគ្គស្នងការដ្ឋាននគរបាលជាតិ ក៏ដូចជាកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានបន្តយកចិត្តទុកដាក់ជំរុញឲ្យនាយកដ្ឋានជំនាញ ស្នងការដ្ឋាននគរបាល និងកងរាជអាវុធហត្ថរាជធានី ខេត្ត ខិតខំតាមដាន ស្រាវជ្រាវ ឃាត់ខ្លួនជនសង្ស័យជាជនបរទេសបញ្ជូនទៅតុលាការ បានចំនួន ១១នាក់ ក្នុងនោះសញ្ជាតិអាមេរិក០៤នាក់ រុស្ស៊ី០១នាក់ អ៊ីតាលី០១នាក់ បារាំង០២នាក់ ជប៉ុន០១នាក់ ស៊ុយអែត០១នាក់ និងអង់គ្លេស០១នាក់ ដោយបញ្ជូនចេញពីព្រះរាជាណាចក្រកម្ពុជា។

៤៨- ចាប់តាំងពីពិធីសារបានចូលជាធរមានរួចមក ព្រះរាជាណាចក្រកម្ពុជាពុំធ្លាប់បដិសេធសំណើសុំធ្វើបត្យាប័នបុគ្គលណាម្នាក់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដែលបុគ្គលនោះត្រូវបានចោទប្រកាន់ដោយរដ្ឋដទៃទៀតថាបានប្រព្រឹត្តបទល្មើសណាមួយដែលកំណត់នៅក្នុងពិធីសារនេះទេ។ ព្រះរាជាណាចក្រកម្ពុជាពុំធ្លាប់បានស្នើសុំធ្វើបត្យាប័នជនណាម្នាក់ដែលត្រូវបានចោទប្រកាន់ពីបទល្មើសណាមួយនៅក្នុងពិធីសារនេះមកព្រះរាជាណាចក្រកម្ពុជាឡើយ។

៤៩- ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ សភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ បានបើកសវនាការ សម្រេចតាមសាលដីកាលេខ៣៤ឈ/២៤ កក្កដា ២០០៩ យល់ព្រមឲ្យធ្វើបត្យាប័នជនជាតិអូស្ត្រាលី០១នាក់ដែលបានប្រព្រឹត្តអំពើអាសអាភាសលើកុមារទៅប្រទេសអូស្ត្រាលីវិញ។

៥០- ក្រៅពីសន្ធិសញ្ញាបត្យាប័ន ព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខាលើសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ នៅខែវិច្ឆិកា ឆ្នាំ២០០៤ ក្នុងក្របខ័ណ្ឌអាស៊ាន ដើម្បីជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌដូចជា ការស៊ើបអង្កេត ការចោទប្រកាន់ និងដំណើរការរឿងក្តី។ ក្រៅពីនេះ ព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងទ្វេភាគី តំបន់ ឬពហុភាគីដូចជា៖

- កិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការអាស៊ានលើវិស័យទេសចរណ៍ បញ្ញត្តិស្តីពីវិធានការត្រូវធ្វើដើម្បីជៀសវាងការរំលោភណាមួយក្នុងវិស័យទេសចរណ៍ទៅលើមរតកវប្បធម៌និងធនធានធម្មជាតិនៃប្រទេសក្នុងតំបន់ ជាពិសេសការកេងប្រវ័ញ្ចលើស្ត្រីនិងកុមារ ក្នុងអំឡុងពេលកិច្ចប្រជុំកំពូលអាស៊ានលើកទី៨ នៅរាជធានីភ្នំពេញ ថ្ងៃទី៤និងទី៥ ខែវិច្ឆិកា ឆ្នាំ២០០២។

- អនុស្សរណៈយោគយល់គ្នាលើកិច្ចសហប្រតិបត្តិការមួយរវាងប្រទេសមហាអនុតំបន់មេគង្គ ដែលអនុវត្តកម្មវិធីស្តីពីការសម្របសម្រួលគំនិតផ្តួចផ្តើមថ្នាក់រដ្ឋមន្ត្រីប្រឆាំងអំពើជួញដូរមនុស្ស (COMMIT) ដើម្បីឆ្លើយតបទៅនឹងការជួញដូរមនុស្ស។

- អនុស្សរណៈយោគយល់គ្នារវាងព្រះរាជាណាចក្រកម្ពុជានិងថៃនៅខែឧសភា ឆ្នាំ២០០៣ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីដើម្បីលុបបំបាត់ការជួញដូរស្ត្រីនិងកុមារនិងជួយដល់ជនរងគ្រោះដោយសារការជួញដូរ។

- កិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋសង្គមនិយមវៀតណាម នៅខែតុលា ឆ្នាំ២០០៥ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីដើម្បីលុបបំបាត់ការជួញដូរស្ត្រីនិងកុមារនិងជួយដល់ជនរងគ្រោះដោយសារការជួញដូរ។

- កិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីនីតិវិធីប្រតិបត្តិក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយសារអំពើជួញដូរ។

- បច្ចុប្បន្ន ព្រះរាជាណាចក្រកម្ពុជាកំពុងដំណើរការរៀបចំធ្វើកិច្ចព្រមព្រៀងជាមួយប្រទេសម៉ាឡេស៊ីផងដែរ។

៥១- នៅក្នុងប្រទេសមានកិច្ចព្រមព្រៀងស្តីពីគោលការណ៍ណែនាំអនុវត្តនិងកិច្ចសហការរវាងស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធនិងបណ្តាទីភ្នាក់ងារជនរងគ្រោះក្នុងដំណើររឿងក្តីជួញដូរមនុស្ស ដែលបានចុះហត្ថលេខានៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៧។

៥២- ជំពូកទី៧ស្តីពីសំណងរដ្ឋប្បវេណីនៃច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ជាពិសេសមាត្រា៤៥ បញ្ញត្តទុកជាមោឃៈនូវរាល់កិច្ចសន្យាសម្រាប់បំពេញនូវអំពើលក់ដូរ មនុស្សឬអំពើធ្វើអាជីវកម្មផ្លូវភេទ។ មាត្រា៤៨ចែងពីទោសបន្ថែមដែលមានដូចជា៖

១- ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុទាំងឡាយដែលត្រូវបានប្រើប្រាស់ឬត្រូវប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស

២- ការរឹបអូសសម្ភារៈទាំងឡាយដែលជាកម្មវត្ថុនៃបទល្មើស

៣- ការរឹបអូសប្រាក់ចំណូលឬទ្រព្យដែលរកបានឬជាផលនៃបទល្មើស

៤- ការបិទការផលិតដែលបម្រើដល់ការប្រព្រឹត្តបទល្មើស

៥- ការដាក់កំហិតលើសិទ្ធិពលរដ្ឋ និង

៦- ការហាមឃាត់ការស្នាក់នៅ។

៥៣- ក្រមព្រហ្មទណ្ឌបានកំណត់ទោសបន្ថែម មានជាអាទិ៍៖

១- ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដែលប្រើប្រាស់ក្នុងពេលប្រព្រឹត្តបទល្មើសឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស

២- ការរឹបអូសវត្ថុឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស

៣- ការរឹបអូសផលទុនឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស

៤- ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុដែលលំអទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត

៥- ការបិទគ្រឹះស្ថានដែលប្រើប្រាស់ដើម្បីត្រៀមឬប្រព្រឹត្តបទល្មើស

៦- ការដាក់កំហិតលើសិទ្ធិពលរដ្ឋ

៧- ការហាមឃាត់ចំពោះការស្នាក់នៅ

៨- ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា

៩- ការហាមឃាត់ចំពោះការចូលនិងការស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាចំពោះទណ្ឌិតដែលជាជនបរទេស។ ទោសបន្ថែមទាំងនេះអាចប្រកាសបានប្រសិនបើបទល្មើសដែលមានចែងក្នុងពិធីសារត្រូវបានប្រព្រឹត្ត។

## កិច្ចការពារសិទ្ធិជនរងគ្រោះ

*ឆ្លើយតបនឹងមាត្រា៨ និងមាត្រា៩ កថាខណ្ឌទី៣និងទី៤នៃពិធីសារបន្ថែម។*

៥៤- សេចក្តីសម្រេចលេខ១០៧ ក.ជ.ក.ក. ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីគោលការណ៍របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារក្នុងការការពារសិទ្ធិកុមាររងគ្រោះដោយសារការជួញដូរ ចែងថា "នៅក្នុងគ្រប់សកម្មភាពទាំងអស់ដែលទាក់ទងនឹងកុមាររងគ្រោះដោយសារការជួញដូរ ទោះបីជាត្រូវបានអនុវត្តដោយស្ថាប័នសុខុមាលភាពសាធារណៈរបស់រដ្ឋឬឯកជន នគរបាល តុលាការ អាជ្ញាធររដ្ឋបាល ឬអង្គការនីតិបញ្ញត្តិក៏ដោយ ឧត្តមប្រយោជន៍របស់កុមារទាំងនោះត្រូវគិតជាចម្បង"។

ក្រសួងយុត្តិធម៌បានចេញប្រកាសលេខ៦២ កយប្រក/០៨ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៨ ស្តីពីការប្រើប្រាស់របាំងក្នុងបន្ទប់សវនាការនិងបន្ទប់សវនាការភ្ជាប់បណ្តាញទូរទស្សន៍ដើម្បីយកសក្ខីកម្មពីកុមារ ឬជនរងគ្រោះ ឬសាក្សីដែលងាយរងគ្រោះដើម្បី៖

- ផ្តល់នូវក្របខ័ណ្ឌច្បាប់មួយដែលអាចផ្តល់បរិយាកាសមួយដែលមានសុវត្ថិភាពនិងមានការគាំទ្រឲ្យកុមារ ឬជនរងគ្រោះ ឬសាក្សីដែលងាយរងគ្រោះ អាចផ្តល់នូវព័ត៌មានដែលខ្លួនបានពើបប្រទះ
- ទទួលបាននូវព័ត៌មានស្តីពីបទល្មើសឲ្យបានច្រើនតាមតែអាចធ្វើទៅបាន
- កាត់បន្ថយការប៉ះទង្គិចផ្លូវចិត្តខ្លាំងទៅលើកុមារ ឬជនរងគ្រោះ ឬសាក្សីដែលងាយរងគ្រោះ
- បន្ថយនូវការគំរាមកំហែងចំពោះសុវត្ថិភាពរបស់កុមារ ឬជនរងគ្រោះ ឬសាក្សីដែលងាយរងគ្រោះ។

៥៥- ក្រសួងយុត្តិធម៌បានបំពាក់របាំងក្នុងបន្ទប់សវនាការនៅក្នុងសាលាដំបូងរាជធានី ខេត្តទូទាំងប្រទេស។ បន្ទប់សវនាការភ្ជាប់បណ្តាញទូរទស្សន៍ ដើម្បីយកសក្ខីកម្មពីកុមារ ឬជនរងគ្រោះ ឬសាក្សីដែលងាយរងគ្រោះ ត្រូវបានបំពាក់នៅក្នុងសាលាដំបូងរាជធានី ខេត្តចំនួន០៥។ ក្រសួងបានផលិតវីដេអូ

សម្រាប់អប់រំណែនាំកុមាររងគ្រោះ កុមារជាសាក្សី និងកុមារល្មើសនឹងច្បាប់ស្តីពីតួនាទីរបស់តួអង្គយុត្តិធម៌ព្រហ្មទណ្ឌ។ ក្រសួងមហាផ្ទៃបានប្រើប្រាស់បន្ទប់សម្ភាសអនីតិជនរងគ្រោះ ដែលមានបំពាក់ឧបករណ៍បច្ចេកទេសត្រឹមត្រូវនៅតាមនាយកដ្ឋានជំនាញនិងរាជធានីខេត្តអាទិភាពមួយចំនួន។

៥៦- គិតត្រឹមខែឧសភា ឆ្នាំ២០១០ អង្គការដែលចុះអនុស្សរណៈយោគយល់គ្នា(MoU) ជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សរុបមានចំនួន១៧៤ ក្នុងនោះអង្គការមិនមែនរដ្ឋាភិបាលជាតិមានចំនួន៦៧ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិមានចំនួន១០៧ ដើម្បីផ្តល់សេវាសុខុមាលភាពកុមារ សុខុមាលភាពសង្គម និងសេវាស្តារនីតិសម្បទាដល់មុខសញ្ញាដូចជា ជនចាស់ជរា កុមារកំព្រា កុមារពិការ ក៏ដូចជាផ្តល់ការការពារជនរងគ្រោះដោយសារអំពើជួញដូរមនុស្សនិងការកេងប្រវ័ញ្ចផ្លូវភេទ។ ក្នុងចំណោមអង្គការទាំងនេះ មានអង្គការជាង២០ដែលផ្តល់ការស្នាក់នៅរយៈពេលវែងនិងខ្លីដើម្បីស្តារនីតិសម្បទា ដូចជា ផ្តល់ការលើកទឹកចិត្ត ការអប់រំស្មារតី ការបណ្តុះបណ្តាលវិជ្ជាជីវៈរយៈពេលខ្លី និងការបង្កើតមុខរបរផ្សេងៗ។ ក្រោយពីទទួលការស្តារនីតិសម្បទា យើងបានធ្វើសមាហរណកម្មទៅក្នុងសហគមន៍វិញ។ រាជរដ្ឋាភិបាលបានបង្កើតនិងអនុវត្តគោលនយោបាយថែទាំជំនួសចំពោះកុមារនិងបទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារតាមមណ្ឌល។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាផ្តល់សេវាបញ្ជូននិងសមាហរណកម្មស្ត្រីនិងកុមាររងគ្រោះនិងងាយរងគ្រោះ ដោយសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល។ ក្នុងឆ្នាំ២០០៩ ជនរងគ្រោះដោយចំណាកស្រុកស្វែងរកការងារធ្វើដោយជួញដូរកម្លាំងពលកម្មនិងដោយអំពើជួញដូរមនុស្ស ចំនួន៩៩២នាក់ ដែលធ្វើមាតុភូមិនិវត្តន៍មកពីព្រះរាជាណាចក្រថៃចំនួន២១៥នាក់ មកពីសាធារណរដ្ឋសង្គមនិយមវៀតណាមចំនួន៧៧៣នាក់ និងមកពីប្រទេសម៉ាឡេស៊ី០៤នាក់ ក្នុងនោះកុមារ៥១៥នាក់ ត្រូវបានស្តារនីតិសម្បទានិងធ្វើសមាហរណកម្ម។ ដោយឡែក ក្នុងប្រទេសមាននារីនិងកុមារីរងគ្រោះដោយសារការជួញដូរផ្លូវភេទចំនួន៨៦៩នាក់ ត្រូវបានសង្គ្រោះនិងផ្តល់សេវាសមស្របនៅមជ្ឈមណ្ឌលរដ្ឋនិងអង្គការមិនមែនរដ្ឋាភិបាល ហើយជនរងគ្រោះចំនួន១ ៨៧៨នាក់ ត្រូវបានធ្វើសមាហរណកម្មនិងបិទករណីចំនួន៥១៦នាក់។ ឆ្នាំ២០១០ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានទទួលនិងស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរផ្លូវភេទនិងជួញដូរកម្លាំងពលកម្មចំនួន១ ៥៥៩នាក់ ក្នុងនោះមកពីព្រះរាជាណាចក្រថៃចំនួន២៥៦នាក់ សាធារណរដ្ឋសង្គមនិយមវៀតណាមចំនួន៥៤៨នាក់ ម៉ាឡេស៊ីចំនួន០៩នាក់ សាធារណរដ្ឋប្រជាធិបតេយ្យទីម័រខាងកើត០៥នាក់ សាធារណរដ្ឋឥណ្ឌា០៩នាក់ អាហ្វ្រិកខាងត្បូង០១នាក់ សាធារណរដ្ឋឥណ្ឌូនេស៊ី០៥នាក់ និងនៅក្នុងប្រទេសចំនួន៧៣០នាក់។ បានបញ្ជូនក្មេងស្រីជនជាតិវៀតណាមរងគ្រោះដោយសារការជួញដូរផ្លូវភេទក្នុងប្រទេសឲ្យត្រឡប់ទៅប្រទេសខ្លួនវិញចំនួន០៥នាក់។ បានធ្វើសមាហរណកម្មនិងតាមដានអនីតិជន(ជនរងគ្រោះ)ចំនួន១ ៦១១នាក់ ក្នុងនោះស្វែងរកគ្រួសារ២៣៧នាក់ ប៉ាន់ប្រមាណគ្រួសារ១៦៥នាក់ សមាហរណកម្ម២១២នាក់ តាមដានបន្ត៥៩៥នាក់ និងបិទករណី៦១៤នាក់។

៥៧- ក្នុងចន្លោះខែតុលា ឆ្នាំ២០០៨ ដល់ខែតុលា ឆ្នាំ២០០៩ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានជួយការពារក្តីជូនជនក្រីក្រចំនួន៥៨៤ករណី ក្នុងនោះមានអនីតិជន៦៦នាក់និងស្ត្រី៩៥នាក់។ ក្រៅពីនេះ សេវាផ្នែកច្បាប់ត្រូវបានផ្តល់ឲ្យកុមារតាមរយៈអង្គការមិនមែនរដ្ឋាភិបាលដែលផ្តល់សេវាផ្នែកច្បាប់។ ក្នុងឆ្នាំ២០១០ គណៈមេធាវីជួយការពារកុមារដែលជាប់ពាក់ព័ន្ធក្នុងប្រព័ន្ធយុត្តិធម៌បានចំនួន១០នាក់។

៥៨- សេចក្តីសម្រេចលេខ១០៧ ក.ជ.ក.ក. ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីគោលការណ៍ការពារសិទ្ធិកុមាររងគ្រោះ ដោយសារការជួញដូរ បានដាក់ចេញនូវគោលការណ៍និងការណែនាំអនុវត្តដូចខាងក្រោម៖

១- ជាគោលការណ៍ សំបុត្រកំណើតជាឯកសារសំខាន់បំផុតសម្រាប់ការស្រាវជ្រាវនិងការកំណត់អត្តសញ្ញាណកុមារ។ ក្នុងករណីដែលមិនបានដឹងអំពីអាយុពិតប្រាកដរបស់ជនរងគ្រោះ ក្រៅពីឯកសារឬសៀវភៅគ្រួសាររបស់ជនរងគ្រោះ អត្តសញ្ញាណបណ្ណ សៀវភៅសិក្ខាគារិក ភិនភាគរូបរាង ភាពចាស់ទុំផ្នែកចិត្តសាស្ត្រ ការអះអាង បណ្ណពិនិត្យសុខភាពឬពិនិត្យធ្មេញ ពិនិត្យឆ្អឹង (ម្រាមដៃ) និងពិនិត្យឌីអិនអេ អាចយកមកពិចារណាក្នុងការកំណត់អាយុកុមាររងគ្រោះដោយសារការជួញដូរ។ ឯកសារទទួលស្គាល់តាមផ្លូវច្បាប់ ដែលបញ្ជាក់ពីកំណើតឬអាយុរបស់កុមារ ដែលទទួលបានពីជនដែលដឹងរឿងទាំងនេះ និងទាក់ទងទៅនឹងការប្រតិបត្តិផ្នែកវប្បធម៌ឬជំនឿដែលបង្ហាញនូវអាយុក៏អាចយកមកពិចារណាផងដែរ។ នៅពេលគ្មានភាពច្បាស់លាស់អំពីអាយុរបស់ជនរងគ្រោះតែមានកត្តាបង្ហាញឲ្យជឿថាជននោះជាកុមារ យើងសន្និដ្ឋានថាជននោះជាកុមារ។ ក្នុងអំឡុងពេលរង់ចាំដំសមស្របមួយសម្រាប់ការផ្ទៀងផ្ទាត់អាយុរបស់ជនរងគ្រោះ ជនរងគ្រោះនោះត្រូវបានគេចាត់ទុកជាកុមារដែលត្រូវទទួលបានវិធានការការពារពិសេសទាំងឡាយដែលមានចែងនៅក្នុងសេចក្តីសម្រេចនេះ។

២- ការស៊ើបអង្កេតមិនត្រូវធ្វើឲ្យប៉ះពាល់ដល់សន្តិសុខរបស់កុមាររងគ្រោះ ដូចជាការមិនឲ្យជនសង្ស័យដឹងពីការស៊ើបអង្កេត ការរក្សាការសម្ងាត់របស់កុមាររងគ្រោះ ជាងនេះទៅទៀត គឺការហាមឃាត់ការថតរូបភាព ការថតសំឡេង និងការផ្សព្វផ្សាយព័ត៌មានដែលធ្វើឲ្យសាធារណជនដឹងអំពីអត្តសញ្ញាណរបស់កុមាររងគ្រោះ។ កុមាររងគ្រោះត្រូវយកចេញពីកន្លែងរកឃើញនិងនាំយកទៅកាន់ទីកន្លែងដែលមានបរិយាកាសល្អនិងមានសុវត្ថិភាព រួមទាំងការបញ្ជូនទៅស្ថាប័នឬអង្គការដែលផ្តល់សេវាសង្គមកិច្ច។ ដើម្បីសុវត្ថិភាពនិងសន្តិសុខរបស់កុមាររងគ្រោះ នគរបាលត្រូវធ្វើការប៉ាន់ប្រមាណអំពីគ្រោះថ្នាក់ដែលអាចកើតឡើង ហើយរក្សាការសម្ងាត់ពីទីកន្លែងនិងអ្នកផ្តល់សេវាដល់កុមារ។

៣- កុមាររងគ្រោះមានសិទ្ធិទទួលបានព័ត៌មានអំពីបញ្ហាទាំងអស់ដែលប៉ះពាល់ដល់ខ្លួន ក្នុងនោះរួមមានការទទួលបានព័ត៌មានអំពីសិទ្ធិដែលខ្លួនអាចទទួលសេវាផ្សេងៗ ការជួបជុំគ្រួសារនិង/ឬដំណើរការនៃការធ្វើមាតុភូមិនិវត្តន៍។

៤- កុមាររងគ្រោះទទួលបានសិទ្ធិបញ្ចេញទស្សនៈដោយសេរី ក្នុងគ្រប់បញ្ហាដែលប៉ះពាល់ដល់ខ្លួន រួមទាំងបញ្ហាដែលទាក់ទងនឹងនីតិវិធីច្បាប់ ការថែទាំជំនួស ការការពារ ព្រមទាំងការកំណត់ និងការអនុវត្តដំណោះស្រាយមួយ ដែលមានរយៈពេលសមស្រប។ ទស្សនៈរបស់កុមាររងគ្រោះដោយសារការជួញដូរត្រូវយកមកពិចារណា ហើយថ្លឹងថ្លែងទៅតាមអាយុ ភាពចាស់ទុំ សមត្ថភាព និងឧត្តមប្រយោជន៍របស់កុមារ។

៥៩- នៅឆ្នាំ២០០៤ មជ្ឈមណ្ឌលបណ្តុះបណ្តាលនិងវិក្រឹតការវិជ្ជាជីវៈមេធាវី បានធ្វើការបណ្តុះបណ្តាលគ្រូបង្គោលអំពីសិទ្ធិកុមារនិងការការពារកុមារតាមផ្លូវច្បាប់ ដោយមានរៀបចំជាសៀវភៅសម្រាប់ការបណ្តុះបណ្តាលនេះ។ ចាប់តាំងពីឆ្នាំ២០០៦មក វគ្គបណ្តុះបណ្តាលមូលដ្ឋានស្តីពីសិទ្ធិកុមារ ច្បាប់និងយុត្តិធម៌ត្រូវបានបញ្ចូលទៅក្នុងវគ្គបណ្តុះបណ្តាលរបស់សាលាមេធាវីសម្រាប់បណ្តុះបណ្តាលដល់សិស្សមេធាវី។ ការបណ្តុះបណ្តាលស្រដៀងនេះ ត្រូវបានធ្វើឡើងនៅរាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការសម្រាប់ចៅក្រមនិងព្រះរាជអាជ្ញាដែលកំពុងបំពេញការងារ និងនិស្សិតចៅក្រមនិងព្រះរាជអាជ្ញា។ រាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការបានផលិតវីដេអូបណ្តុះបណ្តាលចំនួន០២ សម្រាប់មន្ត្រីតុលាការសម្តាសកុមាររងគ្រោះនិងកុមារប្រព្រឹត្តល្មើសនឹងច្បាប់។ ចំនួនចៅក្រម ព្រះរាជអាជ្ញា និងមេធាវីដែលបានទទួលការបណ្តុះបណ្តាល រួមមាន៖

| ឆ្នាំ | ចៅក្រមនិងព្រះរាជអាជ្ញា | មេធាវី |
|---|---|---|
| ២០០៥ | - | ៦០ |
| ២០០៦ | ១០៦ | ៥០ |
| ២០០៧ | ២៤០ | ៨៤ |
| ២០០៨ | ១៨៦ | - |
| ២០០៩ | ២៧០ | ៧៩ |
| ២០១០ | - | ៨៤ (បណ្តុះបណ្តាលនៅខែធ្នូ ឆ្នាំ២០១០) |

៦០- ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល និងក្រសួងយុត្តិធម៌ បានរៀបចំឲ្យមានការបណ្តុះបណ្តាលរួមគ្នានិងការបណ្តុះបណ្តាលដោយឡែកសម្រាប់នគរបាលយុត្តិធម៌ វេជ្ជបណ្ឌិត និងតុលាការស្តីពីនីតិវេជ្ជសាស្ត្រ និងការស៊ើបអង្កេតករណីរំលោភបំពានផ្លូវភេទលើកុមារ លើប្រធានបទ៖

១- ទិដ្ឋភាពនីតិវេជ្ជសាស្ត្រនិងទិដ្ឋភាពសុខុមាលភាពនៃការស៊ើបអង្កេតករណីរំលោភបំពានផ្លូវភេទលើកុមារ។

២- ទិដ្ឋភាពនីតិវេជ្ជសាស្ត្រនិងទិដ្ឋភាពច្បាប់នៃការស៊ើបអង្កេតករណីរំលោភបំពានផ្លូវភេទលើកុមារ។

ក្នុងចន្លោះពីខែតុលា ឆ្នាំ២០០៩ដល់ខែតុលា ឆ្នាំ២០១០ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន បានបើកវគ្គបណ្តុះបណ្តាលចំនួន៣៩វគ្គ ក្នុងនោះមានសិក្ខាកាមចំនួន១ ៧២៤នាក់ និងរៀបចំសិក្ខាសាលាចំនួន១៥វគ្គ មានសិក្ខាកាមចំនួន១ ០៦៨នាក់។

៦១- ពីឆ្នាំ២០០៨ដល់ឆ្នាំ២០១០ នគរបាលយុត្តិធម៌នៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជននិងមន្ត្រីនៃការិយាល័យប្រឆាំងការជួញដូរនិងការពារអនីតិជននៃរាជធានី ខេត្តចំនួន១០ បានទទួលការហ្វឹកហ្វឺនប្រចាំត្រីមាសនៅនឹងកន្លែង ស្តីពីការតាមដានករណី ការគ្រប់គ្រងករណីនៅក្នុងពេលស៊ើបអង្កេតនិងការបញ្ជូនករណីជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ ការកេងប្រវ័ញ្ចផ្លូវភេទ និងអំពើហិង្សាក្នុងគ្រួសារ។ សៀវភៅបណ្តុះបណ្តាលនគរបាលត្រូវបានធ្វើបច្ចុប្បន្នកម្មដោយដាក់បញ្ចូលបទប្បញ្ញត្តិពាក់ព័ន្ធដែលមាននៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនិងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ។ សិក្ខាសាលាថ្នាក់ជាតិចំនួន០២លើក ត្រូវបានរៀបចំឡើងដោយមានការចូលរួមពីការិយាល័យនិងផ្នែកប្រឆាំងការជួញដូរនិងការពារអនីតិជននៃរាជធានី ខេត្តទាំង២៤ ដើម្បីធ្វើការផ្លាស់ប្តូរបទពិសោធនិងមេរៀនល្អក្នុងការចាត់ការករណីរំលោភបំពានផ្លូវភេទ ការកេងប្រវ័ញ្ចផ្លូវភេទ និងអំពើហិង្សាលើស្ត្រីនិងកុមារ និងពិនិត្យឡើងវិញនូវទិដ្ឋភាពច្បាប់និងបច្ចេកទេសស៊ើបអង្កេត។ អធិការ អធិការរងក្រុង ស្រុក ខណ្ឌ ប្រធាន អនុប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ចំនួន៩៥០នាក់ នៃរាជធានី ខេត្តចំនួន១០ បានទទួលការបណ្តុះបណ្តាលស៊ីជម្រៅរៀងរាល់ឆ្នាំទាក់ទងនឹងនីតិវិធីច្បាប់ ជំនាញស៊ើបអង្កេត និងការសហការជាមួយអាជ្ញាធរមូលដ្ឋាន។ នគរបាលយុត្តិធម៌ចំនួន២ ៥៨៨នាក់ បានទទួលការបណ្តុះបណ្តាលនៅបណ្ឌិត្យសភានគរបាលនៅសាលាហ្វឹកហ្វឺននគរបាលនៅតាមភូមិភាគចំនួន០៥ និងនៅសាលាកងរាជអាវុធហត្ថ ដើម្បីធ្វើឲ្យជ្រួតជ្រាបអំពីបញ្ហាទាក់ទងនឹងការរំលោភបំពានផ្លូវភេទ ការកេងប្រវ័ញ្ចផ្លូវភេទ ការជួញដូរកុមារ និងនីតិវិធីក្នុងការចាត់ការករណីទាំងនោះ។

៦២- គិតមកទល់ឆ្នាំ២០០៩ ចំនួន៥៤ភាគរយនៃមន្ត្រីសង្គមកិច្ចថ្នាក់ជាតិ ថ្នាក់រាជធានី ខេត្ត និងចំនួន៨៣ភាគរយនៃមន្ត្រីសង្គមកិច្ចថ្នាក់ក្រុង ស្រុក ខណ្ឌបានទទួលវគ្គបណ្តុះបណ្តាលមូលដ្ឋាននិងជំនាញស្តីពីកិច្ចការសង្គម។ មេរៀនស្តីអំពីតួនាទីមន្ត្រីសង្គមកិច្ចនៅក្នុងប្រព័ន្ធយុត្តិធម៌កុមារត្រូវបានដាក់បញ្ចូលទៅក្នុងវគ្គបណ្តុះបណ្តាលមូលដ្ឋាននិងថ្នាក់ជំនាញខាងសេវាសង្គមកិច្ចនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ក្នុងឆ្នាំ២០០៩ ក្រសួងយុត្តិធម៌បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលពហុវិស័យស្តីពីយុត្តិធម៌កុមារសម្រាប់គ្រូបង្គោលចំនួន៣៥នាក់ដែលជាមន្ត្រីតុលាការ មន្ត្រីសង្គមកិច្ច និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល។

៦៣- ដំណាលគ្នានឹងការផ្តល់កិច្ចការពារសុវត្ថិភាពពិសេសនិងវិធានការសំណងចំពោះកុមាររងគ្រោះនៃបទល្មើស សិទ្ធិរបស់ជនដែលត្រូវបានចោទប្រកាន់ ត្រូវទទួលបានការកាត់ទោសមួយប្រកបដោយភាពយុត្តិធម៌និងមិនលម្អៀង។ មាត្រា៣៨នៃរដ្ឋធម្មនុញ្ញចែងថា ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់

ខ្លួន ឬការឃុំខ្លួនជនណាមួយអាចនឹងធ្វើទៅបានលុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់។ ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តីមិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ។ វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។ ជនជាប់ចោទណាក៏ដោយត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។ ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការឬមានសិទ្ធិរកមេធាវីដើម្បីការពារខ្លួន។ ក្រៅពីនេះ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ បានកំណត់អំពីវិធានទាំងឡាយដែលត្រូវគោរពនិងប្រព្រឹត្តតាមដោយហ្មត់ចត់ ដើម្បីកំណត់ឲ្យច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយនិងដើម្បីធានានូវសិទ្ធិនីតិវិធីរបស់ជនជាប់ចោទ។

៦៤- ក្រៅពីដាក់ចេញនូវវិធានស្តីពីការស្រាវជ្រាវនិងការកំណត់អត្តសញ្ញាណកុមារ សេចក្តីសម្រេចលេខ ១០៧ ក.ជ.ក.ក. ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៧ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ស្តីពីគោលការណ៍ការពារសិទ្ធិកុមាររងគ្រោះដោយសារការជួញដូរ ចែងថា ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវតាក់តែងច្បាប់ គោលនយោបាយ និងនីតិវិធីដើម្បីធានាថាកុមាររងគ្រោះដោយសារការជួញដូរ ដែលមិនមានសញ្ជាតិខ្មែរ មិនត្រូវបានចាត់ទុកជាជនអន្តោប្រវេសខុសច្បាប់ឡើយ។ ចំពោះកុមាររងគ្រោះដែលគ្មានឯកសារស្របច្បាប់ ក្រសួង ស្ថាប័នមានសមត្ថកិច្ចនឹងជួយកុមារដើម្បីធានាឲ្យបានឆាប់រហ័សនូវស្ថានភាពស្របច្បាប់ដូចជា ការផ្តល់លិខិតធ្វើដំណើរបណ្តោះអាសន្នជាដើម។ ក្នុងករណីនេះ កុមារមិនត្រូវបង់ថ្លៃនិងចំណាយផ្សេងៗនៅក្នុងដំណើរការនៃការធ្វើឲ្យបានស្ថានភាពស្របច្បាប់ឡើយ។

## **ជំនួយនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ**

*ឆ្លើយតបនឹងមាត្រា១០នៃពិធីសារបន្ថែម។*

៦៥- កុមារនៅតែជាកម្មវត្ថុដែលត្រូវបានឧក្រិដ្ឋជនជួញដូរយកទៅព្រះរាជាណាចក្រថៃ សាធារណរដ្ឋសង្គមនិយមវៀតណាម និងប្រទេសមួយចំនួនទៀត។ ស្ត្រីនិងក្មេងស្រីជាទូទៅត្រូវបានគេជួញដូរយកទៅធ្វើអាជីវកម្មផ្លូវភេទមួយចំនួនទៀតក៏ត្រូវបានជួញដូរយកទៅធ្វើជាអ្នកសុំទានឬអ្នកធ្វើការងារតាមផ្ទះ។ វិសាលភាពនៃបញ្ហាតម្រូវឲ្យមានកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាមួយប្រទេសដទៃទៀត ជាពិសេសប្រទេសក្នុងមហាអនុតំបន់មេគង្គ។ នៅខែឧសភា ឆ្នាំ២០០៣ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាជាមួយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីដើម្បីលុបបំបាត់ការជួញដូរស្ត្រីនិងកុមារ និងជួយដល់ជនរងគ្រោះដោយសារការជួញដូរ។ នៅឆ្នាំ២០០៤ រាជរដ្ឋាភិបាលបានបង្កើតក្រុមការងារដើម្បីអនុវត្តអនុស្សរណៈនេះ។ នៅខែតុលា ឆ្នាំ២០០៤ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហការប្រឆាំងការជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គ និងបានបង្កើតក្រុមការងារកម្ពុជាដើម្បីអនុវត្តក្នុងខែកក្កដា ឆ្នាំ២០០៥។ ក្រុមការងារកម្ពុជារួមជាមួយក្រុមការងារនៃបណ្តាប្រទេសនៅមហាអនុតំបន់មេគង្គបានរៀបចំនិងអនុវត្តផែនការសកម្មភាពអនុតំបន់៣ឆ្នាំលើកទី១(២០០៤-២០០៧)។ ក្នុងខែធ្នូ ឆ្នាំ២០០៧ នៅក្រុងប៉េកាំង សាធារណរដ្ឋប្រជាមានិតចិន ក្រុមការងារទាំង០៦ប្រទេស បានអនុម័ត ផែនការសកម្មភាពអនុតំបន់

៣ឆ្នាំ លើកទី២ និងរដ្ឋមន្ត្រីនៃប្រទេសទាំង០៦ បានចុះហត្ថលេខាលើសេចក្តីប្រកាសរួមCOMMIT។ នៅខែតុលា ឆ្នាំ២០០៥ រាជរដ្ឋាភិបាលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាមស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីដើម្បីលុបបំបាត់ការជួញដូរស្ត្រី និងកុមារ និងជួយដល់ជនរងគ្រោះដោយសារការជួញដូរ។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានៃព្រះរាជាណាចក្រកម្ពុជានិងក្រសួងនគរបាលរបស់វៀតណាមបានចុះកិច្ចព្រមព្រៀងស្តីពីនីតិវិធីប្រតិបត្តិបទដ្ឋានក្នុងការកំណត់អត្តសញ្ញាណ និងការធ្វើមាតុភូមិនិវត្តន៍របស់ជនរងគ្រោះដោយសារអំពើជួញដូរនៅខែធ្នូ ឆ្នាំ២០០៩។ ក្នុងឆ្នាំ២០១០ នាយកដ្ឋានប្រឆាំងការជួញដូរនិងការពារអនីតិជនបានជួបប្រជុំជាមួយសមភាគីវៀតណាមស្តីពីកិច្ចសហប្រតិបត្តិការការពារសន្តិសុខសណ្តាប់ធ្នាប់ ព្រំដែនព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋសង្គមនិយមវៀតណាម ជាពិសេសបទល្មើសជួញដូរឆ្លងដែននិងបូកសរុបលទ្ធផលការងារប្រចាំ៥ឆ្នាំនៃការអនុវត្តកិច្ចព្រមព្រៀងសហប្រតិបត្តិការដើម្បីលុបបំបាត់ការជួញដូរស្ត្រីនិងកុមារ។ ក្រៅពីនេះ នាយកដ្ឋានបានចូលរួមប្រជុំពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សនៅសាធារណរដ្ឋឥណ្ឌូណេស៊ី នៅសាធារណរដ្ឋហ្វីលីពីន និងចូលរួមប្រជុំថ្នាក់ប្រធាននាយកដ្ឋានឯកទេសប្រឆាំងការជួញដូរមនុស្សលើកទី១៨ របស់អាស៊ានទាំង១០ នៅសហភាពមីយ៉ាន់ម៉ា។ ក្រសួងកិច្ចការនារីបានពិភាក្សាជាមួយប្រទេសម៉ាឡេស៊ី លើសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់គ្នាដើម្បីលុបបំបាត់អំពើជួញដូរមនុស្ស។ អនុស្សរណៈស្តីពីគម្រោងសហប្រតិបត្តិការក្នុងទ្វីបអាស៊ីដើម្បីបង្ការការជួញដូរមនុស្ស ត្រូវបានចុះហត្ថលេខា ក្នុងខែវិច្ឆិកា ឆ្នាំ២០០៣ រវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋមន្ត្រីប្រទេសអូស្ត្រាលី។ ព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខាផងដែរលើសន្ធិសញ្ញាស្តីពីបត្យាប័នជាមួយប្រទេសសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ព្រះរាជាណាចក្រថៃ សាធារណរដ្ឋប្រជាមានិតចិន និងសាធារណរដ្ឋកូរ៉េ។ ក្រៅពីនេះមានកិច្ចសហប្រតិបត្តិការទ្វេភាគីដូចជារវាងគណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារជាមួយនឹងសហរដ្ឋអាមេរិក។

៦៦- ក្រោយពីបានក្លាយជារដ្ឋភាគីនៃអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារនិងកិច្ចសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេសនៅឆ្នាំ២០០៧ ព្រះរាជាណាចក្រកម្ពុជាបាននិងកំពុងសហការយ៉ាងជិតស្និទ្ធជាមួយការិយាល័យអចិន្ត្រៃយ៍នៃសន្និសីទអន្តរជាតិក្រុងឡាអេស្តីពីនីតិអន្តរជាតិឯកជននិងប្រទេសទទួលកូនសុំលើវិស័យសុំកូនអន្តរប្រទេសដើម្បីអនុវត្តអនុសញ្ញាក្រុងឡាអេ ពិធីសារនេះ និងច្បាប់ស្តីពីសុំកូនអន្តរប្រទេស។

៦៧- ដើម្បីសម្របសម្រួលនិងធ្វើសហប្រតិបត្តិការក្នុងវិស័យយុត្តិធម៌កុមារ ជាពិសេសទាក់ទងនឹងអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ រាជរដ្ឋាភិបាលបានបង្កើតក្រុមការងារជាតិស្តីពីគំនិតផ្តួចផ្តើមថ្នាក់រដ្ឋមន្ត្រីប្រឆាំងអំពើជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គ(COMMIT) ដែលស្ថិតក្រោមការដឹកនាំនិងសម្របសម្រួលរបស់ក្រសួងកិច្ចការនារី។ ក្រុមពិគ្រោះយោបល់មួយដែលមានសមាសភាពមកពីដៃគូអភិវឌ្ឍ បានរួមចំណែកយ៉ាងសំខាន់ដល់ការត្រួតពិនិត្យតាមដានស្ថានភាពកុមារនៅក្នុង

ប្រព័ន្ធយុត្តិធម៌តាមរយៈបណ្តាញរបស់ខ្លួន។

៦៨- ព្រះរាជាណាចក្រកម្ពុជាបានធ្វើការប្តេជ្ញាចិត្តនៅក្នុងក្របខ័ណ្ឌអន្តរជាតិ ជាពិសេសក្នុងក្របខ័ណ្ឌអាស៊ាន ក៏ដូចជាអាស៊ានជាមួយប្រទេសជប៉ុន សាធារណរដ្ឋឥណ្ឌា សាធារណរដ្ឋកូរ៉េ កាណាដា និងនូវែលហ្សេឡង់ ដើម្បីធ្វើសហប្រតិបត្តិការៈ

- ប្រយុទ្ធប្រឆាំងភេរវកម្មអន្តរជាតិ
- បង្ក្រាបការជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ
- លុបបំបាត់អំពើហិង្សាលើស្ត្រីនៅក្នុងតំបន់អាស៊ាន។

៦៩- ខែមីនា ឆ្នាំ២០០៥ ក្រសួងមហាផ្ទៃបានបញ្ជូនមន្ត្រីនគរបាលជំនាញទៅសាធារណរដ្ឋសេរ៉ាឡេអូន និងលីបេរីយ៉ា ដើម្បីធ្វើជាអ្នកឧទ្ទេសនាមសម្រាប់វគ្គបណ្តុះបណ្តាលទាក់ទងនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ ក្នុងឆមាសទី១ ឆ្នាំ២០១០នេះ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន បានចែករំលែកបទពិសោធទាក់ទងនឹងការបង្ក្រាបអំពើទិញពេស្យាចារកុមារតាមប្រព័ន្ធអ៊ិនធឺណេតនៅព្រះរាជាណាចក្រថៃ។ ក្នុងឆ្នាំ២០១០ មន្ត្រីនៃនាយកដ្ឋានប្រឆាំងការជួញដូរនិងការពារអនីតិជន បានចូលរួមផ្តល់សក្ខីកម្មក្នុងពេលសវនាការពលរដ្ឋអាមេរិកនៅក្រុងឡូស់អង់ជេឡេស រដ្ឋកាលីហ្វ័រញ៉ាសហរដ្ឋអាមេរិកពីបទរួមភេទជាមួយកុមារីអាយុក្រោម១៨ឆ្នាំនៅព្រះរាជាណាចក្រកម្ពុជា។

## បទប្បញ្ញត្តិច្បាប់ដទៃទៀត

*ឆ្លើយតបនឹងមាត្រា១១នៃពិធីសារបន្ថែម។*

៧០- ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ជាច្បាប់ដែលមិនគ្រាន់តែមានគោលបំណងអនុវត្តកាតព្វកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជាចំពោះពិធីសារប៉ុណ្ណោះទេ តែច្បាប់នេះមានគោលបំណងអនុវត្តផងដែរតាមពិធីសារអង្គការសហប្រជាជាតិស្តីពីការទប់ស្កាត់ ការបង្ក្រាប និងការផ្តន្ទាទោស ការជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារបន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង ក៏ដូចជាឧបករណ៍និងកិច្ចព្រមព្រៀងអន្តរជាតិផ្សេងៗទៀតទាក់ទងនឹងការជួញដូរមនុស្ស ដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នឬចុះហត្ថលេខា។ ច្បាប់នេះកំណត់អំពើជាច្រើនថាជាបទល្មើសទាក់ទងទៅនឹងអំពើជួញដូរមនុស្សនិងអំពើអាជីវកម្មផ្លូវភេទ ហើយបង្កើតឲ្យមានស្ថានទម្ងន់ទោសចំពោះអ្នកប្រព្រឹត្តបទល្មើសទាំងនេះលើកុមារ។

៧១- ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើច្បាប់អន្តរជាតិមួយចំនួនដែលពាក់ព័ន្ធនឹងការទប់ស្កាត់ការជួញដូរកុមារ ពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារមាន ជាអាទិ៍ៈ

- អនុសញ្ញា ILO លេខ១៣៨ លេខ២៩ និងលេខ១៨២
- អនុសញ្ញាក្រុងឡាអេស្តីពីកិច្ចសហប្រតិបត្តិការសុំកូនអន្តរប្រទេស

- ពិធីសារស្តីពីការទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្មចំពោះការជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ ដែលបំពេញបន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំងបទឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង។

ការផ្តល់សច្ចាប័នលើលិខិតុបករណ៍អន្តរជាតិទាំងនេះ បានជួយរួមចំណែកធ្វើឲ្យសម្រេចបាននូវសិទ្ធិរបស់កុមារប្រសើរជាងបទប្បញ្ញត្តិនៃពិធីសារនេះ។

## សេចក្តីសន្និដ្ឋាន

៧២- ប៉ុន្មានឆ្នាំកន្លងមកនេះ ព្រះរាជាណាចក្រកម្ពុជាទទួលបានលទ្ធផលជាផ្លែផ្កាគួរឲ្យមានមោទនភាពក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច រួមទាំងការអភិវឌ្ឍវិស័យសុខុមាលភាពកុមារ ការការពារកុមារជាទូទៅ និងដោយឡែកគឺការទប់ស្កាត់ ការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ។ បច្ចុប្បន្ននេះមានការផ្លាស់ប្តូរការយល់ដឹងគួរឲ្យកត់សម្គាល់ក្នុងមជ្ឈដ្ឋានសាធារណៈទាក់ទងនឹងការទប់ស្កាត់ការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារនិងរូបភាពអាសអាភាសកុមារ ហើយរាជរដ្ឋាភិបាលបាននិងកំពុងយកចិត្តទុកដាក់លើការទប់ស្កាត់តាមរយៈវិធានការតឹងរ៉ឹងនានា និងការអនុវត្តច្បាប់។ ថ្នាក់ដឹកនាំនៅគ្រប់លំដាប់ថ្នាក់និងស្ថាប័ននានាកាន់តែមានការយកចិត្តទុកដាក់និងចូលរួមចំណែកយ៉ាងសកម្មក្នុងការងារការពារកុមារ និងត្រូវបានអនុវត្តយ៉ាងទូលំទូលាយនៅក្នុងសង្គមជារួម និងដោយឡែក មានជាយុទ្ធនាការស្តីពីការការពារកុមារ។ ការទប់ស្កាត់អំពើពេស្យាចារនិងការជួញដូរកុមារ ទទួលបានការចូលរួមពីសង្គមយ៉ាងទូលំទូលាយ ចាប់តាំងពីស្ថាប័ននីតិប្បញ្ញត្តិរហូតដល់ប្រព័ន្ធយុត្តិធម៌និងស្ថាប័នពាក់ព័ន្ធ។ វិធីសាស្ត្រថ្មីៗដ៏មានប្រយោជន៍ត្រូវបានយកមកអនុវត្តយ៉ាងទូលំទូលាយ ដោយប្រើប្រាស់នូវធនធានជាតិនិងអន្តរជាតិ។ ជាលទ្ធផល ចំនួនកុមារដែលត្រូវបានគេជួញដូរនិងបំពារបំពានផ្លូវភេទត្រូវបានកាត់បន្ថយ។

៧៣- ទន្ទឹមនឹងលទ្ធផលខាងលើ ព្រះរាជាណាចក្រកម្ពុជានៅជួបបញ្ហាមួយចំនួនដែលត្រូវបន្តពុះពារថែមទៀតក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច ជាពិសេសអភិវឌ្ឍវិស័យសុខុមាលភាពកុមារ ដោយផ្តោតទៅលើការងារសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- លើកស្ទួយកិច្ចសហប្រតិបត្តិការក្នុងចំណោមស្ថាប័នអនុវត្តច្បាប់ យុត្តិធម៌ និងសង្គមកិច្ច។
- បន្តការលើកកម្ពស់ការយល់ដឹងអំពីច្បាប់ ការអនុវត្តច្បាប់ ការទប់ស្កាត់បទល្មើសនិងបញ្ហាសង្គម។
- បន្តលើកកម្ពស់ការទទួលខុសត្រូវថែមទៀតរបស់ស្ថាប័នមានសមត្ថកិច្ច អង្គការសង្គមស៊ីវិល សហគមន៍ និងគ្រួសារក្នុងការគ្រប់គ្រង ការការពារ និងការអប់រំដល់កុមារ។
- បង្កើតកម្មវិធីរួមគ្នាដើម្បីទប់ស្កាត់និងដោះស្រាយបញ្ហាទាក់ទងនឹងការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារជាមួយនឹងការអនុវត្តនូវកម្មវិធីអភិវឌ្ឍសេដ្ឋកិច្ចសង្គម។
- បង្កើនការវិនិយោគទៅលើការស្រាវជ្រាវ ការប្រមូល ការគ្រប់គ្រង និងការវិភាគទិន្នន័យទាក់ទងនឹងកុមារ។

- រកឲ្យឃើញបទល្មើសនិងបង្កើនល្បឿនការស៊ើបអង្កេត ការចោទប្រកាន់ និងការផ្តន្ទាទោសជនល្មើសដែលជួញដូរកុមារ ទៅតាមផ្លូវច្បាប់។
- បន្តពង្រឹងតួនាទី ភារកិច្ច ការដឹកនាំ និងភាពម្ចាស់ការរបស់គណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ។
- ជំរុញការអនុម័តផែនការសកម្មភាពជាតិលើកទី២ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទ។
- បន្តកិច្ចសហប្រតិបត្តិការល្អជាមួយដៃគូអភិវឌ្ឍ សង្គមស៊ីវិល និងអន្តរជាតិ។

## ឧបសម្ព័ន្ធ

- ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទឆ្នាំ២០០៨
- ច្បាប់ស្តីពីសុំកូនអន្តរប្រទេសឆ្នាំ២០០៩
- គោលនយោបាយនិងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្សឆ្នាំ២០០៩
- សេចក្តីសម្រេចលេខ១០៧ ក.ជ.ក.ក. ចុះថ្ងៃទី២០ខែធ្នូ ឆ្នាំ២០០៧ ស្តីពីគោលការណ៍ការពារសិទ្ធិកុមាររងគ្រោះដោយសារការជួញដូរ

## អត្ថបទយោង

- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣
- របាយការណ៍បូកសរុបលទ្ធផលការងារ ប.ជ.រ.ព.ភ. ឆ្នាំ២០០៩ និងទិសដៅឆ្នាំ២០១០ ចុះថ្ងៃទី ០៣/០៣/២០១០
- របាយការណ៍អនុវត្តសេចក្តីសម្រេចចិត្តលេខ ២០០៩/២៦ របស់ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមកិច្ច ស្តីពីកិច្ចខិតខំប្រឹងប្រែងជាតិនិងអន្តរជាតិដើម្បីកំណែទម្រង់យុត្តិធម៌កុមារឆ្នាំ២០១០
- របាយការណ៍លើកទី២និងទី៣របស់កម្ពុជា ស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារពីឆ្នាំ២០០០ ដល់ឆ្នាំ២០០៧
- ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩
- ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧
- ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទឆ្នាំ២០០៨
- ច្បាប់ស្តីពីសុំកូនអន្តរប្រទេសឆ្នាំ២០០៩
- បទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារឆ្នាំ២០០៨
- សេចក្តីសម្រេចលេខ១០៧ ក.ជ.ក.ក. ចុះថ្ងៃទី២០ខែធ្នូ ឆ្នាំ២០០៧ ស្តីពីគោលការណ៍ការពារសិទ្ធិកុមាររងគ្រោះដោយសារការជួញដូរ
- លទ្ធផលកិច្ចប្រជុំស្តីពីការបង្ហាញគោលការណ៍ណែនាំថ្មីរបស់អង្គការសហប្រជាជាតិសម្រាប់ធ្វើរបាយការណ៍អំពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារឆ្នាំ២០១០
- របាយការណ៍បូកសរុបពិនិត្យឡើងវិញនូវការងារពាក់កណ្តាលអាណត្តិកម្មវិធី២០០៦-២០១០ ខែតុលា ឆ្នាំ២០០៨
- **Strategic Information Response Network, UNIAP, 2010 Edition.**